ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## អាជ្ញាធរអគ្គិសនីកម្ពុជា

# របាយការណ៍វិស័យអគ្គិសនី
# នៃព្រះរាជាណាចក្រកម្ពុជា
# ឆ្នាំ ២០០៤

រៀបចំដោយអាជ្ញាធរអគ្គិសនីកម្ពុជា

ខែកក្កដា ឆ្នាំ ២០០៥

# អារម្ភកថា

យោងតាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាមានភារកិច្ចត្រូវប្រមូលទិន្នន័យ និងពត៌មានផ្សេងៗពីអ្នកកាន់អាជ្ញាប័ណ្ណទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីរៀបចំជា **របាយការណ៍វិស័យអគ្គិសនីប្រចាំឆ្នាំរបស់ព្រះរាជាណាចក្រកម្ពុជា** ។ របាយការណ៍នេះប្រមូលផ្តុំនូវទិន្នន័យ និងពត៌មានសំខាន់ៗពាក់ព័ន្ធនឹងការធ្វើសេវាកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីផ្សព្វផ្សាយបង្ហាញជូនរាជរដ្ឋាភិបាល ស្ថាប័ននានា អ្នកវិនិយោគ និងសាធារណជន ដែលចង់ដឹងពីស្ថានភាពបច្ចុប្បន្នរបស់វិស័យអគ្គិសនី ។

ដើម្បីសំរួលដល់ការងារប្រមូលទិន្នន័យ និងពត៌មានផ្សេងៗនៃវិស័យអគ្គិសនីក្នុងគោលបំណងរៀបចំរបាយការណ៍ខាងលើ ច្បាប់អគ្គិសនីបានកំណត់ឱ្យអ្នកកាន់អាជ្ញាប័ណ្ណម្នាក់ៗ ត្រូវផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជានូវ :

១. របាយការណ៍សង្ខេបប្រចាំឆ្នាំនៃបណ្តាសកម្មភាពរបស់អ្នកកាន់អាជ្ញាប័ណ្ណក្នុងឆ្នាំកន្លងមក
២. ផែនការប្រចាំឆ្នាំដែលរៀបរាប់អំពីសកម្មភាពរបស់អ្នកកាន់អាជ្ញាប័ណ្ណដែលត្រូវអនុវត្តសម្រាប់ឆ្នាំបន្ទាប់និង
៣. របាយការណ៍ សេចក្តីប្រកាស និងពត៌មានផ្សេងៗទៀតដែលអាជ្ញាធរអគ្គិសនីកម្ពុជាកំណត់ដោយបទប្បញ្ញត្តិ ថាចាំបាច់ និងសមស្រប ។

អាជ្ញាធរអគ្គិសនីកម្ពុជា បានចាប់ផ្តើមដំណើរការការងាររបស់ខ្លួនពីថ្ងៃទី ៣ ខែកញ្ញា ឆ្នាំ ២០០១ ។ ក្នុងរយៈពេលជាង ៣ឆ្នាំ នៃការអនុវត្តន៏ការងាររបស់ខ្លួននេះ អាជ្ញាធរអគ្គិសនីកម្ពុជាបានខិតខំបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនយ៉ាងសកម្មដោយប្រមូលផ្តុំយកចិត្តទុកដាក់រៀបចំលក្ខណៈសម្បត្តិជាមូលដ្ឋាននានាក្នុងការអនុវត្តន៍នូវខ្លឹមសារកំណត់របស់ច្បាប់អគ្គិសនី ដើម្បីជំរុញការអភិវឌ្ឍន៍វិស័យអគ្គិសនីប្រកបដោយនិរន្តភាព និងពង្រឹងការគោរពច្បាប់ក្នុងការធ្វើសេវាកម្ម និងការប្រើប្រាស់អគ្គិសនី ។ រហូតដល់ចុងឆ្នាំ ២០០៤ សេវាករអគ្គិសនីសំខាន់ៗចំនួន ១០៧ ដែលគ្រប់គ្រងទីផ្សារអគ្គិសនីជាង ៩៥% នៃទីផ្សារអគ្គិសនីទាំងមូលរបស់ព្រះរាជាណាចក្រកម្ពុជាបានឋិតនៅក្រោមអាជ្ញាប័ណ្ណ បទប្បញ្ញត្តិ និងការត្រួតពិនិត្យជាប្រចាំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។ ដោយយល់ឃើញថា របាយការណ៍វិស័យអគ្គិសនីគឺជាឯកសារមួយដែលចាំបាច់ និងសំខាន់ អាជ្ញាធរអគ្គិសនីកម្ពុជាបានចាប់ផ្តើមរៀបចំ និងចេញផ្សាយរបាយការណ៍វិស័យអគ្គិសនីរបស់ព្រះរាជាណាចក្រកម្ពុជាលើកទី១ នៅឆ្នាំ ២០០៤ ដែលបង្ហាញនូវទិន្នន័យ និងពត៌មានសំខាន់ៗពាក់ព័ន្ធនឹងការធ្វើសេវាកម្មអគ្គិសនីនៅក្នុងឆ្នាំ ២០០៣ ។ នៅឆមាស

ទី១ ឆ្នាំ ២០០៥ អាជ្ញាធរអគ្គិសនីកម្ពុជាបានចាប់ផ្តើមប្រមូលទិន្នន័យ និងពត៌មាននានាក្នុងឆ្នាំ ២០០៤ របស់អ្នកកាន់អាជ្ញាប័ណ្ណ ដើម្បីរៀបចំរបាយការណ៍វិស័យអគ្គិសនីរបស់ព្រះរាជាណាចក្រកម្ពុជាលើកទី ២ សំរាប់ឆ្នាំ ២០០៤ តាមការកំណត់របស់ច្បាប់អគ្គិសនី ។ តាមផែនការរបស់អាជ្ញាធរអគ្គិសនីកម្ពុជា របាយការណ៍វិស័យអគ្គិសនីរបស់ព្រះរាជាណាចក្រកម្ពុជានេះនឹងត្រូវចេញ១ឆ្នាំម្តង ដើម្បីឱ្យទិន្នន័យ និង ពត៌មាន នានាក្នុងវិស័យអគ្គិសនី តាមទាន់សភាពការណ៍វិវត្តន៍ជាក់ស្តែងរបស់វិស័យ ។

អាជ្ញាធរអគ្គិសនីកម្ពុជាសង្ឃឹមថា របាយការណ៍វិស័យអគ្គិសនីនេះនឹងក្លាយទៅជាឯកសារមួយដែល មានតម្លៃសំរាប់ការយល់ដឹងពីវិស័យអគ្គិសនីរបស់ព្រះរាជាណាចក្រកម្ពុជា ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

# តារាងមាតិកា


ទំព័រ

**ជំពូកទី ១ : ពត៌មានទូទៅ** **៧**

១.១ : សេចក្តីផ្តើម ៨

១.២ : ការវិវត្តន៍របស់វិស័យអគ្គិសនីនៅកម្ពុជាចាប់ពីការកកើតរហូតដល់ឆ្នាំ ១៩៧៩ ៩

១.៣ : ការវិវត្តន៍របស់វិស័យអគ្គិសនីចាប់ពីឆ្នាំ ១៩៧៩ រហូតដល់បច្ចុប្បន្ន ១១

**ជំពូកទី ២ : គោលការណ៍ច្បាប់ និងបទប្បញ្ញត្តិក្នុងការគ្រប់គ្រងវិស័យអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា** **១៥**

២.១ : ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ១៦

២.២ : ការបែងចែកភារៈកិច្ចរវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអាជ្ញាធរអគ្គិសនីកម្ពុជា ១៨

២.៣ : តួនាទីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងវិស័យអគ្គិសនី ២០

២.៣.១ : ការត្រួតពិនិត្យលើការធ្វើសេវាកម្មអគ្គិសនី ២០

២.៣.២ : ការគ្រប់គ្រងលើទំនាក់ទំនងរវាងការផ្តល់ ការទទួល និងការប្រើប្រាស់សេវាអគ្គិសនី ២១

២.៣.៣ : លិខិតបទដ្ឋានសំរាប់គ្រប់គ្រងនិងបញ្ញត្តិលើការធ្វើសេវាកម្ម និងការប្រើប្រាស់អគ្គិសនី ២២

**ជំពូកទី ៣ : ពត៌មានស្តីពីអាជ្ញាធរអគ្គិសនីកម្ពុជា ~ បញ្ញត្តិករក្នុងវិស័យអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា** **២៦**

៣.១ : បញ្ញត្តិករក្នុងវិស័យអគ្គិសនី ២៧

៣.២ : រចនាសម្ព័ន្ធរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ២៧

៣.៣ : ថវិការបស់អាជ្ញាធរអគ្គិសនីកម្ពុជា និងកម្រៃអាជ្ញាប័ណ្ណ ២៨

**ជំពូកទី ៤ : ពត៌មានស្តីពីអាជ្ញាប័ណ្ណ និងអ្នកកាន់អាជ្ញាប័ណ្ណនៅក្នុងព្រះរាជាណាចក្រកម្ពុជា** **៣០**

៤.១ : អាជ្ញាប័ណ្ណសំរាប់ធ្វើសេវាកម្មអគ្គិសនី ៣១
៤.២ : អាជ្ញាប័ណ្ណដែលបានចេញ និង តំបន់ផ្គត់ផ្គង់ ៣២
៤.៣ : ស្ថានភាពទូទៅនៃការធ្វើសេវាកម្មអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ ៣៦
៤.៣.១ : ស្ថានភាពនៃការធ្វើសេវាកម្មអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណរួម ៣៧
៤.៤ : ផែនការរបស់អាជ្ញាធរអគ្គិសនីកម្ពុជាសំរាប់ស្តារកំរិតកំពស់ការងារធ្វើសេវាកម្មអគ្គិសនី ៣៨
៤.៤.១ : កម្មវិធីជួយណែនាំ បង្ហាត់បង្ហាញ និងបណ្តុះបណ្តាល ៣៨
៤.៤.២ : កម្មវិធីលើកទឹកចិត្ត និងដាក់ពិន័យ ៣៩
៤.៤.៣ : កម្មវិធីកំណត់ហិរញ្ញវត្ថុ និង ប្រកួតប្រជែង ៣៩
៤.៥ : ការកែលំអមធ្យោបាយធ្វើសេវាកម្មអគ្គិសនី ៤០
៤.៥.១ : ការកែលំអមធ្យោបាយផលិតកម្មរបស់សេវាករតូចៗ ៤៣
៤.៥.២ : ការកែលំអមធ្យោបាយចែកចាយរបស់សេវាករតូចៗ ៤៥

**ជំពូកទី ៥ : របាយការណ៍ស្តីពីការផលិត ការនាំចូល ការបញ្ជូន និងការផ្គត់ផ្គង់អគ្គិសនី ៤៨**

៥.១ : ការផលិតអគ្គិសនី ៤៩
៥.១.១ : ការផលិតអគ្គិសនីតាមប្រភេទអ្នកកាន់អាជ្ញាប័ណ្ណ ៤៩
៥.១.២ : ការផលិតអគ្គិសនីតាមប្រភេទមធ្យោបាយផលិតកម្ម ៥០
៥.១.៣ : ការផលិតអគ្គិសនីតាមប្រភេទទំហំរោងចក្រអគ្គិសនី ៥១
៥.១.៤ : ថ្លៃលក់អគ្គិសនីរបស់អ្នកផលិតអគ្គិសនីឯករាជ ៥៣
៥.២ : ការនាំចូលអគ្គិសនីពីប្រទេសជិតខាង ៥៤
៥.៣ : ការបញ្ជូនអគ្គិសនី ៥៧
៥.៣.១ : ខ្សែបណ្តាញ និងអនុស្ថានីយអគ្គិសនីតង់ស្យុងខ្ពស់ ៥៧
៥.៣.២ : ការបញ្ជូនអគ្គិសនី ៥៩
៥.៤ : ការចែកចាយអគ្គិសនី ៥៩
៥.៤.១ : មធ្យោបាយចែកចាយអគ្គិសនី ៥៩
៥.៤.២ : បរិមាណថាមពលលក់ និង ចំនួនអ្នកប្រើប្រាស់ ៦០
៥.៤.៣ : បញ្ជីថ្លៃលក់អគ្គិសនី ៦១

| | | | |
|---|---|---|---|
| ឧបសម្ព័ន្ធទី | ១ | : ពត៌មានស្ដីពីតំបន់ផ្គត់ផ្គង់ដោយអ្នកកាន់អាជ្ញាប័ណ្ណរួម និងអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ និងរយៈពេលផ្គត់ផ្គង់ | ៦៤ |
| ឧបសម្ព័ន្ធទី | ២(ក) | : ពត៌មានសង្ខេបស្ដីពីអានុភាពតម្លើង និងថាមពលបញ្ចេញ | ៧៦ |
| ឧបសម្ព័ន្ធទី | ២(ខ) | : ពត៌មានសង្ខេបស្ដីពីមធ្យោបាយផលិតកម្ម និងថាមពលបញ្ចេញ បែងចែកតាមប្រភេទផលិតកម្ម | ៧៧ |
| ឧបសម្ព័ន្ធទី | ២(គ) | : ពត៌មានសង្ខេបស្ដីពីមធ្យោបាយផលិតកម្ម និងថាមពលបញ្ចេញ បែងចែកតាមទំហំរោងចក្រអគ្គិសនី | ៧៨ |
| ឧបសម្ព័ន្ធទី | ៣ | : ពត៌មានសង្ខេបស្ដីពីអ្នកកាន់អាជ្ញាប័ណ្ណផលិតកម្ម | ៧៩ |
| ឧបសម្ព័ន្ធទី | ៤ | : ពត៌មានសង្ខេបស្ដីពីអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ | ៨២ |
| ឧបសម្ព័ន្ធទី | ៥ | : ពត៌មានសង្ខេបស្ដីពីអគ្គិសនីកម្ពុជា កាន់អាជ្ញាប័ណ្ណរួមលេខ ០០១អ | ៨៣ |
| ឧបសម្ព័ន្ធទី | ៦ | : ពត៌មានសង្ខេបស្ដីពីកាន់អាជ្ញាប័ណ្ណរួម | ៨៤ |
| ឧបសម្ព័ន្ធទី | ៧ | : បញ្ជីថ្លៃលក់អគ្គិសនីនៅតាមតំបន់ផ្គត់ផ្គង់អគ្គិសនីដទៃទៀតរបស់អ្នកកាន់អាជ្ញាប័ណ្ណនីមួយៗ | ៩៤ |

# បញ្ជីតារាង


| | | | |
|---|---|---|---|
| | | | ទំព័រ |
| តារាងទី ១ | : | លិខិតបទដ្ឋានសំរាប់គ្រប់គ្រង និងបញ្ញត្តិលើការធ្វើសេវាកម្ម និងការប្រើប្រាស់អគ្គិសនី | ២៣ |
| តារាងទី ២ | : | លិខិតបទដ្ឋានជាមូលដ្ឋានដែលបានរៀបចំរួច និងបានដាក់ឱ្យចូលជាធរមាន សំរាប់គ្រប់គ្រង និងបញ្ញត្តិលើការធ្វើសេវាកម្មនិងការប្រើប្រាស់អគ្គិសនី | ២៤ |
| តារាងទី ៣ | : | អត្រាកំម្រៃអាជ្ញាប័ណ្ណ ដែលអ្នកកាន់អាជ្ញាប័ណ្ណត្រូវបង់ | ២៩ |
| តារាងទី ៤ | : | សង្ខេបប្រភេទ និងចំនួនអាជ្ញាប័ណ្ណដែលបានចេញរហូតដល់ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៤ | ៣៣ |
| តារាងទី ៥ | : | ចំនួននៃប្រភេទអ្នកកាន់អាជ្ញាប័ណ្ណផ្សេងៗដំណើរការក្នុងខេត្ត/ក្រុងនីមួយៗ | ៣៥ |
| តារាងទី ៦ | : | ការវាយតម្លៃស្ថានភាពទូទៅនៃសេវាកម្មអគ្គិសនី | ៣៦ |
| តារាងទី ៧ | : | ពត៌មានស្តីពីការកែលំអមធ្យោបាយផលិតកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណតូចៗ | ៤៤ |
| តារាងទី ៨ | : | ពត៌មានស្តីពីការកែលំអមធ្យោបាយចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណតូចៗ | ៤៦ |
| តារាងទី ៩ | : | ពត៌មានស្តីពីថ្លៃលក់អគ្គិសនីក្នុង១គីឡូវ៉ាត់ម៉ោងរបស់ផលិតករ អគ្គិសនីឯករាជ | ៥៣ |
| តារាងទី ១០ | : | អានុភាព និងថាមពលអគ្គិសនីនាំចូលពីប្រទេសជិតខាង | ៥៥ |
| តារាងទី ១១ | : | ពត៌មានស្តីពីថ្លៃទិញអគ្គិសនីមធ្យមក្នុង១គីឡូវ៉ាត់ពីប្រទេសជិតខាង | ៥៦ |
| តារាងទី ១២ | : | ពត៌មានស្តីពីខ្សែបណ្តាញតង់ស្យុងខ្ពស់ | ៥៧ |
| តារាងទី ១៣ | : | ពត៌មានស្តីពីអនុស្ថានីយតង់ស្យុងខ្ពស់ | ៥៨ |
| តារាងទី ១៤ | : | ការបញ្ជូនអគ្គិសនី | ៥៩ |
| តារាងទី ១៥ | : | ពត៌មានស្តីពីមធ្យោបាយចែកចាយអគ្គិសនី | ៥៩ |
| តារាងទី ១៦ | : | ពត៌មានសង្ខេបស្តីពីការធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនី | ៦០ |
| តារាងទី ១៧ | : | បញ្ជីថ្លៃលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជាសំរាប់រាជធានីភ្នំពេញ និងខេត្តកណ្តាល | ៦១ |
| តារាងទី ១៨ | : | បញ្ជីថ្លៃលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជាសំរាប់ទីរួមខេត្តក្រុង និងទីប្រជុំជននានា | ៦២ |

# ជំពូកទី ១

# ពត៌មានទូទៅ

# ជំពូកទី ១
# ពត៌មានទូទៅ

## ១.១ សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជាគឺជាប្រទេសមួយនៃសមាគមប្រទេសអាស៊ានដែលមានផ្ទៃដី ១៨១,០៣៥ គីឡូម៉ែត្រការ៉េ ឋិតនៅតំបន់ទន្លេមេគង្គផ្នែកខាងក្រោម និងមានព្រំដែនជាប់ជាមួយប្រទេសថៃផ្នែកខាងលិចប្រទេសវៀតណាមផ្នែកខាងកើត និងប្រទេសឡាវផ្នែកខាងជើង ។ ប្រទេសកម្ពុជាមានប្រជាជនប្រហែល ១៣ លាននាក់ ក្នុងនោះ ៨៤% រស់នៅតំបន់ជនបទ ។ ប្រភពថាមពលដែលមានក្នុងស្រុក ហើយកំពុងត្រូវបានប្រជាជនភាគច្រើននៅតំបន់ជនបទកំពុងប្រើប្រាស់គឺ អុស និងធ្យូង ដែលជាប្រភពថាមពលតែ១គត់សំរាប់ការចំអិនអាហារ ។ នៅពុំទាន់មានការសិក្សាជាក់ច្បាស់ណាមួយបង្ហាញអំពីទំហំនៃប្រភពធ្យូងថ្ម ប្រេងកាត និងឧស្ម័ននៅក្នុងប្រទេសកម្ពុជាឡើយ ទោះបីជាបច្ចុប្បន្នមានក្រុមហ៊ុនបរទេសមួយចំនួនកំពុងធ្វើការរុករកប្រេងកាត និងឧស្ម័ន នៅតំបន់សមុទ្ររបស់ប្រទេសកម្ពុជា និងក្រុមហ៊ុនឯកជនក្នុងស្រុកមួយចំនួនកំពុងធ្វើការរុករកធ្យូងថ្ម នៅតំបន់ខ្ពង់រាបខាងជើងប្រទេសក៏ដោយ ។ តាមរបាយការណ៍បណ្តោះអាសន្នក្រៅផ្លូវការបានឱ្យដឹងថា នៅតំបន់សមុទ្ររបស់ប្រទេសកម្ពុជាមានប្រភពប្រេងនិងឧស្ម័ន ហើយនៅតំបន់ខាងជើងប្រទេសមានជំរកធ្យូងថ្ម ដែលអាចជាទីសង្ឃឹមថានឹងក្លាយទៅជាប្រភពថាមពលផ្ទាល់មួយរបស់ប្រទេសកម្ពុជា ។ សក្តានុពលនៃប្រភពវារីអគ្គិសនីរបស់ប្រទេសកម្ពុជាមានកំរិតខ្ពស់ (លើសពី ១០,០០០មេហ្គាវ៉ាត់) ប៉ុន្តែការអភិវឌ្ឍន៍ប្រភពថាមពលនេះពុំទាន់ត្រូវបានអនុវត្តជាក់ស្តែងធំដុំនៅឡើយ ដោយសារខ្វះខាតការសិក្សាសមិទ្ធិលទ្ធភាពរបស់គំរោង និងទុនវិនិយោគ ។ ការនាំចូលថាមពលអគ្គិសនី ដែលមានថ្លៃថោកពីប្រទេសជិតខាង គឺជាជំរើសមួយសំរាប់ដំណាក់កាលបច្ចុប្បន្ន ដើម្បីបំពេញសេចក្តីត្រូវការអគ្គិសនីចំពោះមុខ បន្ថយថ្លៃលក់អគ្គិសនី និង ដើម្បីបង្កើនទំហំទីផ្សារអគ្គិសនីសំរាប់ត្រៀមអភិវឌ្ឍន៍ប្រភពថាមពលអគ្គិសនីដែលមានទំហំធំនៅក្នុងប្រទេស ។




## ១.២ ការវិវត្តន៍របស់វិស័យអគ្គិសនីនៅកម្ពុជាចាប់ពីការកកើតរហូតដល់ឆ្នាំ ១៩៧៩

អគ្គិសនីបានចូលមកព្រះរាជាណាចក្រកម្ពុជាជាដំបូងនៅឆ្នាំ ១៩០៦ ។ រហូតដល់ឆ្នាំ ១៩៥៨ ការផ្គត់ផ្គង់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជាបានត្រូវផ្តល់ដោយក្រុមហ៊ុនឯកជនចំនួន ៣ គឺ :

១- ក្រុមហ៊ុនទឹកនិងអគ្គិសនី (Compagnie des Eaux Electricité) ហៅកាត់ថា CEE

២-សហភាពអគ្គិសនីឥណ្ឌូចិន (Union d' Electricité de l' Indochine) ហៅកាត់ថា UNEDI

៣- ក្រុមហ៊ុនអគ្គិសនីបារាំង-ខ្មែរ (Compagnie Franco-Khmer d'Electricité) ហៅកាត់ថា CFKE ។

ពេលនោះ CEE ជាអ្នកផ្គត់ផ្គង់អគ្គិសនីឱ្យរាជធានីភ្នំពេញនិងតំបន់ជុំវិញ ហើយ UNEDI ជាអ្នកផ្គត់ផ្គង់អគ្គិសនីឱ្យបណ្តាខេត្តដទៃទៀត លើកលែងតែខេត្តបាត់ដំបងដែលត្រូវបានផ្គត់ផ្គង់ដោយ CFKE ។

នៅខែតុលា ឆ្នាំ ១៩៥៨ រាជរដ្ឋាភិបាលកម្ពុជាបានទិញយក CEE និង UNEDI រួចបង្កើតជាក្រុមហ៊ុនរបស់រដ្ឋធំមួយឈ្មោះថា អគ្គិសនីកម្ពុជា (Electricité du Cambodge) ហៅកាត់ថា EDC ។

នៅពេលនោះ អគ្គិសនីកម្ពុជាធ្វើអាជីវកម្មផ្គត់ផ្គង់អគ្គិសនីនៅរាជធានីភ្នំពេញ និងនៅទីរួមខេត្តទាំងអស់របស់ប្រទេសកម្ពុជា លើកលែងតែទីរួមខេត្តបាត់ដំបង និងទីប្រជុំជនដទៃទៀតដែលត្រូវបានធ្វើអាជីវកម្មដោយក្រុមហ៊ុនឯកជននានា ។ នៅឆ្នាំ ១៩៥៨ ផលិតកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជាមានអានុភាពសរុបទាំងអស់ប្រហែល ៣០ មេហ្គាវ៉ាត់ ដែលក្នុងនោះ ១៦ មេហ្គាវ៉ាត់ គឺជាផលិតកម្មរបស់អគ្គិសនីកម្ពុជា និង ១៤ មេហ្គាវ៉ាត់ គឺជាផលិតម្មរបស់ក្រុមហ៊ុនឯកជននានា ។

នៅឆ្នាំ ១៩៧០ អានុភាពផលិតរបស់អគ្គិសនីកម្ពុជាបានកើនឡើងដល់ ៦១,១២៥ គីឡូវ៉ាត់ ដែលស្មើនឹង ៧៧.៥% នៃអានុភាពផលិតដែលមានក្នុងប្រទេសកម្ពុជាទាំងមូល (៧៨,៨០៥ គីឡូវ៉ាត់) ។ ក្នុងឆ្នាំ ១៩៧០ ថាមពលអគ្គិសនីដែលអគ្គិសនីកម្ពុជាផលិតបានគឺមានចំនួន ១២៣,៨២០,០០០ គីឡូវ៉ាត់ម៉ោង នៅរាជធានីភ្នំពេញ និង ១២,២៣០,០០០ គីឡូវ៉ាត់ម៉ោង នៅទីរួមខេត្តនានា ។ នៅពេលនោះ ប្រភេទមធ្យោបាយផលិតកម្មរបស់អគ្គិសនីកម្ពុជា និងសមាមាត្រនៃថាមពលផលិតដោយប្រភេទមធ្យោបាយផលិតកម្មទាំងនេះ មានដូចខាងក្រោម :

| | | |
|---|---|---|
| ១-វារីអគ្គិសនី | ១២.៧ % | (ស្ថានីយវារីអគ្គិសនីគីរីរម្យ១) |
| ២-ចំហាយ | ២៣.០ % | (រោងចក្រអគ្គិសនីចំហាយចាក់អង្រែក្រោម) |
| ៣-ដៀស៊ែល | ៦៤.០ % | |
| ៤-សាំង | ០.៣០ % | |
| សរុប | ១០០% | |

ក្នុងកំឡុងឆ្នាំ ១៩៧០ នៅក្នុងព្រះរាជាណាចក្រកម្ពុជា គឺមានតែខ្សែបណ្តាញបញ្ជូន១ខ្សែគត់ដែលភ្ជាប់ស្ថានីយវារីអគ្គិសនីគីរីរម្យ១មករាជធានីភ្នំពេញ កាត់តាមព្រែកត្នោត ក្រៅពីនោះពុំមានខ្សែបណ្តាញបញ្ជូនណាផ្សេងឡើយ ។ ខ្សែបណ្តាញបញ្ជូនគីរីរម្យ ព្រែកត្នោត ភ្នំពេញ មានកំរិតតង់ស្យុង ១១០ គីឡូវ៉ុល មានប្រវែងប្រហែល ១២០ គីឡូម៉ែត្រ និងមានសមត្ថភាពបញ្ជូនប្រហែល ៥០,០០០ គីឡូវ៉ុលអាំពែរ ។

ក្នុងកំឡុងឆ្នាំ ១៩៧១ ដល់ឆ្នាំ ១៩៧៩ វិស័យអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានឆ្លងកាត់នូវព្រឹត្តិការណ៍ដ៏គ្រោះថ្នាក់២គឺ ១-សង្គ្រាម (១៩៧១-១៩៧៥) និង២-របបប៉ុលពត (១៩៧៥-១៩៧៩) ។ ក្នុងកំឡុងពេលនេះ មធ្យោបាយផ្គត់ផ្គង់អគ្គិសនីទាំងស្ថានីយផលិតអគ្គិសនីនានា ទាំងខ្សែបណ្តាញបញ្ជូន ទាំងប្រព័ន្ធបណ្តាញចែកចាយបានត្រូវបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុង ទាំងនៅរាជធានីភ្នំពេញ ទាំងនៅតាមបណ្តាទីរួមខេត្ត និងទីប្រជុំជននានា ហើយនៅពេលនោះពុំមានពត៌មាន និងទិន្នន័យអ្វីផ្សេងៗបន្សល់ទុកឡើយ ។

## ១.៣ ការវិវត្តន៍របស់វិស័យអគ្គិសនីចាប់ពីឆ្នាំ ១៩៧៩ រហូតដល់បច្ចុប្បន្ន

ក្រោយថ្ងៃរំដោះ ៧ ខែមករា ឆ្នាំ ១៩៧៩ រដ្ឋាភិបាលកម្ពុជាបានចាប់ផ្ដើមរៀបចំស្ដារហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅភ្នំពេញ និងទីរួមខេត្តសំខាន់ៗរបស់ប្រទេសកម្ពុជាឡើងវិញ ។ នៅពេលនោះការផ្គត់ផ្គង់អគ្គិសនីទាំងមូលនៅក្នុងប្រទេសកម្ពុជា បានឋិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងឧស្សាហកម្ម ។ ក្រសួងឧស្សាហកម្មបានបង្កើតអគ្គិសនីកម្ពុជាឡើងវិញឱ្យទទួលបន្ទុកការផ្គត់ផ្គង់អគ្គិសនីនៅភ្នំពេញ និងតំបន់ជុំវិញ និងបង្កើតអង្គភាពអគ្គិសនីតូចៗតាមបណ្ដាខេត្ត ដើម្បីឱ្យទទួលបន្ទុកផ្គត់ផ្គង់អគ្គិសនីនៅតាមបណ្ដាខេត្តទាំងនោះ ។ នៅក្នុងអំឡុងឆ្នាំ ១៩៧៩ រហូតដល់ឆ្នាំ ១៩៩៣ ប្រទេសកម្ពុជាមិនត្រឹមតែឋិតនៅក្នុងស្ថានភាពមួយដែលមានការលំបាកដោយសារមានសង្គ្រាម នៅតាមតំបន់មួយចំនួនប៉ុណ្ណោះទេ តែត្រូវទ្រាំទ្រនឹងការហ៊ុំព័ទ្ធសេដ្ឋកិច្ចពីខាងក្រៅផង ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ដោយសារការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានធ្វើការស្ដារប្រព័ន្ធអគ្គិសនីនៅរាជធានីភ្នំពេញ និងតាមបណ្ដាទីរួមខេត្ត និងទីប្រជុំជនសំខាន់ៗឡើងវិញ ធ្វើឱ្យយ៉ាងហោចណាស់ប្រជាពលរដ្ឋដែលរស់នៅតំបន់ទាំងនោះ មានអគ្គិសនីប្រើប្រាស់ដែរ ។

ក្រោយឆ្នាំ ១៩៩៣ ដោយសារកំរិតកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងសកម្មភាពសេដ្ឋកិច្ចបានរីកចំរើនជាបន្តបន្ទាប់ អត្រាកំណើននៃសេចក្ដីត្រូវការអគ្គិសនីប្រចាំឆ្នាំនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានកើនឡើងជាបន្តបន្ទាប់ ជាពិសេសនៅរាជធានីភ្នំពេញនិងបណ្ដាទីប្រជុំជនសំខាន់ៗនានា ធ្វើឱ្យប្រទេសកម្ពុជាត្រូវការចាំបាច់នូវការអភិវឌ្ឍន៍វិស័យអគ្គិសនីរបស់ខ្លួន ។ ការអភិវឌ្ឍន៍វិស័យអគ្គិសនីត្រូវការនូវទុនវិនិយោគមួយដ៏ធំ ដែលទុនវិនិយោគសាធារណៈ ទាំងថវិការបស់រាជរដ្ឋាភិបាល និងទាំងជំនួយនិងឥណទានផ្សេងៗពុំអាចគ្រាប់គ្រាន់បានឡើយ ។ ពិតមែនតែបន្ទាប់ពីឆ្នាំ ១៩៩៣ រាជរដ្ឋាភិបាលបានទទួលជំនួយ និងឥណទានជាបន្តបន្ទាប់ពីប្រទេសនានា និងពីស្ថាប័នហិរញ្ញវត្ថុផ្សេងៗ ដើម្បីធ្វើការស្ដារ និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានាក្នុងវិស័យអគ្គិសនី ប៉ុន្តែជំហាននៃការស្ដារ និងសាងសង់នេះ ពុំអាចធានាឱ្យបានគ្រប់គ្រាន់នូវសេចក្ដីត្រូវការ ដែលចេះតែកើនខ្ពស់ឡើងឥតឈប់ឈររបស់តំបន់នីមួយៗនៃព្រះរាជាណាចក្រកម្ពុជាឡើយ ។ ឃើញនូវសភាពការណ៍នេះ ចាប់ពីឆ្នាំ ១៩៩៦ រាជរដ្ឋាភិបាលបានបើកចំហរឱ្យផ្នែកឯកជនចូលរួមវិនិយោគ និងធ្វើអាជីវកម្មក្នុងវិស័យផ្គត់ផ្គង់អគ្គិសនី ដើម្បីបំពេញបន្ថែមលើលទ្ធភាពរបស់រដ្ឋ ក្នុងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធវិស័យអគ្គិសនី ។ រាជរដ្ឋាភិបាលបានចាត់ទុកថា វិស័យឯកជនគឺជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ចជាតិ ដូច្នេះគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងវិស័យអគ្គិសនីនៅក្នុងដំណាក់កាលក្រោយនេះ គឺពុំត្រឹមតែបើកចំហរនិងជំរុញឱ្យក្រុមហ៊ុនឯកជនចូលរួមវិនិយោគក្នុងវិស័យនេះប៉ុណ្ណោះទេ តែរាជរដ្ឋាភិបាលក៏បានរៀបចំបង្កើតឱ្យមានបរិយាកាសមួយសមស្រប យុត្តិធម៌ មានផលប្រយោជន៍ទៅវិញទៅមក និងអាចទុកចិត្តបាន សំរាប់ការវិនិយោគ

ឯកជនក្នុងវិស័យអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដើម្បីធានានូវតម្លាភាព យុត្តិធម៌ និងផលប្រយោជន៍ទៅវិញទៅមក ព្រមទាំងធានានូវសុវត្ថិភាពទុនវិនិយោគរបស់អ្នកវិនិយោគក្នុងវិស័យអគ្គិសនី រាជរដ្ឋាភិបាលបានរៀបចំបង្កើតឱ្យមានច្បាប់អគ្គិសនីមួយច្បាស់លាស់ សំរាប់គ្រប់គ្រងការធ្វើធុរកិច្ច ក្នុងវិស័យអគ្គិសនី គ្រប់គ្រងទំនាក់ទំនងរវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់អគ្គិសនីឱ្យបានច្បាស់លាស់ និងមានតម្លាភាព ដែលបានប្រកាសដាក់ឱ្យប្រើប្រាស់នៅខែកុម្ភៈ ឆ្នាំ ២០០១ ។ តាមការកំណត់របស់ច្បាប់អគ្គិសនីនេះ នៅក្នុងឆ្នាំ ២០០១ ដដែល រាជរដ្ឋាភិបាលបានបង្កើតឱ្យមានស្ថាប័នអាជ្ញាធរអគ្គិសនីកម្ពុជាមួយ ដើម្បីឱ្យដើរតួនាទីជាបញ្ញត្តិករ និងជាអាជ្ញាកណ្តាលនៅក្នុងសកម្មភាពធុរកិច្ចក្នុងវិស័យអគ្គិសនី ។ ក្រៅពីនេះ រាជរដ្ឋាភិបាលក៏បានចេញនូវអនុក្រឹត្យ លិខិតបទដ្ឋាននានា ស្របតាមការកំណត់របស់ច្បាប់ដើម្បីធានាឱ្យអភិបាលកិច្ចក្នុងវិស័យអគ្គិសនីប្រព្រឹត្តទៅប្រកបដោយគុណភាព តម្លាភាព និងប្រសិទ្ធភាព ។ នេះគឺជាជំហានដ៏ធំមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកែទម្រង់វិស័យអគ្គិសនី ដើម្បីបង្កើតនូវបរិស្ថានមួយដ៏សមស្របក្នុងការធ្វើអាជីវកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលអ្នកវិនិយោគឯកជនអាចទុកចិត្តបាន និងចូលមកវិនិយោគអភិវឌ្ឍន៍វិស័យនេះ តាមបែបផែនមួយដ៏ត្រឹមត្រូវយុត្តិធម៌ និងមានប្រសិទ្ធភាព ដើម្បីជាផលប្រយោជន៍ទូទៅរបស់សង្គម ។

នៅព្រះរាជាណាចក្រកម្ពុជា វិស័យអគ្គិសនីទើបនឹងត្រូវបានអភិវឌ្ឍន៍ឡើងវិញក្រោយពីសង្គ្រាមជាច្រើនទសវត្ស ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីរបស់យើងនៅជាប្រព័ន្ធទោលដាច់ៗពីគ្នាពុំទាន់មានខ្សែបណ្តាញធំៗភ្ជាប់ចូលគ្នានៅឡើយ ដូច្នេះការអភិវឌ្ឍន៍វិស័យអគ្គិសនីរបស់យើងនៅពេលបច្ចុប្បន្ន ត្រូវបំរើនូវគោលដៅ ២ ក្នុងពេលតែមួយ គឺ ទី១-កសាងមូលដ្ឋានគ្រឹះនៃប្រព័ន្ធអគ្គិសនីរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីឈានទៅធានាឱ្យបាននូវភាពគ្រប់គ្រាន់ ថ្លៃសមរម្យ និងគុណភាពនៃការផ្គត់ផ្គង់អគ្គិសនី ព្រមទាំងធានាបើកផ្លូវឱ្យមានការអភិវឌ្ឍន៍ជាលក្ខណៈយូរអង្វែង និងទី២-ដោះស្រាយឱ្យបានគ្រប់គ្រាន់នូវសេចក្តីត្រូវការអគ្គិសនីក្នុងតំបន់ ដែលកំពុងបិតនៅទោលដាច់ពីគ្នាជាបណ្តោះអាសន្ន ដែលជាធម្មតាការដោះស្រាយបណ្តោះអាសន្នរបៀបនេះ គឺជាដំណោះស្រាយមួយដែលមានថ្លៃអគ្គិសនីខ្ពស់ជាងការដោះស្រាយនៅពេលដែលមានប្រព័ន្ធអគ្គិសនីធំភ្ជាប់គ្នា ។ ដោយសារដំណោះស្រាយសំរាប់សំរេចគោលដៅទាំង២ខាងលើអាចមានឥទ្ធិពលជាឧបសគ្គចំពោះគ្នាទៅវិញទៅមក ដើម្បីឱ្យការអភិវឌ្ឍន៍វិស័យអគ្គិសនីរបស់យើង នៅពេលបច្ចុប្បន្នអាចផ្តល់នូវប្រសិទ្ធភាពសេដ្ឋកិច្ចទៅអនាគត គំរោងអភិវឌ្ឍន៍វិស័យអគ្គិសនីនៅពេលបច្ចុប្បន្នត្រូវតែធ្វើឡើងតាមផែនការយុទ្ធសាស្ត្រមួយ ដែលមានការសិក្សាយ៉ាងម៉ត់ចត់ និងគ្រប់ជ្រុងជ្រោយច្បាស់លាស់ ។

យោងតាមការសិក្សាបច្ចេកទេសសេដ្ឋកិច្ច ការកសាងមូលដ្ឋានគ្រឹះនៃប្រព័ន្ធអគ្គិសនីរបស់ព្រះរាជាណាចក្រកម្ពុជានៅដំណាក់ដំបូង ត្រូវចាប់ផ្តើមក្នុងតំបន់ធំៗដែលមានសក្តានុពលសេដ្ឋកិច្ចនីមួយៗបន្ទាប់

មកទើបពង្រីកប្រព័ន្ធឱ្យកាន់តែធំ និងភ្ជាប់បញ្ចូលគ្នាជាប្រព័ន្ធធំតែ១ទូទាំងប្រទេស ។ តំបន់ធំៗ២ដែលបច្ចុប្បន្នយើងកំពុងតែចាប់ផ្តើមធ្វើការកសាងមូលដ្ឋានគ្រឹះនៃប្រព័ន្ធអគ្គិសនីគឺ (១)-តំបន់ភូមិភាគខាងត្បូងដែលមានរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ តាកែវ កំពត ក្រុងព្រះសីហនុ និង (២)-តំបន់ភូមិភាគខាងលិចដែលមានខេត្តបន្ទាយមានជ័យ បាត់ដំបង និងសៀមរាប ។ ចំពោះតំបន់ទាំង២នេះយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអគ្គិសនីនៅក្នុងតំណាក់កាលដំបូង គឺការសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនីភ្ជាប់ទីប្រជុំជនសំខាន់នៃតំបន់នេះបញ្ចូលគ្នាជាប្រព័ន្ធតែមួយ រួចនាំចូលអគ្គិសនីពីប្រទេសជិតខាងដែលមានថ្លៃថោកជាបណ្តោះអាសន្ន ដើម្បីពង្រីកទីផ្សារអគ្គិសនីឱ្យកាន់តែធំ ទើបចាប់ផ្តើមរកលទ្ធភាពសាងសង់រោងចក្រអគ្គិសនីធំៗដែលមានថ្លៃផលិតថោករបស់ព្រះរាជាណាចក្រកម្ពុជាយើងផ្ទាល់ ។ ជាមួយគ្នានឹងការសាងសង់ខ្សែបណ្តាញតង់ស្យុងខ្ពស់ភ្ជាប់ទីប្រជុំជនសំខាន់នៃតំបន់បញ្ចូលគ្នាជាប្រព័ន្ធតែមួយ រាជរដ្ឋាភិបាលក៏បានពិនិត្យលទ្ធភាពពង្រីកខ្សែបណ្តាញចែកចាយចេញពីទីប្រជុំជនសំខាន់ៗនៃតំបន់នេះ ដើម្បីផ្តល់សេវាអគ្គិសនីឱ្យដល់ប្រជាពលរដ្ឋនៅតំបន់ជនបទនានានៅជុំវិញទីប្រជុំជនទាំងនេះដែរ ។

ចំពោះតំបន់ភូមិភាគខាងត្បូងដែលមានរាជធានីភ្នំពេញ ខេត្តកណ្តាល កំពង់ស្ពឺ តាកែវ កំពត និងក្រុងព្រះសីហនុ បច្ចុប្បន្នយើងបានចុះកិច្ចព្រមព្រៀងទិញអគ្គិសនីពីប្រទេសវៀតណាម និងចុះកិច្ចព្រមព្រៀងខ្ចីឥណទានពីធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីធ្វើការសាងសង់ខ្សែបណ្តាញបញ្ជូនភ្ជាប់ពីភ្នំពេញទៅតាកែវ និងភ្ជាប់ទៅវៀតណាម ព្រមទាំងដើម្បីអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទនៅតំបន់នេះ ។ ឥឡូវនេះ អគ្គិសនីកម្ពុជាកំពុងរៀបចំឯកសារដេញថ្លៃម៉ៅការសំណង់នេះ ហើយសង្ឃឹមថានឹងអាចចាប់ផ្តើមធ្វើការសាងសង់គំរោងនេះនៅឆ្នាំ ២០០៦ ព្រមទាំងអាចនាំចូលអគ្គិសនីពីប្រទេសវៀតណាមមកបន្ថែមឱ្យរាជធានីភ្នំពេញនៅចុងឆ្នាំ ២០០៧ ។ ការនាំចូលអគ្គិសនីពីប្រទេសវៀតណាមគ្រោងថាមានទំហំ ៨០ មេហ្គាវ៉ាត់ នៅក្នុងរយៈពេល ២ឆ្នាំដំបូង និងបង្កើនដល់ ២០០ មេហ្គាវ៉ាត់ចាប់ពីឆ្នាំទី៣ ។ ចំពោះការសាងសង់ខ្សែបណ្តាញបញ្ជូនពីតាកែវទៅកំពត ជំនួយរបស់ KfW ប្រទេសអាល្លឺម៉ង់សំរាប់គំរោងនេះបានសិក្សារួចនិងចុះអនុស្សារណៈយល់ព្រមរួចហើយដែរ ដូច្នេះការសាងសង់ខ្សែបណ្តាញបញ្ជូនតាកែវ-កំពតអាចនឹងចាប់ផ្តើមក្នុងពេលឆាប់ៗនេះដែរ ។ នៅពេលថ្មីៗនេះ គណៈប្រតិភូធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JBIC) របស់ប្រទេសជប៉ុនបានធ្វើការពិភាក្សាជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលអំពីការផ្តល់ហិរញ្ញប្បទានសំរាប់ធ្វើការសាងសង់ខ្សែបណ្តាញបញ្ជូនកំពត-ក្រុងព្រះសីហនុ និងភ្នំពេញ-កំពង់ចាមបន្ថែមទៀត ដូច្នេះតាមស្ថានភាពនេះ នៅប៉ុន្មានឆ្នាំខាងមុខ ភូមិភាគខាងត្បូងនៃប្រទេសកម្ពុជាយើងអាចនឹងមានប្រព័ន្ធអគ្គិសនីភ្ជាប់គ្នាដ៏ធំមួយ ដែលយើងនឹងអាចរៀបចំបើកឱ្យមានការវិនិយោគសាងសង់រោងចក្រអគ្គិសនីធំៗ ដែលមាន

ថ្លៃថោក ដូចជារោងចក្រវារីអគ្គិសនី រោងចក្រអគ្គិសនីប្រើឧស្ម័ន ឬរោងចក្រអគ្គិសនីប្រើធ្យូងថ្ម របស់យើងផ្ទាល់នៅតំបន់នេះ ។

ចំពោះតំបន់ភូមិភាគខាងលិចដែលមានខេត្តបន្ទាយមានជ័យ បាត់ដំបង និងសៀមរាប បច្ចុប្បន្នយើងបានចុះកិច្ចព្រមព្រៀងទិញអគ្គិសនីពីប្រទេសថៃ និងបានចុះកិច្ចព្រមព្រៀងវិនិយោគសាងសង់ខ្សែបណ្តាញបញ្ជូនភ្ជាប់ពីព្រំដែនមក ទីរួមខេត្តទាំង ៣ ជាមួយក្រុមហ៊ុន ASK ដោយកំណត់ល័ក្ខខ័ណ្ឌត្រូវតែចាប់ផ្តើមធ្វើការសាងសង់ក្នុងរយៈពេល ៦ខែ បន្ទាប់ពីចុះកិច្ចព្រមព្រៀង ។ ដូច្នេះយើងសង្ឃឹមថាប្រសិនបើក្រុមហ៊ុន ASK អាចចាប់ផ្តើមធ្វើការសាងសង់ខ្សែបណ្តាញនេះតាមល័ក្ខខ័ណ្ឌកិច្ចព្រមព្រៀង នៅឆ្នាំ ២០០៧ យើងអាចនឹងនាំចូលអគ្គិសនីពីប្រទេសថៃមកផ្គត់ផ្គង់ឱ្យខេត្តបន្ទាយមានជ័យ បាត់ដំបង និងសៀមរាប ។ ដោយឡែកនៅក្នុងគំរោងឥណទានពីធនាគារពិភពលោក យើងក៏មានគំរោងពង្រីកខ្សែបណ្តាញចែកចាយ ចេញពីទីរួមខេត្តបាត់ដំបងដើម្បីផ្គត់ផ្គង់ឱ្យតំបន់ជនបទនានា ដែលនៅជុំវិញទីរួមខេត្តចំនួន ៤០ គីឡូម៉ែត្រ ដែរ ។

# ជំពូកទី ២






# គោលការណ៍ច្បាប់និង
# បទប្បញ្ញត្តិក្នុងការគ្រប់គ្រង
# វិស័យអគ្គិសនីនៅ
# ព្រះរាជាណាចក្រកម្ពុជា















# ជំពូកទី ២
# គោលការណ៍ច្បាប់ និងបទប្បញ្ញត្តិក្នុងការគ្រប់គ្រងវិស័យអគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា

## ២.១ ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

ក្នុងក្របខ័ណ្ឌនៃគោលនយោបាយកែទម្រង់វិស័យអគ្គិសនី ដើម្បីបើកចំហរ និងទាក់ទាញអ្នកវិនិយោគឯកជននានា ឱ្យចូលរួមអភិវឌ្ឍន៍វិស័យអគ្គិសនីរបស់ព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំបង្កើតឱ្យមានច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាឡើង ។ ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាបានត្រូវរដ្ឋសភាអនុម័តជាស្ថាពរកាលពីថ្ងៃទី ៦ ខែវិច្ឆិកា ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គលើកទី ៥ នីតិកាលទី២ ហើយបន្ទាប់មកត្រូវបានព្រឹទ្ធសភាអនុម័តយល់ស្របលើទំរង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ ២០០០ នាសម័យប្រជុំពេញអង្គលើកទី ៤ នីតិកាលទី ១ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញកាលពីថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០០១ ។ ចុងក្រោយច្បាប់នេះបានត្រូវព្រះមហាក្សត្រព្រះបាទសម្តេច **ព្រះនរោត្តមសីហនុ** ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០០១ ។

ខ្លឹមសាររបស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាមានគោលបំណងគ្រប់គ្រង និងរៀបចំក្របខ័ណ្ឌការងារសំរាប់ការផ្គត់ផ្គង់ និងការធ្វើសេវាកម្មអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជាទាំងមូល ។ ច្បាប់នេះ បញ្ញត្តិលើរាល់សកម្មភាពនៃការផ្គត់ផ្គង់ ការផ្តល់សេវា ការប្រើប្រាស់អគ្គិសនី និងលើសកម្មភាពផ្សេងៗទៀត ដែលមានក្នុងវិស័យអគ្គិសនី ។ ច្បាប់នេះបង្កើតនូវគោលការណ៍សំរាប់កិច្ចប្រតិបត្តិការក្នុងវិស័យអគ្គិសនី បង្កើតនូវល័ក្ខខ័ណ្ឌសមស្របក្នុងការវិនិយោគទុន និងកិច្ចប្រតិបត្តិការពាណិជ្ជកម្មក្នុងវិស័យអគ្គិសនី ព្រមទាំងបង្កើតនូវគោលការណ៍សំរាប់ការពារសិទ្ធិអ្នកប្រើប្រាស់ គោលការណ៍បង្កើនកម្មសិទ្ធិឯកជនលើមធ្យោបាយផ្តល់សេវាកម្មអគ្គិសនី និងគោលការណ៍ប្រកួតប្រជែងក្នុងការធ្វើសេវាកម្មអគ្គិសនី ។

ក្នុងការរៀបចំក្របខ័ណ្ឌការងារគ្រប់គ្រងវិស័យអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា ច្បាប់អគ្គិសនីបានបង្កើតស្ថាប័នមួយមានឈ្មោះថា **"អាជ្ញាធរអគ្គិសនីកម្ពុជា"** ហើយកំណត់ឱ្យស្ថាប័ននេះជានីតិបុគ្គលសាធារណៈមួយ ដែលទទួលសិទ្ធិពីរាជរដ្ឋាភិបាល និងមានស្វ័យភាពក្នុងការអនុវត្តន៍ការងាររបស់ខ្លួនតាមការកំណត់របស់ច្បាប់ ។ នៅក្នុងការគ្រប់គ្រងវិស័យអគ្គិសនីរបស់ព្រះរាជាណាចក្រកម្ពុជា ច្បាប់អគ្គិសនីបានកំណត់ថា ការរៀបចំ និងគ្រប់គ្រងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍

របស់រាជរដ្ឋាភិបាលលើវិស័យអគ្គិសនីជាសមត្ថកិច្ចទទួលខុសត្រូវរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ ឯការធានាឱ្យការផ្គត់ផ្គង់សេវាកម្មអគ្គិសនី និងការប្រើប្រាស់អគ្គិសនី ប្រព្រឹត្តិទៅប្រកបដោយប្រសិទ្ធភាព គុណភាព ចីរភាព និងមានតម្លាភាព គឺជាសមត្ថកិច្ចទទួលខុសត្រូវរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។

សិទ្ធិអំណាច និងភារកិច្ចដែលច្បាប់អគ្គិសនីបានផ្តល់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជា ដើម្បីធានាឱ្យការផ្គត់ផ្គង់សេវាកម្មអគ្គិសនី និងការប្រើប្រាស់អគ្គិសនីប្រព្រឹត្តិទៅប្រកបដោយប្រសិទ្ធភាព គុណភាព ចីរភាព គឺសិទ្ធិចេញអាជ្ញាប័ណ្ណឱ្យសេវាករធ្វើសេវាកម្មអគ្គិសនី សិទ្ធិកំណត់ថ្លៃអគ្គិសនីនិងបន្ទុកផ្សេងៗ សិទ្ធិចេញបទប្បញ្ញត្តិ នីតិវិធី វិធាន បទបញ្ជា និងសេចក្តីសំរេចផ្សេងៗ ព្រមទាំងសិទ្ធិដោះស្រាយបណ្តឹងតវ៉ា និងវិវាទពាក់ព័ន្ធនឹងប្រតិបត្តិការផ្គត់ផ្គង់សេវាកម្ម និងការប្រើប្រាស់អគ្គិសនី ។ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវរៀបចំបង្កើតគោលការណ៍ច្បាស់លាស់សំរាប់ការផ្គត់ផ្គង់ និងការកំណត់ថ្លៃលក់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបង្កើតគោលការណ៍នានាសំរាប់បញ្ញត្តិរាល់សកម្មភាពក្នុងវិស័យនេះ តាមរយៈការផ្តល់អាជ្ញាប័ណ្ណឱ្យអ្នកធ្វើសេវាកម្មអគ្គិសនី ។ ជាមួយគ្នាដែរ ច្បាប់អគ្គិសនីអនុញ្ញាតឱ្យមានកម្មសិទ្ធិឯកជនលើមធ្យោបាយធ្វើសេវាកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនឹងបង្កើននូវការប្រកួតប្រជែងក្នុងការផ្គត់ផ្គង់សេវាអគ្គិសនីឱ្យអ្នកប្រើប្រាស់ ។

លើមូលដ្ឋាននៃការកំណត់ក្របខ័ណ្ឌការងារ សិទ្ធិអំណាច និងសមត្ថកិច្ចទទួលខុសត្រូវនេះ អាជ្ញាធរអគ្គិសនីកម្ពុជាគឺជា **បញ្ញត្តិករ** នៃវិស័យអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជាដែលជាអ្នកធ្វើបញ្ញត្តិកម្មលើការធ្វើសេវាកម្មអគ្គិសនី និងការប្រើប្រាស់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ច្បាប់អគ្គិសនីបានកំណត់ថា អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវមានសមាជិក ៣រូប ដែលក្នុងនោះមាន ១រូប ជាប្រធាន ។ សមាជិកអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។ សមាជិកនីមួយៗត្រូវមានអាណត្តិ ៣(បី)ឆ្នាំ ហើយត្រូវបញ្ចប់ក្នុងពេលខុសៗគ្នា លើកលែងតែក្នុងអាណត្តិដំបូង ដែលមានរយៈពេលខុសៗគ្នាដើម្បីឱ្យពេលបញ្ចប់អាណត្តិខុសៗគ្នា ។ សមាជិកអាជ្ញាធរអគ្គិសនីកម្ពុជាមិនអាចត្រូវតែងតាំងឱ្យលើសពី ២អាណត្តិ បានឡើយ ។

យោងតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា **"គ្មានជនណាមួយអាចដំណើរការជាក្រុមហ៊ុនធ្វើសេវាកម្មអគ្គិសនី ឬអាចផ្គត់ផ្គង់សេវាកម្មអគ្គិសនីដោយគ្មានអាជ្ញាប័ណ្ណត្រឹមត្រូវពីអាជ្ញាធរអគ្គិសនីកម្ពុជាបានឡើយ ។ អ្នកដែលកំពុងផ្គត់ផ្គង់សេវាកម្មអគ្គិសនីទាំងអស់ ត្រូវសុំអាជ្ញាប័ណ្ណពីអាជ្ញាធរអគ្គិសនីកម្ពុជា ៦(ប្រាំមួយ)ខែ យ៉ាងយូរ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងពីអាជ្ញាធរអគ្គិសនីកម្ពុជា "** ។

រាល់បទប្បញ្ញត្តិ បទបញ្ជា និងសេចក្តីសំរេចដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជាតាមច្បាប់នេះ ត្រូវមានប្រសិទ្ធភាពអនុវត្តតាមផ្លូវច្បាប់ ។ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវប្តឹងទៅតុលាការនៃព្រះរាជាណាចក្រកម្ពុជាអំពីការរំលោភច្បាប់នេះ និងការរំលោភបំពានលើបទប្បញ្ញត្តិ បទបញ្ជា សេចក្តីសំរេច ព្រមទាំងអាជ្ញាប័ណ្ណដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ។

ច្បាប់ក៏បានកំណត់នូវសិទ្ធិ កាតព្វកិច្ច និងពិន័យ ចំពោះអ្នកផ្គត់ផ្គង់ក៏ដូចជាអ្នកប្រើប្រាស់ដែរ ដើម្បីបង្កើតនូវល័ក្ខខ័ណ្ឌយុត្តិធម៌មួយក្នុងការធ្វើអាជីវកម្ម និងការប្រើប្រាស់អគ្គិសនី ។

ចុងក្រោយ ច្បាប់អគ្គិសនីបានកំណត់ថា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលត្រូវបញ្ចប់ការអនុវត្តនីតួនាទី និងភារកិច្ចដែលត្រូវប្រគល់ជូនទៅអាជ្ញាធរអគ្គិសនីកម្ពុជាដោយច្បាប់នេះ និងត្រូវផ្ទេរជាបណ្តើរៗតាមនីតិវិធីសមស្រប នៅពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានចាប់ផ្តើមដំណើរការ ។ ពេលនោះការងារសំខាន់ទាំង២ ក្នុងការគ្រប់គ្រងវិស័យអគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជាគឺ ១-ការងារធ្វើគោលនយោបាយ ផែនការអភិវឌ្ឍន៍ និងយុទ្ធសាស្រ្តអគ្គិសនី និង២-ការងារបញ្ញត្តិ សំរបសំរួល និងអាជ្ញាកណ្តាលក្នុងការធ្វើសេវាកម្ម និងប្រើប្រាស់អគ្គិសនី នឹងត្រូវបានបំបែកចេញពីគ្នាដូចប្រទេសរីកចំរើនដទៃទៀតដែរ ។ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទទួលបន្ទុកការងាររៀបចំគោលនយោបាយ យុទ្ធសាស្រ្ត និងផែនការថាមពល ឯការងារបញ្ញត្តិ និងសម្របសម្រួលការធ្វើអាជីវកម្ម និងប្រើប្រាស់អគ្គិសនី នឹងត្រូវផ្ទេរទៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។

ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជានេះ គឺជាជំហានដ៏ធំមួយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកែទម្រង់វិស័យអគ្គិសនី ដែលនឹងទាក់ទាញអ្នកវិនិយោគឯកជនឱ្យទុកចិត្ត និងចូលមកវិនិយោគវិស័យនេះតាមបែបផែនមួយដ៏ត្រឹមត្រូវ យុត្តិធម៌ និងមានប្រសិទ្ធភាព ដើម្បីជាផលប្រយោជន៍ទូទៅរបស់សង្គម ។

## ២.២ ការបែងចែកភារកិច្ចរវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអាជ្ញាធរអគ្គិសនីកម្ពុជា

មាត្រា ៣ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់បែងចែកភារកិច្ចទទួលខុសត្រូវរវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងអាជ្ញាធរអគ្គិសនីកម្ពុជាដាច់ពីគ្នា ។ តាមខ្លឹមសារមាត្រានេះ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ផ្តើមដំណើរការ ការគ្រប់គ្រងវិស័យអគ្គិសនីនៅក្នុងប្រទេសកម្ពុជាត្រូវបែងចែកជា២ដាច់ពីគ្នាគឺ ទី១-ការរៀបចំ និងគ្រប់គ្រងគោលនយោបាយ ផែនការយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាលលើវិស័យអគ្គិសនី ជាសមត្ថកិច្ចទទួលខុសត្រូវទូទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងទី២-ការរៀបចំបទប្បញ្ញត្តិ និងល័ក្ខខ័ណ្ឌក្នុងការផ្គត់ផ្គង់សេវាកម្មអគ្គិសនី ការត្រួតពិនិត្យការធ្វើសេវាកម្មអគ្គិសនី និងការគ្រប់គ្រងទំនាក់ទំនងក្នុងការផ្តល់ការទទួល និង

ការប្រើប្រាស់អគ្គិសនី ដើម្បីធានាឱ្យការផ្គត់ផ្គង់សេវាកម្មអគ្គិសនី និងការប្រើប្រាស់អគ្គិសនីប្រព្រឹត្តទៅដោយប្រសិទ្ធភាព គុណភាព ចីរភាព និងមានតម្លាភាពជាសមត្ថកិច្ចទទួលខុសត្រូវរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។

ដូច្នេះមានន័យថា ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល តាមរយៈសមត្ថកិច្ចក្នុងការរៀបចំ និងគ្រប់គ្រងគោលនយោបាយ និងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងវិស័យអគ្គិសនី គឺជាស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាល ទទួលបន្ទុកជាអ្នកគូសវាសផ្លូវដែលវិស័យអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាត្រូវធ្វើដំណើរ និងគឺជាអ្នករៀបចំស្តង់ដាបច្ចេកទេសសំរាប់ឱ្យវិស័យអគ្គិសនីទាំងមូលអនុវត្ត ។

ដោយឡែក អាជ្ញាធរអគ្គិសនីកម្ពុជាគឺជាអ្នករៀបចំគោលការណ៍ បទប្បញ្ញត្តិ នីតិវិធី និងជាអ្នកត្រួតពិនិត្យ តំរែតម្រង់ សម្របសម្រួល ព្រមទាំងជំរុញឱ្យអ្នកប្រតិបត្តិការទាំងឡាយក្នុងវិស័យអគ្គិសនី ទាំងអ្នកផ្គត់ផ្គង់ ទាំងអ្នកប្រើប្រាស់ធ្វើដំណើរតាមផ្លូវ និងស្តង់ដាបច្ចេកទេសដែលក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលគូសវាស ព្រមទាំងធានាឱ្យការផ្គត់ផ្គង់សេវាកម្មអគ្គិសនី និងការប្រើប្រាស់អគ្គិសនីប្រព្រឹត្តទៅដោយប្រសិទ្ធភាព គុណភាព ចីរភាព និងមានតម្លាភាព ។

លើមូលដ្ឋាននៃការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា តួនាទីគ្រប់គ្រងវិស័យអគ្គិសនីនៅព្រះរាជាណាចក្រកម្ពុជាត្រូវបានបែងចែកជា២ ដូចបង្ហាញជូនដូចក្នុងរូបគំនូរខាងក្រោម ៖



## ២.៣ តួនាទីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងវិស័យអគ្គិសនី

មាត្រា ៦ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ថា " អាជ្ញាធរអគ្គិសនីកម្ពុជា គឺជានីតិបុគ្គលនៃនីតិសាធារណៈដែលទទួលនូវសិទ្ធិពីរាជរដ្ឋាភិបាល និងមានស្វ័យភាពក្នុងការត្រួតពិនិត្យលើការធ្វើសេវាកម្មអគ្គិសនី និងគ្រប់គ្រងលើទំនាក់ទំនងរវាងការផ្តល់ ការទទួល និងការប្រើប្រាស់សេវាអគ្គិសនី " ។ មានន័យថា អាជ្ញាធរអគ្គិសនីកម្ពុជាគឺជាស្ថាប័នបំរើកិច្ចការសាធារណៈមួយក្នុងវិស័យអគ្គិសនីដែលរាជរដ្ឋាភិបាលបានប្រគល់សិទ្ធិ និងស្វ័យភាព ឱ្យត្រួតពិនិត្យលើការធ្វើសេវាកម្មអគ្គិសនី និងគ្រប់គ្រងលើទំនាក់ទំនងរវាងការផ្តល់ ការទទួល និងការប្រើប្រាស់សេវាអគ្គិសនី ។

យោងតាមការកំណត់របស់ច្បាប់ខាងលើ រាជរដ្ឋាភិបាលបានផ្តល់នូវសិទ្ធិ និងស្វ័យភាពឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាចំនួន២ចំណុចគឺ ទី១– ត្រួតពិនិត្យលើការធ្វើសេវាកម្មអគ្គិសនី និងទី២– គ្រប់គ្រងលើទំនាក់ទំនងរវាងការផ្តល់ ការទទួល និងការប្រើប្រាស់សេវាអគ្គិសនី ។

### ២.៣.១ ការត្រួតពិនិត្យលើការធ្វើសេវាកម្មអគ្គិសនី

ការធ្វើសេវាកម្មអគ្គិសនីមានន័យថាជាការធ្វើអាជីវកម្មក្នុងការផ្តល់សេវាផ្នែកអគ្គិសនី ។ ចំពោះការធ្វើសេវាកម្មឬការធ្វើអាជីវកម្មអគ្គិសនីផ្ទាល់របស់អ្នកធ្វើសេវាកម្មនីមួយៗ ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់សិទ្ធិ និងស្វ័យភាពឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាត្រួតពិនិត្យសកម្មភាពនៃការធ្វើសេវាកម្មនេះ ដើម្បីធានាថាការធ្វើសេវាកម្ម ឬអាជីវកម្មរបស់អ្នកធ្វើសេវាកម្មអគ្គិសនីនេះពិតជាមានប្រសិទ្ធភាព គុណភាព ចីរភាព និងតម្លាភាព តាមការកំណត់របស់ច្បាប់មែន ។ ការផ្តល់សិទ្ធិ និងស្វ័យភាពឱ្យអាជ្ញាធរត្រឹមតែត្រួតពិនិត្យដូច្នេះ មានន័យថា ច្បាប់មិនចង់ឱ្យអាជ្ញាធរទៅលូកលាន់ ឬចាត់ចែងការងារអាជីវកម្មផ្ទៃក្នុងរបស់អ្នកធ្វើសេវាកម្មអគ្គិសនីឡើយ អាជ្ញាធរអគ្គិសនីកម្ពុជាអាចធ្វើសកម្មភាពណែនាំ ឬបញ្ជាឱ្យកែសំរួល ឬឱ្យបញ្ឈប់សកម្មភាពអ្វីមួយ ក្នុងការធ្វើអាជីវកម្មផ្ទាល់របស់អ្នកធ្វើសេវាកម្មអគ្គិសនីតែនៅពេលណាដែលអាជ្ញាធរបានត្រួតពិនិត្យឃើញថា សកម្មភាពទាំងនោះអាចធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាព គុណភាព ចីរភាព និងតម្លាភាពនៃការធ្វើសេវាកម្មអគ្គិសនី ដែលអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវធានាចំពោះមុខច្បាប់ប៉ុណ្ណោះ ។ សកម្មភាពណែនាំឬបញ្ជាឱ្យកែសំរួល ឬឱ្យបញ្ឈប់សកម្មភាពអ្វីមួយក្នុងការធ្វើអាជីវកម្មផ្ទាល់របស់អ្នកធ្វើសេវាកម្មអគ្គិសនី នៅពេលដែលអាជ្ញាធរត្រួតពិនិត្យឃើញថា សកម្មភាពទាំងនោះអាចធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាព គុណភាព ចីរភាព និងតម្លាភាពនៃការធ្វើសេវាកម្មអគ្គិសនីត្រូវអនុវត្តតាមការកំណត់របស់ច្បាប់ ក្នុងនាមអាជ្ញាធរអគ្គិសនីកម្ពុជាជាតំណាងឱ្យផលប្រយោជន៍សាធារណៈ និងក្នុងនាមអាជ្ញាធរអគ្គិសនីកម្ពុជាជាតំណាងឱ្យអ្នកប្រើប្រាស់អគ្គិសនី ។

## ២.៣.២ ការគ្រប់គ្រងលើទំនាក់ទំនងរវាងការផ្តល់ ការទទួល និងការប្រើប្រាស់សេវាអគ្គិសនី

ទំនាក់ទំនងរវាងការផ្តល់ ការទទួល និងការប្រើប្រាស់សេវាអគ្គិសនី មានន័យថា គឺជាទំនាក់ទំនងរវាងអ្នកផលិតនិងអ្នកបញ្ជូន រវាងអ្នកផលិតនិងអ្នកចែកចាយ រវាងអ្នកបញ្ជូននិងអ្នកចែកចាយ ឬរវាងអ្នកផ្គត់ផ្គង់និងអ្នកប្រើប្រាស់អគ្គិសនី ។ ទំនាក់ទំនងនេះកំណត់ត្រឹមតែក្នុងរង្វង់នៃការផ្តល់ ការទទួល និងការប្រើប្រាស់សេវាអគ្គិសនីប៉ុណ្ណោះ ។ ទំនាក់ទំនងនេះអាចជាល័ក្ខខ័ណ្ឌក្នុងការផ្តល់ និងទទួលសេវាអគ្គិសនីរវាងភាគីខាងលើ អាចជាកាតព្វកិច្ចនិងសិទ្ធិរបស់ភាគីខាងលើ ក្នុងការផ្តល់និងទទួលសេវាអគ្គិសនី អាចជាថ្លៃសេវាអគ្គិសនីដែលភាគីមួយត្រូវលក់ ឬត្រូវទូទាត់ឱ្យភាគីមួយទៀត អាចជាគុណភាពនៃសេវាអគ្គិសនីដែលភាគីមួយត្រូវផ្គត់ផ្គង់ឱ្យទៅភាគីមួយទៀត ។ល។

សេវាអគ្គិសនីមានន័យថា ជាសេវាផ្នែកអគ្គិសនីដែលផ្តល់ដោយភាគីមួយទៅឱ្យភាគីមួយទៀតក្នុងនោះសេវាអគ្គិសនីមិនមែនមានន័យត្រឹមតែ **"អគ្គិសនី"** ដែលផ្តល់ដោយអ្នកផ្គត់ផ្គង់ទៅឱ្យអ្នកប្រើប្រាស់ ឬសេវាផលិត បញ្ជូន ឬ ចែកចាយដែលផ្តល់ដោយសេវាករមួយឱ្យទៅសេវាករមួយទៀតប៉ុណ្ណោះទេ តែក៏អាចជាការងារផ្នែកអគ្គិសនីណាមួយ ដូចជាការតម្លើងបរិក្ខានិងខ្សែបណ្តាញអគ្គិសនី ការថែទាំជួសជុលមធ្យោបាយធ្វើសេវាកម្មអគ្គិសនី ការអនុវត្តន៍ការងារណាមួយក្នុងសេវាអគ្គិសនី ។ល។ ដែលសេវាករអគ្គិសនីមួយផ្តល់ឱ្យទៅសេវាករអគ្គិសនីមួយទៀត ឬដែលសេវាករអគ្គិសនីមួយផ្តល់ឱ្យអ្នកប្រើប្រាស់ ។

ចំពោះទំនាក់ទំនងរវាងការផ្តល់ ការទទួល និងការប្រើប្រាស់សេវាអគ្គិសនីខាងលើ ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាបានផ្តល់សិទ្ធិ និងស្វ័យភាពឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាគ្រប់គ្រងទំនាក់ទំនងនេះ ។

យោងតាមខ្លឹមសារមាត្រា ៧ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាមានភារកិច្ចលំអិត ដូចខាងក្រោម :

ក. ចេញ កែសំរួល ព្យួរ ដកហូតឬបដិសេធអាជ្ញាប័ណ្ណសំរាប់ការផ្គត់ផ្គង់សេវាកម្មអគ្គិសនី
ខ. អនុម័តថ្លៃ និងបន្ទុកចំណាយផ្សេងៗ ព្រមទាំងល័ក្ខខ័ណ្ឌនៃសេវាកម្មអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ លើកលែងតែថ្លៃ និងបន្ទុកចំណាយផ្សេងៗ ព្រមទាំងល័ក្ខខ័ណ្ឌទាំងនោះត្រូវបានបង្កើតឡើងតាមវិធីប្រកួតប្រជែង និងផ្អែកលើទីផ្សារ
គ. ដាក់ឱ្យអនុវត្តបទប្បញ្ញត្តិនីតិវិធី និងស្តង់ដាសំរាប់កម្មវិធីវិនិយោគរបស់អ្នកកាន់អាជ្ញាប័ណ្ណ

ឃ. ពិនិត្យឡើងវិញលើសកម្មភាពហិរញ្ញវត្ថុ និង រចនាសម្ព័ន្ធសហគ្រាសរបស់អ្នកកាន់អាជ្ញាប័ណ្ណ ក្នុងក៏រិតមួយដែលសកម្មភាព និងរចនាសម្ព័ន្ធនោះអាចជាឧបសគ្គដោយផ្ទាល់ដល់កិច្ចប្រតិបត្តិការនៃវិស័យអគ្គិសនី និងប្រសិទ្ធិភាពនៃការផ្គត់ផ្គង់អគ្គិសនី

ង. អនុម័ត និងដាក់ឱ្យអនុវត្តស្តង់ដាប្រតិបត្តិសំរាប់អ្នកកាន់អាជ្ញាប័ណ្ណ

ច. វាយតម្លៃ និងសំរុះសំរួលបណ្តឹងតវ៉ារបស់អ្នកប្រើប្រាស់ និងវិវាទកិច្ចសន្យាដែលពាក់ព័ន្ធនឹងអ្នកកាន់អាជ្ញាប័ណ្ណ ក្នុងករណីដែលការតវ៉ា និងវិវាទនោះទាក់ទិននឹងការរំលោភបំពានលើល័ក្ខខ័ណ្ឌដែលមានកំណត់ក្នុងអាជ្ញាប័ណ្ណ

ឆ. អនុម័ត និងដាក់ឱ្យប្រតិបត្តិនូវប្រព័ន្ធគណនីឯកភាពសំរាប់អ្នកកាន់អាជ្ញាប័ណ្ណទាំងអស់

ជ. រៀបចំ និងផ្សព្វផ្សាយរបាយការណ៍លើវិស័យអគ្គិសនី និងពត៌មានពាក់ព័ន្ធនានាដែលទទួលពីអ្នកកាន់អាជ្ញាប័ណ្ណ សំរាប់ជាផលប្រយោជន៍ដល់រាជរដ្ឋាភិបាល និងផលប្រយោជន៍សាធារណៈ

ឈ. កំណត់កម្រៃនានាដែលត្រូវអនុវត្តលើអ្នកកាន់អាជ្ញាប័ណ្ណ

ញ. កំណត់បែបបទសំរាប់ការផ្តល់ពត៌មានដល់សាធារណជន អំពីកិច្ចការក្នុងសមត្ថកិច្ចរបស់ខ្លួន ដើម្បីធានាឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាអនុវត្តទៅតាមគោលការណ៍តម្លាភាព

ដ. ចេញបញ្ញត្តិ និងបទបញ្ជាសមស្រប ព្រមទាំងបញ្ជាផ្អាកជាបណ្តោះអាសន្ន និងជាស្ថាពរចំពោះសេវាកម្មអគ្គិសនី

ឋ. ពិន័យជាប្រាក់ ផ្អាកការប្រើប្រាស់អគ្គិសនី ព្យួរឬដកហូតអាជ្ញាប័ណ្ណចំពោះការរំលោភលើច្បាប់អគ្គិសនី និងលិខិតបទដ្ឋាននានា ព្រមទាំងបញ្ញត្តិផ្សេងៗទៀតរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

ឌ. តម្រូវឱ្យអ្នកធ្វើសេវាកម្ម និងអ្នកប្រើប្រាស់អគ្គិសនីគោរពប្រតិបត្តិនូវរាល់វិធានដែលទាក់ទងនឹងសន្តិសុខថាមពល សេដ្ឋកិច្ច បរិស្ថានរបស់ប្រទេសជាតិ ព្រមទាំងគោលនយោបាយដទៃទៀតរបស់រាជរដ្ឋាភិបាល

ឍ. ចាត់វិធានការផ្សេងទៀតចំពោះបញ្ហាបន្ទាប់បន្សំ ឬដែលជាផលវិបាកស្តែងចេញពីមុខងារ ដូចបានរៀបរាប់ខាងលើនេះ និង

ណ. បង្កើតល័ក្ខខ័ណ្ឌជ្រើសរើស និងប្រើប្រាស់មន្ត្រី ឬបុគ្គលិកអាជ្ញាធរអគ្គិសនីកម្ពុជា ព្រមទាំងជំនាញការ ឬទីប្រឹក្សា ។

## ២.៣.២ លិខិតបទដ្ឋានសំរាប់គ្រប់គ្រង និងបញ្ញត្តិលើការធ្វើសេវាកម្មនិងការប្រើប្រាស់អគ្គិសនី

លិខិតបទដ្ឋានជាមូលដ្ឋានសំរាប់គ្រប់គ្រង និងបញ្ញត្តិលើការធ្វើសេវាកម្មនិងការប្រើប្រាស់អគ្គិសនី

នៅក្នុងព្រះរាជាណាចក្រកម្ពុជាមានតាមលំដាប់ថ្នាក់ ដូចបង្ហាញជូនក្នុងតារាងទី ១ ខាងក្រោម ។

**តារាងទី ១ : លិខិតបទដ្ឋានសំរាប់គ្រប់គ្រង និងបញ្ញត្តិលើការធ្វើសេវាកម្ម និងការប្រើប្រាស់អគ្គិសនី**

| | |
|---|---|
| **១. ច្បាប់** | ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ដទៃទៀតដែលពាក់ព័ន្ធដល់ការគ្រប់គ្រង និងបញ្ញត្តិវិស័យអគ្គិសនី ។ ច្បាប់គឺជាឯកសារគោលក្នុងការបញ្ញត្តិលើរាល់សកម្មភាពទាំងអស់ក្នុងវិស័យអគ្គិសនី និងក៏ជាមូលដ្ឋានគោលក្នុងការរៀបចំលិខិតបទដ្ឋានដទៃទៀតសំរាប់គ្រប់គ្រង និងបញ្ញត្តិវិស័យអគ្គិសនីដែរ ។ |
| **២. លិខិតបទដ្ឋានថ្នាក់រដ្ឋាភិបាល** | អនុក្រឹត្យ សេចក្តីសំរេច សេចក្តីជូនដំណឹង ។ល។ របស់រាជរដ្ឋាភិបាល ។ លិខិតបទដ្ឋានទាំងនេះគឺជាឯកសារសំរាប់កំណត់គោលនយោបាយវិស័យអគ្គិសនី និងសំរាប់បញ្ញត្តិលើសកម្មភាពក្នុងវិស័យអគ្គិសនីទាំងឡាយណា ដែលច្បាប់អគ្គិសនីបានកំណត់ថា ត្រូវកំណត់ដោយលិខិតបទដ្ឋានរបស់រាជរដ្ឋាភិបាល ។ គោលការណ៍គន្លឹះសំខាន់ៗ នៃវិស័យអគ្គិសនីដែលពុំទាន់មានកំណត់នៅក្នុងច្បាប់ក៏អាចដាក់ឱ្យប្រើប្រាស់ដោយលិខិតបទដ្ឋានរបស់រាជរដ្ឋាភិបាលដែរ ។ |
| **៣. លិខិតបទដ្ឋានថ្នាក់ក្រសួង** | ប្រកាស និងសេចក្តីសំរេចរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។ លិខិតបទដ្ឋានទាំងនេះគឺជាឯកសារសំរាប់គ្រប់គ្រងការងារទាំងឡាយ ដែលចេញដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដូចជាគោលនយោបាយ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រ ស្តង់ដាបច្ចេកទេសអគ្គិសនី និងការកំណត់ផ្សេងៗទៀតក្នុងវិស័យអគ្គិសនី ដូចជា :<br>-ការវិនិយោគលើការស្តារ និងការអភិវឌ្ឍន៍វិស័យអគ្គិសនីសំរាប់រយៈពេលខ្លី មធ្យម និងវែង<br>-ការរៀបចំឡើងវិញការចូលរួមរបស់ផ្នែកឯកជន និងឯកជនភាវូបនីយកម្មរបស់សហគ្រាសសាធារណៈ<br>-ការលើកទឹកចិត្តចំពោះការប្រើប្រាស់ធនធានថាមពល ដែលមានស្រាប់ក្នុងស្រុកសំរាប់ការផលិតអគ្គិសនី<br>-ការរៀបចំផែនការ និងកិច្ចព្រមព្រៀងលើការនាំចេញនាំចូលថាមពលអគ្គិសនី<br>-ការឧបត្ថម្ភក្រុមអ្នកជាវជាកំណត់ណាមួយ និងការផ្តល់អាទិភាពដល់អ្នកប្រើប្រាស់អគ្គិសនី |

| | |
|---|---|
| | -ការបង្កើនប្រសិទ្ធភាពក្នុងការផលិត បញ្ជូន ចែកចាយអគ្គិសនី និងការប្រើប្រាស់អគ្គិសនី ព្រមទាំងសកម្មភាពដើម្បីបង្កើតកម្មវិធីសន្សំសំចៃអគ្គិសនីសំរាប់កម្ពុជា និង<br>-កាលៈទេសៈដែលមានភ័យន្តរាយផ្នែកអគ្គិសនី និងយុទ្ធសាស្រ្ត ដើម្បីធានាសន្តិសុខផ្នែកថាមពល |
| **៤. លិខិតបទដ្ឋានរបស់អាជ្ញាធរអគ្គិសនីកម្ពុជា** | អាជ្ញាប័ណ្ណ បទប្បញ្ញត្តិ នីតិវិធី និងសេចក្តីសំរេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ដែលអាជ្ញាធរអគ្គិសនីកម្ពុជា មានកាតព្វកិច្ចត្រូវចេញក្នុងក្របខ័ណ្ឌរបស់ច្បាប់អគ្គិសនី ។ លិខិតបទដ្ឋានទាំងនេះគឺជាឯកសារសំរាប់គ្រប់គ្រង និងបញ្ញត្តិលើការធ្វើសេវាកម្ម និងប្រើប្រាស់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ |

រហូតដល់ចុងឆ្នាំ ២០០៤ លិខិតបទដ្ឋានជាមូលដ្ឋានធានា ដែលបានរៀបចំរួច និងបានដាក់ឱ្យចូលជាធរមានសំរាប់គ្រប់គ្រង និងបញ្ញត្តិលើការធ្វើសេវាកម្មនិងការប្រើប្រាស់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានបង្ហាញជូនក្នុងតារាងទី ២ ខាងក្រោម ។

**តារាងទី ២ : លិខិតបទដ្ឋានជាមូលដ្ឋាន ដែលបានរៀបចំរួច និងបានដាក់ឱ្យចូលជាធរមានសំរាប់គ្រប់គ្រង និងបញ្ញត្តិលើការធ្វើសេវាកម្ម និងការប្រើប្រាស់អគ្គិសនី**

| ល.រ | ឈ្មោះលិខិតបទដ្ឋាន | ដាក់ឱ្យប្រើប្រាស់ដោយ | កាលបរិច្ឆេទដាក់ឱ្យប្រើប្រាស់ |
|---|---|---|---|
| ១ | ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា | ព្រះមហាក្សត្រ | ថ្ងៃទី ២ ខែកុម្ភៈ ឆ្នាំ ២០០១ |
| ២ | អនុក្រឹត្យស្តីពីការកំណត់កម្រិតអតិបរមានៃកម្រៃអាជ្ញាប័ណ្ណសម្រាប់អនុវត្តចំពោះអ្នកធ្វើសេវាកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា | រាជរដ្ឋាភិបាល | ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០០១ |
| ៣ | នីតិវិធីសំរាប់ការចេញ កែសំរួល ព្យួរ ដកហូត ឬបដិសេធអាជ្ញាប័ណ្ណធ្វើសេវាកម្មអគ្គិសនី | អាជ្ញាធរអគ្គិសនីកម្ពុជា | ថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០០១ |
| | កែសំរួលលើកទី១ | | ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ២០០២ |
| | កែសំរួលលើកទី២ | | ថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០០៤ |

| | | | |
|---|---|---|---|
| ៤ | បទប្បញ្ញត្តិស្តីពីល័ក្ខខ័ណ្ឌទូទៅក្នុងការផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា | អាជ្ញាធរអគ្គិសនីកម្ពុជា | ថ្ងៃទី ១៧ ខែមករា ឆ្នាំ ២០០៣ |
| | កែសំរួលលើកទី១ | | ថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០០៤ |
| ៥ | វិធីបញ្ញត្តិលើការពង្រីកប្រព័ន្ធបញ្ជូន និងប្រព័ន្ធចែកចាយអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា | អាជ្ញាធរអគ្គិសនីកម្ពុជា | ថ្ងៃទី ២៨ ខែតុលា ឆ្នាំ ២០០៣ |
| ៦ | បទប្បញ្ញត្តិស្តីពីស្តង់ដាប្រតិបត្តិទូទៅសំរាប់អ្នកផ្គត់ផ្គង់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា | អាជ្ញាធរអគ្គិសនីកម្ពុជា | ថ្ងៃទី ២ ខែមេសា ឆ្នាំ ២០០៤ |
| ៧ | នីតិវិធីនៃការដាក់ពាក្យបណ្តឹងមកអាជ្ញាធរអគ្គិសនីកម្ពុជា និងការដោះស្រាយបណ្តឹងដោយអាជ្ញាធរអគ្គិសនីកម្ពុជា | អាជ្ញាធរអគ្គិសនីកម្ពុជា | ថ្ងៃទី ២ ខែមេសា ឆ្នាំ ២០០៤ |
| ៨ | ល័ក្ខខ័ណ្ឌទូទៅនៃស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០០៤ |
| ៩ | ព្រះរាជក្រឹត្យស្តីពីមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃព្រះរាជាណាចក្រកម្ពុជា | រាជរដ្ឋាភិបាល | ថ្ងៃទី ៤ ខែធ្នូ ឆ្នាំ ២០០៤ |

**កំណត់សំគាល់ :**

នៅឆ្នាំ ២០០៤ អាជ្ញាធរអគ្គិសនីកម្ពុជាបានសហការជាមួយទីប្រឹក្សាសេដ្ឋកិច្ច NERA មកពីប្រទេសអង់គ្លេសក្នុងក្របខ័ណ្ឌនៃជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីសិក្សា និងរៀបចំឯកសារសំខាន់ ៣ សំរាប់បញ្ញត្តិនិងកំណត់បញ្ជីថ្លៃលក់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ឯកសារទាំង ៣ នេះ មាន :

១. អនុក្រឹត្យស្តីពីគោលការណ៍អាជីវកម្មសំរាប់កំណត់បញ្ជីថ្លៃលក់អគ្គិសនី
២. បទប្បញ្ញត្តិស្តីពីការកំណត់បញ្ជីថ្លៃលក់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា
៣. នីតិវិធីសំរាប់ការតាមដានទិន្នន័យ ការស្នើសុំ និងការកំណត់បញ្ជីថ្លៃលក់អគ្គិសនី

ឯកសារទាំងនេះ គ្រោងនឹងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅ ២០០៥ ។

ខ្លឹមសារលំអិតនៃលិខិតបទដ្ឋាននានាដែលមាននៅក្នុងតារាងខាងលើ អ្នកមានបំណងយល់ដឹងអាចរកបាន និងអានបាននៅក្នុងគេហទំព័ររបស់អាជ្ញាធរអគ្គិសនីកម្ពុជា www.eac.gov.kh ។

# ជំពូកទី ៣




## ពត៌មានស្តីពីអាជ្ញាធរអគ្គិសនីកម្ពុជា ~ បញ្ញត្តិករក្នុងវិស័យអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី ៣
# ពត៌មានស្តីពីអាជ្ញាធរអគ្គិសនីកម្ពុជា — បញ្ញត្តិករក្នុងវិស័យអគ្គិសនី នៅក្នុងព្រះរាជាណាចក្រកម្ពុជា

## ៣.១ បញ្ញត្តិករក្នុងវិស័យអគ្គិសនី

អនុលោមតាមខ្លឹមសារច្បាប់អគ្គិសនី បញ្ញត្តិករក្នុងវិស័យអគ្គិសនីត្រូវមាន៣រូប ដែលជាសមាជិកអាជ្ញាធរអគ្គិសនីកម្ពុជា ។ សមាជិកអាជ្ញាធរអគ្គិសនីកម្ពុជាត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ។ នៅឆ្នាំ ២០០៤ បញ្ញត្តិករក្នុងវិស័យអគ្គិសនី ដែលត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ដើម្បីទទួលបន្ទុកការបញ្ញត្តិវិស័យអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានដូចខាងក្រោម :

១- **ឯកឧត្តមបណ្ឌិត ទី នរិទ្ធ** ជាប្រធាន

២- **ឯកឧត្តម យ៉ាវ ប៊ុនម៉េង** ជាអនុប្រធានទី១

៣- **ឯកឧត្តមបណ្ឌិត អ៊ុច ថៅងសេង** ជាអនុប្រធានទី២

នៅចុងឆ្នាំ ២០០៤ **ឯកឧត្តមបណ្ឌិត អ៊ុច ថៅងសេង** អនុប្រធានទី២នៃអាជ្ញាធរអគ្គិសនីកម្ពុជា ត្រូវបានផ្ទេរតួនាទីនៅបំពេញភារកិច្ចនៅសាលាក្រុងភ្នំពេញ ។ ក្នុងពេលជាមួយគ្នានេះ **ឯកឧត្តម សំអឿន គីមហឿន** ត្រូវបានតែងតាំងជាអនុប្រធានទី២នៃអាជ្ញាធរអគ្គិសនីកម្ពុជាជំនួស **ឯកឧត្តមបណ្ឌិត អ៊ុច ថៅងសេង** ។

## ៣.២ រចនាសម្ព័ន្ធរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

តាមការកំណត់របស់ច្បាប់អគ្គិសនី អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវមានសមាជិកចំនួន ៣រូប និងត្រូវមានលេខាធិការដ្ឋានមួយសំរាប់ធ្វើជាសេនាធិការ ។ លេខាធិការដ្ឋាននេះ មាននាយកប្រតិបត្តិ ១រូប ជាអ្នកគ្រប់គ្រង ។ នាយកប្រតិបត្តិត្រូវបានតែងតាំងដោយប្រធានអាជ្ញាធរអគ្គិសនីកម្ពុជាបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកឯទៀត ។ លេខាធិការដ្ឋានរបស់អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវមាននាយកដ្ឋានជំនាញដែលធ្វើការងារជំនាញឱ្យអាជ្ញាធរអគ្គិសនីកម្ពុជា ។

បច្ចុប្បន្ន អាជ្ញាធរអគ្គិសនីកម្ពុជាបានរៀបចំរចនាសម្ព័ន្ធរបស់ខ្លួនតាមគំនូសបំព្រួញមួយ ដូចខាង

ក្រោម ។ ថ្នាក់ដឹកនាំខ្ពស់បំផុតរបស់អាជ្ញាធរអគ្គិសនីកម្ពុជា គឺបញ្ញត្តិករទាំង ៣រូប ដែលក្នុងនោះមាន ១រូប ជាប្រធាននៃអាជ្ញាធរអគ្គិសនីកម្ពុជា និង ២រូប ទៀត ជាអនុប្រធាននៃអាជ្ញាធរអគ្គិសនីកម្ពុជា ។ នៅក្រោមប្រធាន និងអនុប្រធានអាជ្ញាធរមានលេខាធិការដ្ឋានមួយ ដែលគ្រប់គ្រងដោយនាយកប្រតិបត្តិ ១រូប ។ លេខាធិការដ្ឋានគឺជាសេនាធិការមួយដែលអាជ្ញាធរបង្កើតឡើង ដើម្បីបំរើកិច្ចការរដ្ឋបាល និងជំនាញបច្ចេកទេសរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ហើយមាននាយកដ្ឋានជំនាញក្រោមចំណុះ ។ លេខាធិការដ្ឋាននេះមាននាយកដ្ឋានចំនួន ៤ សំរាប់ធ្វើការងារជំនាញ ៤ ដោយឡែកពីគ្នាឱ្យអាជ្ញាធរគឺ ១-នាយកដ្ឋានរដ្ឋបាលនិងបុគ្គលិក ដែលទទួលបន្ទុកការងាររដ្ឋបាលនិងបុគ្គលិក ២-នាយកដ្ឋានបញ្ញត្តិកម្មអគ្គិសនី ដែលទទួលបន្ទុកការងារបច្ចេកទេសអគ្គិសនី ៣-នាយកដ្ឋានហិរញ្ញវត្ថុនិងតម្លៃ ដែលទទួលបន្ទុកការងារហិរញ្ញវត្ថុ គណនេយ្យ និងការវិភាគថ្លៃអគ្គិសនី និង ៤-នាយកដ្ឋាននីតិកម្ម ដែលទទួលបន្ទុកការងារច្បាប់ និងការងារដោះស្រាយវិវាទ និងពិន័យ ។

**រចនាសម្ព័ន្ធរបស់អាជ្ញាធរអគ្គិសនីកម្ពុជា**




## ៣.៣ ថវិការបស់អាជ្ញាធរអគ្គិសនីកម្ពុជា និងកម្រៃអាជ្ញាប័ណ្ណ

អាជ្ញាធរអគ្គិសនីកម្ពុជាគឺជាស្ថាប័នមានស្វ័យភាពមួយ ដែលធ្វើការងារសំរាប់ជាផលប្រយោជន៍ឱ្យអ្នកធ្វើសេវាកម្ម និងអ្នកប្រើប្រាស់អគ្គិសនីទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដូច្នេះការចំណាយរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការបំពេញការងារនេះ គឺត្រូវទទួលបន្ទុកដោយអ្នកធ្វើសេវាកម្មអគ្គិសនីទាំងអស់ ក្នុងរូបភាពជាការបង់កម្រៃអាជ្ញាប័ណ្ណ ។ មាត្រា ២៧ របស់ច្បាប់អគ្គិសនីបានកំណត់ថាអាជ្ញាធរអគ្គិសនីកម្ពុជាមានថវិកាស្វ័យយ័តមួយសំរាប់កិច្ចប្រតិបត្តិការរបស់ខ្លួន ។ ថវិកានេះគឺកម្រៃដែល

អ្នកសុំអាជ្ញាប័ណ្ណ និងអ្នកកាន់អាជ្ញាប័ណ្ណត្រូវបង់តាមការកំណត់របស់អាជ្ញាធរអគ្គិសនីកម្ពុជា ។ កម្រៃនេះហៅថា "**កម្រៃអាជ្ញាប័ណ្ណ** " ។ ដើម្បីគ្រប់គ្រងការយកកម្រៃអាជ្ញាប័ណ្ណរបស់អាជ្ញាធរអគ្គិសនីកម្ពុជានេះ ច្បាប់អគ្គិសនីបានកំណត់បន្ថែមថា "កំរិតអតិបរមានៃកម្រៃអាជ្ញាប័ណ្ណត្រូវកំណត់ដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល" ។ មានន័យថា ការយកកម្រៃអាជ្ញាប័ណ្ណរបស់អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវឋិតនៅក្នុងព្រំដែនកំណត់មួយច្បាស់លាស់ ដែលព្រំដែននេះត្រូវសំរេចដោយអនុក្រឹត្យរបស់រាជរដ្ឋាភិបាល ។

តាមការកំណត់របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យមួយលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០០១ កំណត់កំរិតអតិបរិមានៃកម្រៃអាជ្ញាប័ណ្ណសំរាប់អនុវត្តចំពោះអ្នកធ្វើសេវាកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

យោងតាមការកំណត់របស់ច្បាប់ និងតាមកំរិតអតិបរិមានៃកម្រៃអាជ្ញាប័ណ្ណ ដែលកំណត់ដោយអនុក្រឹត្យ អាជ្ញាធរអគ្គិសនីកម្ពុជាត្រូវកំណត់អត្រាកម្រៃអាជ្ញាប័ណ្ណ ដែលអ្នកកាន់អាជ្ញាប័ណ្ណត្រូវបង់ជារៀងរាល់ឆ្នាំ ។ សំរាប់ឆ្នាំ ២០០៤ អាជ្ញាធរអគ្គិសនីកម្ពុជាបានកំណត់កម្រៃអាជ្ញាប័ណ្ណ ដែលអ្នកកាន់អាជ្ញាប័ណ្ណត្រូវបង់តាមសេចក្តីជូនដំណឹងលេខ ០១៧-សរ-០៤-អអក ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ ២០០៤ របស់អាជ្ញាធរអគ្គិសនីកម្ពុជាដែលមានអត្រា ដូចមានបង្ហាញជូនក្នុងតារាងទី ៣ ខាងក្រោម :

**តារាងទី ៣ : អត្រាកម្រៃអាជ្ញាប័ណ្ណ ដែលអ្នកកាន់អាជ្ញាប័ណ្ណត្រូវបង់**

| **ប្រភេទ** | **រៀល/គីឡូវ៉ាត់ម៉ោង** | |
|---|---|---|
| | **ឆ្នាំ ២០០៣** | **ឆ្នាំ ២០០៤** |
| ការផលិតអគ្គិសនីឬការទិញអគ្គិសនីពីក្រៅប្រទេស | ១.៦០ | ១.៦០ |
| ការបញ្ជូនអគ្គិសនី | ០.៦០ | ០.៦០ |
| ការចែកចាយ និងលក់អគ្គិសនី | ១.១០ | ១.១០ |
| ការធ្វើសេវាកម្មលក់រាយ | ០.៥០ | ០.៥០ |
| ការធ្វើសេវាកម្មអគ្គិសនីផ្សេងៗទៀត | ០.១% | ០.១% |

# ជំពូកទី ៤

# ពត៌មានស្តីពីអាជ្ញាប័ណ្ណ និង អ្នកកាន់អាជ្ញាប័ណ្ណអគ្គិសនីនៅ ក្នុងព្រះរាជាណាចក្រកម្ពុជា

# ជំពូកទី ៤
# ពត៌មានស្តីពីអាជ្ញាប័ណ្ណ និងអ្នកកាន់អាជ្ញាប័ណ្ណអគ្គិសនី
# នៅក្នុងព្រះរាជាណាចក្រកម្ពុជា

## ៤.១ អាជ្ញាប័ណ្ណសំរាប់ធ្វើសេវាកម្មអគ្គិសនី

តាមខ្លឹមសាររបស់ច្បាប់អគ្គិសនី អ្នកផ្គត់ផ្គង់សេវាកម្មអគ្គិសនីនីមួយៗ ត្រូវមានអាជ្ញាប័ណ្ណដែលចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ហើយត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ និងរាល់បញ្ញត្តិដែលកំណត់ក្នុងអាជ្ញាប័ណ្ណរបស់ខ្លួន ព្រមទាំងបទប្បញ្ញត្តិ និងនីតិវិធីផ្សេងទៀតរបស់អាជ្ញាធរអគ្គិសនីកម្ពុជា ។ **អាជ្ញាប័ណ្ណ** តាមច្បាប់អគ្គិសនីគឺលិខិតផ្តល់សិទ្ធិឱ្យធ្វើសេវាកម្មអគ្គិសនី ដូច្នេះអាជ្ញាប័ណ្ណសំរាប់ធ្វើសេវាកម្មអគ្គិសនី **គឺជាលិខិតអនុញ្ញាតតាមផ្លូវច្បាប់មួយ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាសំរេចផ្តល់ឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយដើម្បីមានសិទ្ធិធ្វើសេវាកម្មអគ្គិសនី នៅតាមបញ្ញត្តិដែលកំណត់ក្នុងអាជ្ញាប័ណ្ណនោះ** (ហៅថា **ល័ក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណ**) ។ តាមនិយមន័យខាងលើ នៅក្នុងអាជ្ញាប័ណ្ណនីមួយៗត្រូវមានខ្លឹមសារសំខាន់ ២ គឺ :

ក. សេចក្តីសំរេចផ្តល់សិទ្ធិឱ្យធ្វើសេវាកម្មអគ្គិសនី និង
ខ. ល័ក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណសំរាប់ធ្វើសេវាកម្មអគ្គិសនី

ប្រភេទអាជ្ញាប័ណ្ណដែលត្រូវចេញ និងគ្រប់គ្រងដោយអាជ្ញាធរអគ្គិសនីកម្ពុជាមាន :

១. **អាជ្ញាប័ណ្ណផលិតកម្ម** ដែលផ្តល់សិទ្ធិឱ្យធ្វើសេវាកម្មផលិតអគ្គិសនី ដោយមធ្យោបាយផលិតកម្មកំណត់មួយ ។

២. **អាជ្ញាប័ណ្ណបញ្ជូន** ដែលផ្តល់សិទ្ធិឱ្យធ្វើសេវាកម្មបញ្ជូនអគ្គិសនី ។ អាជ្ញាប័ណ្ណបញ្ជូនមាន ២ប្រភេទ គឺអាជ្ញាប័ណ្ណបញ្ជូនសំរាប់បណ្តាញជាតិបញ្ជូនអគ្គិសនី និងអាជ្ញាប័ណ្ណបញ្ជូនសំរាប់គោលបំណងពិសេស :

- **អាជ្ញាប័ណ្ណបញ្ជូនសំរាប់បណ្តាញជាតិបញ្ជូនអគ្គិសនី**
ដែលផ្តល់ឱ្យអ្នកធ្វើសេវាកម្មបញ្ជូនអគ្គិសនី តែមួយគត់ដែលរដ្ឋគ្រប់គ្រងឱ្យមានសិទ្ធិផ្តាច់មុខសំរាប់ធ្វើការបញ្ជូនអគ្គិសនីដល់ក្រុមហ៊ុនចែកចាយអគ្គិសនី និងដល់អ្នកប្រើប្រាស់ធំៗនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

- **អាជ្ញាប័ណ្ណបញ្ជូនសំរាប់គោលបំណងពិសេស**

  គឺជាអាជ្ញាប័ណ្ណមួយសំរាប់សាងសង់ធ្វើជាម្ចាស់ និង ប្រតិបត្តិការលើមធ្យោបាយបញ្ជូនអគ្គិសនីកំណត់ច្បាស់លាស់មួយ ហើយដែលមានគោលដៅជាក់លាក់នៅក្នុង ព្រះរាជាណាចក្រកម្ពុជា ។

៣. **អាជ្ញាប័ណ្ណចែកចាយ** ដែលផ្តល់សិទ្ធិឱ្យធ្វើសេវាកម្មចែកចាយអគ្គិសនីក្នុងតំបន់ជាកំណត់មួយដែលមានផ្ទៃដីជាប់គ្នា ។

៤. **អាជ្ញាប័ណ្ណរួម** ជាប្រភេទអាជ្ញាប័ណ្ណមួយដែលរួមបញ្ចូលអាជ្ញាប័ណ្ណមួយចំនួនឬទាំងអស់ ។ អាជ្ញាប័ណ្ណ រួមអាចចេញឱ្យអគ្គិសនីកម្ពុជា និង ប្រព័ន្ធទោល ដើម្បីផ្តល់សិទ្ធិឱ្យផលិត បញ្ជូន បែងចែក ចែកចាយ និងលក់អគ្គិសនីឱ្យអ្នកប្រើប្រាស់ ។

៥. **អាជ្ញាប័ណ្ណបែងចែក** ដែលផ្តល់សិទ្ធិឱ្យគ្រប់គ្រង ត្រួតត្រា និងធ្វើប្រតិបត្តិការលើមធ្យោបាយបែងចែកអគ្គិសនី ដើម្បីសំរបសំរួលការប្រគល់ និងការទទួលអគ្គិសនីនៃប្រព័ន្ធផលិតកម្ម ប្រព័ន្ធបញ្ជូន និង ប្រព័ន្ធចែកចាយ ។

៦. **អាជ្ញាប័ណ្ណលក់ដុំ** ដែលផ្តល់សិទ្ធិឱ្យចូលរួមទិញអគ្គិសនីពីអ្នកកាន់អាជ្ញាប័ណ្ណផលិតកម្ម ឬពី ប្រព័ន្ធអគ្គិសនីនៃប្រទេសជិតខាងណាមួយ ដើម្បីលក់ឱ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ ឬអ្នក ប្រើប្រាស់ធំៗនៅក្នុងប្រព័ន្ធអគ្គិសនីជាប់គ្នាមួយ ។

៧. **អាជ្ញាប័ណ្ណលក់រាយ** ដែលផ្តល់សិទ្ធិឱ្យចូលរួមក្នុងការលក់អគ្គិសនីឱ្យអ្នកប្រើប្រាស់លើតំបន់សេវាកម្មជាប់គ្នាមួយ ។

៨. **អាជ្ញាប័ណ្ណសេវាកម្មបន្ត**

ដែលផ្តល់សិទ្ធិឱ្យធ្វើសេវាកម្មអគ្គិសនីផ្នែកណាមួយរបស់អ្នកកាន់អាជ្ញាប័ណ្ណ ស្របតាមកិច្ចសន្យាបន្តជាមួយអ្នកដែលមានអាជ្ញាប័ណ្ណស្រាប់ ។

## ៤.២ អាជ្ញាប័ណ្ណដែលបានចេញ និង តំបន់ផ្គត់ផ្គង់

រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៤ អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាប័ណ្ណចំនួន ១០៧ ដើម្បីផ្តល់សិទ្ធិឱ្យសេវាករអគ្គិសនីមានសិទ្ធិធ្វើសេវាកម្មអគ្គិសនីស្របតាមច្បាប់ ។ ប្រភេទអាជ្ញាប័ណ្ណ និង ចំនួនអាជ្ញាប័ណ្ណដែលបានចេញរហូតដល់ចុងឆ្នាំ ២០០៤ មានបង្ហាញក្នុងតារាងទី ៤ ខាងក្រោម ។

## តារាងទី ៤ : ប្រភេទ និងចំនួនអាជ្ញាប័ណ្ណដែលបានចេញរហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០០៤

| ល.រ | ប្រភេទអាជ្ញាប័ណ្ណដែលបានចេញ | ចំនួនអាជ្ញាប័ណ្ណដែលបានចេញ | | ចំនួនអាជ្ញាប័ណ្ណ | |
|---|---|---|---|---|---|
| | | ឆ្នាំ ២០០៣ | ឆ្នាំ ២០០៤ | អស់សុពលភាព | មានសុពលភាព |
| ១ | អាជ្ញាប័ណ្ណរួម រួមមាន អាជ្ញាប័ណ្ណផលិតកម្ម អាជ្ញាប័ណ្ណចែកចាយ និងអាជ្ញាប័ណ្ណបញ្ជូន | ១ | | | ១ |
| ២ | អាជ្ញាប័ណ្ណផលិតកម្ម | ៨ | ៣ | ៣ | ៨ |
| ៣ | អាជ្ញាប័ណ្ណចែកចាយ | ៧ | ១ | | ៨ |
| ៤ | អាជ្ញាប័ណ្ណរួម រួមមាន អាជ្ញាប័ណ្ណផលិតកម្ម និង អាជ្ញាប័ណ្ណចែកចាយ | ៦៩ | ១៨ | | ៨៧ |
| **សរុប** | | **៨៥** | **២២** | **៣** | **១០៤** |

អាជ្ញាប័ណ្ណផលិតកម្មលេខ ០១០L ដែលបានចេញឱ្យ **ក្រុមហ៊ុនខេមបូឌា វ៉ានឡុង អ៊ិនធើណេសិនណល អ៊ិនដាសស្ទ្រៀល** អស់សុពលភាពបន្ទាប់ពីថ្ងៃ ៣០ ខែមិថុនា ឆ្នាំ ២០០៣, អាជ្ញាប័ណ្ណផលិតកម្មលេខ ០២៥L ដែលបានចេញឱ្យ **ក្រុមហ៊ុនវិនិយោគកម្ពុជាសន្តិភាព** អស់សុពលភាពបន្ទាប់ពីថ្ងៃ ១៥ ខែសីហា ឆ្នាំ ២០០៤ និងអាជ្ញាប័ណ្ណផលិតកម្មលេខ ០០៥L ដែលបានចេញឱ្យ **លោក ជា សុផា** អស់សុពលភាពបន្ទាប់ពីថ្ងៃ ៣០ ខែកញ្ញា ឆ្នាំ ២០០៤ តាមអាណត្តិនៃកិច្ចព្រមព្រៀងទិញអគ្គិសនី ។

អគ្គិសនីកម្ពុជាគឺជាក្រុមហ៊ុនអគ្គិសនីរបស់រដ្ឋដែលទទួលបានអាជ្ញាប័ណ្ណរួម ក្នុងនោះមានអាជ្ញាប័ណ្ណផលិតកម្ម អាជ្ញាប័ណ្ណចែកចាយ និងអាជ្ញាប័ណ្ណបញ្ជូន ។ អាជ្ញាប័ណ្ណបានផ្តល់សិទ្ធិឱ្យអគ្គិសនីកម្ពុជាផ្តល់សេវាកម្មបញ្ជូនទូទាំងព្រះរាជាណាចក្រកម្ពុជា ផ្តល់សេវាកម្មចែកចាយនៅក្នុងតំបន់អនុញ្ញាតក្នុងអាជ្ញាប័ណ្ណរបស់ខ្លួន និងដំណើរការមធ្យោបាយផលិតអគ្គិសនីនៅតាមទីតាំងផ្សេងៗដែលបានកំណត់ក្នុងអាជ្ញាប័ណ្ណ ។

អ្នកកាន់អាជ្ញាប័ណ្ណផលិតកម្ម ផលិតអគ្គិសនី និងលក់ឱ្យអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ ឬ អ្នកកាន់អាជ្ញាប័ណ្ណរួម ។ អ្នកកាន់អាជ្ញាប័ណ្ណចែកចាយទិញអគ្គិសនីពីប្រទេសជិតខាង ឬទិញអគ្គិសនីពីអ្នក

កាន់អាជ្ញាប័ណ្ណដទៃទៀត (អ្នកកាន់អាជ្ញាប័ណ្ណផលិតកម្ម អ្នកកាន់អាជ្ញាប័ណ្ណចែកចាយ អ្នកកាន់អាជ្ញាប័ណ្ណរួម) និងធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីឱ្យអ្នកប្រើប្រាស់ក្នុងតំបន់ផ្គត់ផ្គង់របស់ខ្លួន ។ អ្នកកាន់អាជ្ញាប័ណ្ណរួម លើកលែងតែអគ្គិសនីកម្ពុជា ផលិតអគ្គិសនីដើម្បីធ្វើការផ្គត់ផ្គង់អគ្គិសនីទៅតាមតម្រូវការរបស់ខ្លួនផ្ទាល់ ។ អគ្គិសនីកម្ពុជាផលិតអគ្គិសនីដោយខ្លួនឯង ទិញអគ្គិសនីពីអ្នកកាន់អាជ្ញាប័ណ្ណផលិតកម្ម និងទិញពីប្រទេសជិតខាង ដើម្បីបំពេញទៅតាមតម្រូវការអគ្គិសនីរបស់ខ្លួន ។

អ្នកកាន់អាជ្ញាប័ណ្ណចែកចាយ និងអ្នកកាន់អាជ្ញាប័ណ្ណរួមទាំងអស់ផ្តល់សេវាកម្មអគ្គិសនីឱ្យតំបន់ភូមិសាស្ត្រដែលមានផ្ទៃដីជាប់គ្នា លើកលែងតែក្រុមហ៊ុនហ្វ្រាណាស៊ី អាហរ័ណ នីហរ័ណ, ក្រុមហ៊ុនឱធីហ្វ្រីសបលីមីធីត និងអគ្គិសនីកម្ពុជា ។ ប៉ុន្តែទោះបីយ៉ាងណាក្តី តំបន់ផ្គត់ផ្គង់ដែលមានផ្ទៃដីជាប់គ្នាខ្លះ អាចបំបែងឆ្លងកាត់លើសពីខេត្តមួយ ។ ក្រុមហ៊ុនហ្វ្រាណាស៊ី អាហរ័ណ នីហរ័ណផ្គត់ផ្គង់អគ្គិសនីក្នុងទីប្រជុំស្រុកកំរៀង ភ្នំព្រឹក និងសំពៅលូន ក្នុងខេត្តបាត់ដំបង ចំណែកឯក្រុមហ៊ុនឱធីហ្វ្រីសបលីមីធីតផ្គត់ផ្គង់អគ្គិសនីឱ្យតំបន់២គឺទីរួមខេត្តកោះកុង និងទីប្រជុំជនអូរស្មាច់ក្នុងខេត្តឧត្តរមានជ័យ ។ រហូតដល់ចុងឆ្នាំ ២០០៤ នេះ អគ្គិសនីកម្ពុជាបានផ្គត់ផ្គង់អគ្គិសនីក្នុងតំបន់អនុញ្ញាតក្នុងអាជ្ញាប័ណ្ណរបស់ខ្លួននៅរាជធានីភ្នំពេញ ក្រុងព្រះសីហនុ ទីរួមខេត្តសៀមរាប ទីរួមខេត្តបាត់ដំបង ទីរួមខេត្តតាកែវ ទីរួមខេត្តកំពង់ចាម ទីរួមខេត្តកំពត ទីរួមខេត្តព្រៃវែង ទីរួមខេត្តរតនគិរី ស្រុកពញាក្រែក ស្រុកមេមត់ ឃុំបាវិត និងទីរួមស្រុកកំពង់ត្រាច ហើយគ្រោងនឹងធ្វើសេវាកម្មផ្គត់ផ្គង់អគ្គិសនីនៅទីរួមខេត្តបន្ទាយមានជ័យ ទីរួមខេត្តស្ទឹងត្រែង ទីរួមខេត្តស្វាយរៀង និងទីរួមខេត្តកំពង់ស្ពឺ នៅឆ្នាំ ២០០៥ ។

តំបន់ដែលអ្នកកាន់អាជ្ញាប័ណ្ណទាំងអស់ធ្វើការផ្គត់ផ្គង់ រួមមានគ្រប់ដណ្តប់លើទីក្រុង ទីរួមខេត្តនានា ទីប្រជុំជនដទៃទៀត និងតាមភូមិតូចៗនានា ។ ការផ្គត់ផ្គង់អគ្គិសនីតាមទីក្រុងនានា និងតំបន់ទីប្រជុំជនសំខាន់ៗដែលការផ្គត់ផ្គង់អគ្គិសនីធ្វើឡើងតាមរយៈនៃការនាំចូលពីប្រទេសជិតខាងគឺ ២៤ម៉ោងក្នុង ១ថ្ងៃ ។ ប៉ុន្តែតម្រូវការបន្ទុកនៅតាមតំបន់ជនបទភាគច្រើន នៅម៉ោងខ្លះបន្ទុកប្រើប្រាស់អគ្គិសនីទាបខ្លាំង ដូច្នេះហើយការផ្គត់ផ្គង់អគ្គិសនីធ្វើឡើងពុំគ្រប់ ២៤ម៉ោងក្នុង១ថ្ងៃឡើយ ។

ឧបសម្ព័ន្ធទី១ ផ្តល់នូវពត៌មានស្តីពីតំបន់ផ្គត់ផ្គង់ដោយអ្នកកាន់អាជ្ញាប័ណ្ណរួម និងអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ និងរយៈពេលផ្គត់ផ្គង់ក្នុងតំបន់នោះបែងចែកតាមខេត្ត ។ ចំនួននៃប្រភេទអ្នកកាន់អាជ្ញាប័ណ្ណផ្សេងៗដំណើរការក្នុងខេត្ត/ក្រុងនីមួយៗ រហូតដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០០៤ មានបង្ហាញជូនក្នុងតារាងទី ៥ ខាងក្រោម ។

## តារាងទី ៥ : ចំនួននៃប្រភេទអ្នកកាន់អាជ្ញាប័ណ្ណផ្សេងៗដំណើរការក្នុងខេត្ត/ក្រុងនីមួយៗ

| ល.រ | ឈ្មោះខេត្ត /ក្រុង | អាជ្ញាប័ណ្ណរួម ដែលមានអាជ្ញាប័ណ្ណផលិតកម្ម អាជ្ញាប័ណ្ណបញ្ជូន និង អាជ្ញាប័ណ្ណចែកចាយ | អាជ្ញាប័ណ្ណផលិតកម្ម | អាជ្ញាប័ណ្ណចែកចាយ | អាជ្ញាប័ណ្ណរួមដែលមានអាជ្ញាប័ណ្ណ ផលិតកម្ម និង អាជ្ញាប័ណ្ណចែកចាយ | សរុប |
|---|---|---|---|---|---|---|
| ១ | បន្ទាយមានជ័យ | | | ១ | ៧ | ៨ |
| ២ | បាត់ដំបង | ១ | ១ | ១ | ៥ | ៨ |
| ៣ | កំពង់ចាម | ១ | ១ | | ១៣ | ១៥ |
| ៤ | កំពង់ឆ្នាំង | | ១ | ១ | ៤ | ៦ |
| ៥ | កំពង់ស្ពឺ | | | | ៨ | ៨ |
| ៦ | កំពង់ធំ | | | | ៧ | ៧ |
| ៧ | កំពត | ១ | | | ៤ | ៥ |
| ៨ | កណ្ដាល | ១ | | ១ | ១៤ | ១៦ |
| ៩ | កោះកុង | | ១ | ១ | ២ | ៤ |
| ១០ | ក្រចេះ | | | | ១ | ១ |
| ១១ | ក្រុងកែប | | | | | |
| ១២ | មណ្ឌលគិរី | | | | | |
| ១៣ | ឧត្ដរមានជ័យ | | | ១ | ១ | ២ |
| ១៤ | ប៉ៃលិន | | | ២ | | ២ |
| ១៥ | រាជធានីភ្នំពេញ | ១ | ២ | | ២ | ៥ |
| ១៦ | ព្រះវិហារ | | | | ១ | ១ |
| ១៧ | ព្រៃវែង | ១ | ១ | | ៥ | ៧ |
| ១៨ | ពោធិសាត់ | | ១ | ១ | ៤ | ៦ |
| ១៩ | រតនគិរី | ១ | | | | ១ |
| ២០ | សៀមរាប | ១ | | | ៣ | ៤ |
| ២១ | ក្រុងព្រះសីហនុ | ១ | | | ៣ | ៤ |
| ២២ | ស្ទឹងត្រែង | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ២៣ | ស្វាយរៀង | ១ | | | | ១ |
| ២៤ | តាកែវ | ១ | ១ | | ១០ | ១២ |

## ៤.៣ ស្ថានភាពទូទៅនៃការធ្វើសេវាកម្មអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ

តាមរយៈការចុះពិនិត្យតាមបណ្តាមូលដ្ឋានធ្វើសេវាកម្មអគ្គិសនីនានា អាជ្ញាធរអគ្គិសនីកម្ពុជាបាន ពិនិត្យឃើញថា លើកលែងតែអគ្គិសនីកម្ពុជា, ផលិតករអគ្គិសនីឯករាជ និងអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ ធំៗមួយចំនួន សេវាករភាគច្រើនមានលក្ខណៈអន់ថយ ដូចខាងក្រោម ៖

១-មធ្យោបាយធ្វើសេវាកម្មអគ្គិសនីមានលក្ខណៈហួសសម័យ លែងនិយមប្រើ ឬចាស់ទ្រុឌទ្រោម មិនត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស គ្មានសុវត្ថិភាពក្នុងការដំណើរការនិងក្នុងការប្រើប្រាស់ ។ លក្ខណៈអន់ថយនេះ បានធ្វើឱ្យប្រសិទ្ធភាពនៃការធ្វើអាជីវកម្មរបស់ពួកគាត់ធ្លាក់ចុះយ៉ាងខ្លាំង ។

២-អ្នកកាន់អាជ្ញាប័ណ្ណ និងបុគ្គលិកបំរើការរបស់គាត់ ពុំមានចំណេះដឹងគ្រប់គ្រាន់ទាក់ទងនឹងការដំណើរការ និងការថែទាំមធ្យោបាយផលិតកម្មនិងមធ្យោបាយចែកចាយឱ្យមានសុវត្ថិភាព និងប្រសិទ្ធភាពក្នុងការដំណើរការធ្វើសេវាកម្មអគ្គិសនី ។

៣-អ្នកកាន់អាជ្ញាប័ណ្ណ និងបុគ្គលិកបំរើការរបស់គាត់ ពុំមានចំណេះដឹងគ្រប់គ្រាន់ក្នុងការគ្រប់គ្រងអាជីវកម្ម ការងាហិរញ្ញវត្ថុ គណនេយ្យ គ្រប់គ្រងធនធានមនុស្ស និងសេវាទំនាក់ទំនងជាមួយអតិថិជន ។ល។

ការវាយតម្លៃស្ថានភាពទូទៅនៃសេវាកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានបង្ហាញជូននៅក្នុងតារាងទី ៦ ខាងក្រោម ៖

**តារាងទី ៦ ៖ ការវាយតម្លៃស្ថានភាពទូទៅនៃសេវាកម្មអគ្គិសនី**

| ប្រភេទសេវាកម្ម | ប្រសិទ្ធភាពផលិតកម្ម អត្រាប្រើប្រាស់ប្រេង, *l/kWh* | ប្រសិទ្ធភាព ខ្សែបណ្តាញ | ការគ្រប់គ្រង |
|---|---|---|---|
| អាជ្ញាប័ណ្ណរួមរបស់អគ្គិសនីកម្ពុជា | ពី ០.២៧ ដល់ ០.៣១ | បាត់បង់ជាមធ្យម ១៣% គុណភាពថាមពលល្អ | មធ្យម, នៅមានចំណុចកែលំអច្រើន |

| | | | |
|---|---|---|---|
| អាជ្ញាប័ណ្ណផលិតកម្ម | ០.២៧ | គុណភាពថាមពលល្អ | មធ្យម |
| អាជ្ញាប័ណ្ណចែកចាយ | - | បាត់បង់ជាមធ្យម ១២% គុណភាពថាមពលមធ្យម | ខ្វះបទពិសោធន៍ក្នុងការធ្វើអាជីវកម្មអគ្គិសនី |
| អាជ្ញាប័ណ្ណរួមធុនធំ | ០.៣២ | បាត់បង់ជាមធ្យមក្រោម ១៧% គុណភាពថាមពលមធ្យម | មធ្យម |
| អាជ្ញាប័ណ្ណរួមធុនតូច | ពី ០.២៩ ដល់ ០.៥០ | បាត់បង់ជាមធ្យម ៣៣% គុណភាពថាមពលទាប | អន់, ត្រូវការការបណ្តុះបណ្តាល |

### ៤.៣.១ ស្ថានភាពនៃការធ្វើសេវាកម្មអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណរួម

ជាទូទៅ ស្ថានភាពនៃការធ្វើសេវាកម្មអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណតូចៗខ្សោយ — ប្រសិទ្ធភាពផលិតកម្ម និងប្រសិទ្ធភាពខ្សែបណ្តាញចែកចាយទាប ពុំសូវមានសុវត្ថិភាព ការគ្រប់គ្រងពុំសូវល្អ គុណភាពសេវាកម្មក្រោមមធ្យម និងសម្បូរវិវាទនាឡិកាស្ទង់ ។ សេវាករភាគច្រើនពុំមានតម្លើងនាឡិកាស្ទង់សំរាប់កត់ត្រាបរិមាណថាមពលផលិត ហើយកន្លែងខ្លះមានតម្លើងដែរ តែខ្វះភាពជាក់លាក់ ។ ការរៀបចំតម្លើងទ្វារចរន្តពុំបានល្អ ហើយម៉ាស៊ីនភ្លើងពុំអាចដំណើរការស្របគ្នាបាន ។ ឧបករណ៍ការពារពុំត្រឹមត្រូវតាមស្តង់ដា គ្មានសុវត្ថិភាព និងទាមទារនូវការប្រុងប្រយ័ត្នខ្លាំង ក្នុងពេលដំណើរការបិទបើកចរន្ត ។ ការរៀបចំ ឬការបំបែកទ្វារចរន្តពុំទាន់បានល្អ ដោយត្រូវកាត់ផ្តាច់ការផ្គត់ផ្គង់ទាំងស្រុងនៅពេលមានកំហូចចរន្តកើតឡើងនៅផ្នែកណាមួយនៃប្រព័ន្ធ ។

ម៉ាស៊ីនភ្លើងពុំត្រូវតាមសំណុំ ភាគច្រើនជាប្រភេទម៉ាស៊ីនផ្គុំ ធ្វើឱ្យប្រសិទ្ធភាពនៃការដំណើរការទាប ។ ឧបករណ៍ត្រួតពិនិត្យតង់ស្យុង និងបន្ទុកពុំអាចលៃតម្រូវ/ដំណើរការបានត្រឹមត្រូវ ។ សេវាករមួយចំនួនបានធ្វើការកែលំអប្រព័ន្ធរបស់ខ្លួនជាបណ្តើរៗហើយ ។

ខ្សែបណ្តាញចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណរួមភាគច្រើនបានសាងសង់ឡើងដោយមានលក្ខណៈបណ្តោះអាសន្ន ។ ខ្សែបណ្តាញចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណដែលបានទទួលអាណត្តិអាជ្ញាប័ណ្ណតិចជាង ៤ឆ្នាំ មានលក្ខណៈដូចខាងក្រោម :

- បង្គោលភ្លើងពុំមានភាពរឹងមាំគ្រប់គ្រាន់ និងមានកំពស់ទាបជាង ៥ ម៉ែត្រ
- ខ្សែចំលងភាគច្រើនជាខ្សែស្រោត ដែលត្រូវប្តូរជាខ្សែស្រោមវិញ
- មុខកាត់ខ្សែចំលងភាគច្រើនពុំគ្រប់គ្រាន់សំរាប់ធានាតង់ស្យុងចុងខ្សែឱ្យគ្រប់ ២០៧ វ៉ុល

- ប្រព័ន្ធដំណើរការពុំមានសុវត្ថិភាពនៅពេលភ្លៀង
- ខ្សែដីពុំបានផ្ទៀងផ្ទាត់ត្រឹមត្រូវ
- ពុំមានឧបករណ៍ការពារស្វ័យប្រវត្តិត្រឹមត្រូវ ដើម្បីកាត់ផ្តាច់ចរន្តនៅពេលមានកំហូច ។

## ៤.៤ ផែនការរបស់អាជ្ញាធរអគ្គិសនីកម្ពុជាសំរាប់ស្តារកំរិតកំពស់ការងារធ្វើសេវាកម្មអគ្គិសនី

ឃើញនូវស្ថានភាពដូចបានបញ្ជាក់ខាងលើនេះ ដើម្បីការពារនូវផលប្រយោជន៍របស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍វិស័យអគ្គិសនី និងដើម្បីធានាថា ប្រជាជនទទួលបាននូវផលប្រយោជន៍ពីកាប្រើប្រាស់អគ្គិសនី ព្រមទាំងដើម្បីជួយសេវាករអគ្គិសនីឱ្យអាចធ្វើសេវាកម្មអគ្គិសនីមួយ ប្រកបដោយប្រសិទ្ធភាពសុវត្ថិភាព និងចីរភាព អាជ្ញាធរអគ្គិសនីបានកំណត់ផែនការសកម្មភាពមួយ ដើម្បីជំរុញឱ្យសេវាករអគ្គិសនីធ្វើការកែលំអស្ថានភាពសេវាកម្មទាំង៣ខាងលើ ។ ក្នុងផែនការនេះមានកម្មវិធី ៣ ដូចខាងក្រោម :

### ៤.៤.១ កម្មវិធីជួយណែនាំ បង្ហាត់បង្ហាញ និងបណ្តុះបណ្តាល

ក្នុងកម្មវិធីនេះ អាជ្ញាធរអគ្គិសនីកម្ពុជាមានការងារ ៣ ដែលកំពុងអនុវត្តជាក់ស្តែងបច្ចុប្បន្ន ។ ការងារទី១ គឺចុះពិនិត្យ និងសិក្សាផ្ទាល់ដល់មូលដ្ឋានធ្វើសេវាកម្មរបស់សេវាករ ហើយធ្វើការណែនាំ និង បង្ហាត់បង្ហាញជាក់ស្តែងដោយផ្ទាល់ ដល់មូលដ្ឋានធ្វើសេវាកម្មអគ្គិសនីអំពីវិធីសាស្ត្រនៃការកែលំអមធ្យោបាយធ្វើសេវាកម្ម ការដំណើរការ និងការកត់ត្រានិងថែទាំទិន្នន័យសំខាន់ៗចាំបាច់ ។ កាណែនាំនេះ គឺផ្តោតលើស្ថានភាពជាក់ស្តែងនៃមធ្យោបាយធ្វើសេវាកម្មអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណនីមួយៗ ។ ការងារទី២ គឺការធ្វើសិក្ខាសាលា ការផ្សព្វផ្សាយនិងផ្លាស់ប្តូរយោបល់អំពីការកែលំអមធ្យោបាយធ្វើសេវាកម្មអគ្គិសនី និងការដំណើរការ និងការងារទី៣ គឺផ្តល់នូវការបណ្តុះបណ្តាលឱ្យសេវាករ ។

ការឡើងថ្លៃប្រេងឥន្ទនៈចាប់តាំងពីដើមឆ្នាំរហូតដល់ចុងឆ្នាំ ២០០៤ នេះ បានប៉ះពាល់ដល់ថ្លៃដើមផលិតអគ្គិសនីយ៉ាងខ្លាំង ហើយការប៉ះពាល់នេះបានជះឥទ្ធិពលកាន់តែខ្លាំងដល់អ្នកផ្គត់ផ្គង់អគ្គិសនីធុនតូច ព្រោះថា ទី១-អ្នកផ្គត់ផ្គង់អគ្គិសនីទាំងនោះប្រើប្រាស់តែប្រេងឥន្ទនៈម៉ាស៊ូតទាំងស្រុងដើម្បីផលិតអគ្គិសនី ទី២-ហេដ្ឋារចនាសម្ព័ន្ធផលិតកម្ម និងចែកចាយពុំមានប្រសិទ្ធភាព ដែលធ្វើឱ្យថ្លៃលក់អគ្គិសនីឡើងខ្ពស់ ។ ដើម្បីទប់ទល់នឹងឥទ្ធិពលអាក្រក់នៃការឡើងថ្លៃប្រេងឥន្ទនៈនេះ អាជ្ញាធរអគ្គិសនីកម្ពុជាបានដាក់កម្មវិធីជម្រុញ និងណែនាំសេវាករ ឱ្យប្រើប្រាស់ប្រេងខ្មៅដែលជាប្រភពប្រេងឥន្ទនៈដែលមានតម្លៃថោកសំរាប់ផលិតថាមពលអគ្គិសនី និងខិតខំធ្វើការកែលំអហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីរបស់ខ្លួន ឱ្យកាន់តែមានប្រសិទ្ធភាពជាងមុន ដើម្បីឈានទៅកាត់បន្ថយថ្លៃដើមអគ្គិសនី នៅតាមតំបន់ណាដែលអាចអនុវត្តទៅបាន ។ ការណែនាំនេះ មានដូចជា :

កម្មវិធីទី១ : ប្តូរពីកាប្រើប្រេងម៉ាស៊ូត (DO) មកប្រើប្រេងខ្មៅ (HFO) ។ ឧទាហរណ៍ក្នុងនោះរួមមាន (១)-ក្រុមហ៊ុនណារ៉េតអភិវឌ្ឍន៍អគ្គិសនីលីមីធីត បានបញ្ចប់កិច្ចព្រមព្រៀងទិញអគ្គិសនីជាមួយក្រុមហ៊ុន ហ្សាបភីធ័រ ផៅវ័រ (ខេមបូឌា) លីមីធីត តាមអាណត្តិ ហើយបានចុះកិច្ចព្រមព្រៀងទិញអគ្គិសនីថ្មីជាមួយក្រុមហ៊ុន អ៊ែតវើត អេនើជី ស៊ីបផ្លាយ ដែលប្រើប្រាស់ប្រេងខ្មៅសំរាប់ផលិតថាមពលអគ្គិសនី ដែលមានថ្លៃផលិតថោកជាងមុន ។

កម្មវិធីទី២ : រៀបចំកម្មវិធីផលិត ដើម្បីប្រើម៉ាស៊ីនភ្លើងឱ្យបានលើសពី ៥០% នៃអានុភាពតម្លើងរបស់វា ។ កម្មវិធីនេះមានការពិបាកក្នុងការអនុវត្តន៍ ព្រោះថាសេវាករតូចៗពុំសូវយល់ដឹងពីការរៀបចំកម្មវិធីផលិតឱ្យបានសមស្របតាមបន្ទុកអគ្គិសនី ។

កម្មវិធីទី៣ : កែលំអប្រព័ន្ធចែកចាយអគ្គិសនីឱ្យស្របតាមស្តង់ដាបច្ចេកទេស ដើម្បីឱ្យមានប្រសិទ្ធភាពជាងមុន និងដើម្បីកាត់បន្ថយការបាត់បង់ថាមពលឱ្យបិតក្នុងកំរិតកំណត់អនុញ្ញាត ។

## ៤.៤.២ កម្មវិធីលើកទឹកចិត្ត និងដាក់ពិន័យ

អាជ្ញាធរអគ្គិសនីកម្ពុជា បានកំណត់គោលការណ៍តម្លាភាពជាក់លាក់មួយ ក្នុងការផ្តល់អាណត្តិអាជ្ញាប័ណ្ណឱ្យសេវាករអគ្គិសនី ។ ក្នុងករណីដែលសេវាករបានធ្វើការកែលំអមធ្យោបាយធ្វើសេវាកម្មអគ្គិសនីស្របតាមស្តង់ដាបច្ចេកទេស និងគ្រប់គ្រងដំណើរការអាជីវកម្មមានប្រសិទ្ធភាព អ្នកកាន់អាជ្ញាប័ណ្ណមានសិទ្ធិដាក់ពាក្យស្នើសុំបន្តអាណត្តិអាជ្ញាប័ណ្ណ ហើយអាជ្ញាធរអគ្គិសនីកម្ពុជានឹងផ្តល់អាណត្តិមួយវែងជាមុន ។ ក្នុងករណីដែលសេវាករពុំបានកែលំអ ដំណើរការ និងគ្រប់គ្រងមធ្យោបាយធ្វើសេវាកម្មអគ្គិសនីឱ្យបានត្រឹមត្រូវ អាជ្ញាធរអគ្គិសនីកម្ពុជានឹងជ្រើសរើសអ្នកផ្សេង ដែលមានសមត្ថភាពផ្តល់សេវាកម្មប្រសើរជាងឱ្យមកជំនួសវិញ រួចអាជ្ញាធរនឹងដកហូតអាជ្ញាប័ណ្ណលែងឱ្យធ្វើសេវាកម្មអគ្គិសនីបន្តទៀតឡើយ ។

## ៤.៤.៣ កម្មវិធីកំណត់ហិរញ្ញវត្ថុ និងប្រកួតប្រជែង

ក្នុងកម្មវិធីនេះ អាជ្ញាធរអគ្គិសនីកម្ពុជាមានវិធីសាស្ត្រ ២ ។ វិធីសាស្ត្រទី១ គឺការកំណត់ឱ្យសេវាករធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងការត្រួតពិនិត្យហិរញ្ញវត្ថុរបស់សេវាករដោយអាជ្ញាធរអគ្គិសនីកម្ពុជា វិធីសាស្ត្រទី២ គឺការកំណត់ថ្លៃលក់អគ្គិសនីរបស់សេវាករអគ្គិសនីតូចៗជាកន្សោមក្នុងតារាងបញ្ជីថ្លៃលក់រួមមួយ ដែលនឹងបង្កើតនូវការប្រកួតប្រជែងមួយរវាងសេវាករដែលមានស្ថានភាព និងល័ក្ខខ័ណ្ឌអាជីវកម្មប្រហាក់ប្រហែលគ្នា ពេលនោះសេវាករណាដែលមានមធ្យោបាយធ្វើសេវាកម្មល្អនិងត្រឹមត្រូវ ដំណើរការសេវាកម្មមានប្រសិទ្ធភាពនឹងអាចទទួលបាននូវផលចំណេញច្រើន ហើយសេវាករណាដែលពុំបានកែ

លំអមធ្យោបាយអាជីវកម្មរបស់ខ្លួន សេវាករនោះអាចនឹងមានការលំបាក ឬអាចមានការខាតបង់ ហើយអាចឈានដល់ការបញ្ឈប់ការធ្វើសេវាកម្មរបស់ខ្លួន ។

អាជ្ញាធរអគ្គិសនីកម្ពុជាបានអនុវត្តកម្មវិធីទី១ និងទី២យ៉ាងសកម្មក្នុងជំហានដំបូង ដើម្បីឱ្យសេវាករធុនតូចត្រៀមខ្លួនចូលរួមក្នុងកម្មវិធីទី៣ ក្នុងល័ក្ខខ័ណ្ឌមួយសមស្របទៅតាមស្ថានភាពជាក់លាក់ និងតម្រូវការជាក់ស្តែងនៃកម្មវិធីអភិវឌ្ឍន៍ថាមពលអគ្គិសនីរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

## ៤.៥ ការកែលំអមធ្យោបាយធ្វើសេវាកម្មអគ្គិសនី

សេវាករទាំងអស់បានយល់ដឹង និងស្វាគមន៍ចំពោះកម្មវិធីនេះ ។ សេវាករជាច្រើនបានប្រឹងប្រែងធ្វើការកែលំអហេដ្ឋារចនាសម្ព័ន្ធធ្វើសេវាកម្មអគ្គិសនី តាមទិសដៅបង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចផ្នែកផលិតកម្ម និងចែកចាយអគ្គិសនី និងធានាកំរិតសុវត្ថិភាពដល់សាធារណជន ។ សេវាករទាំងនេះបានចំណាយថវិកាសំរាប់ធ្វើការកែលំអទៅតាមលទ្ធភាពហិរញ្ញវត្ថុជាក់ស្តែងរបស់ខ្លួន ។ សេវាករខ្លះទៀតបានខិតខំធ្វើការកែលំអដែរ ប៉ុន្តែពុំអាចរីកចំរើនតាមការចង់បានឡើយ ដោយសារតែចំណេះដឹងបច្ចេកទេសពុំគ្រប់គ្រាន់ និងថវិកាមានកំរិត ហើយមធ្យោបាយធ្វើសេវាកម្មអគ្គិសនីក៏នៅពុំទាន់សមស្របតាមស្តង់ដាបច្ចេកទេស ។ រូបភាពមធ្យោបាយធ្វើសេវាកម្មរបស់សេវាករដែលបានធ្វើការអភិវឌ្ឍន៍ និងកែលំអ ឈានមុខគេចំនួន ២រូប មានបង្ហាញជូនដូចខាងក្រោម ៖

**មធ្យោបាយធ្វើសេវាកម្មអគ្គិសនីរបស់លោក គួច អ៊ែតវើត**
**នៅទីប្រជុំជនផ្សារឧត្តុង្គ ឃុំរាំងចាស់ ស្រុកឧត្តុង្គ (ខេត្តកំពង់ស្ពឺ)**
**និងឃុំវិហារលួង ស្រុកពញាឮ (ខេត្តកណ្តាល)**



ម៉ាស៊ីនភ្លើងមុនពេលកែលំអ



ម៉ាស៊ីនភ្លើងក្រោយពេលកែលំអ



ទូរបញ្ជាមុនពេលកែលំអ



ទូរបញ្ជាក្រោយពេលកែលំអ



ប្រព័ន្ធចែកចាយតង់ស្យុងទាបមុនពេលកែលំអ



ប្រព័ន្ធចែកចាយតង់ស្យុងមធ្យមក្រោយពេលកែលំអ



ប្រព័ន្ធចែកចាយតង់ស្យុងទាបមុនពេលកែលំអ



ត្រង់ស្វូរម៉ាទ័រក្រោយពេលកែលំអ

## មធ្យោបាយធ្វើសេវាកម្មអគ្គិសនីរបស់លោក  គុយ  សួរ  នៅទីប្រជុំជនផ្សារស្ទូង
## ឃុំស្ទូង  ស្រុកត្បូងឃ្មុំ  (ខេត្តកំពង់ចាម)




ម៉ាស៊ីនភ្លើងមុនពេលកែលំអ




ម៉ាស៊ីនភ្លើងក្រោយពេលកែលំអ



ប្រព័ន្ធចែកចាយតង់ស្យុងទាបមុនពេលកែលំអ



ប្រព័ន្ធចែកចាយតង់ស្យុងមធ្យមក្រោយពេលកែលំអ




ប្រព័ន្ធនាឡិកាស្ទង់មុនពេលកែលំអ



សំភារៈអគ្គិសនីសំរាប់ធ្វើការកែលំអ

រូបភាពនៃការកែលំអដែលបានបង្ហាញខាងលើ មានខ្លឹមសារដូចខាងក្រោម :

ទី១-សេវាករ គួច អ៊ែតវើត កាន់អាជ្ញាប័ណ្ណលេខ ០៧៦ឯអ បានប្តូរប្រព័ន្ធផលិតកម្មពីការប្រើប្រេងដ្យេសែលមកប្រព័ន្ធថ្មីដោយប្រើប្រេងខ្មៅវិញ ធ្វើថ្លៃដើមផលិតកម្មចុះទាប និងបានសាងសង់រោងម៉ាស៊ីនភ្លើងថ្មីដោយអាចកាត់បន្ថយការរំខានដោយសំលេង និងជាតិពុលដទៃទៀតមកខាងក្រៅ ។ ចំពោះហេដ្ឋារចនាសម្ព័ន្ធចែកចាយវិញ សេវាករបានសាងសង់ប្រព័ន្ធតង់ស្យុងមធ្យម និងកែលំអប្រព័ន្ធតង់ស្យុងទាប ស្របតាមស្តង់ដាបច្ចេកទេសអគ្គិសនី ។ ដោយសារការកែលំអនេះ បានធ្វើឱ្យកំហាតបង់តាមខ្សែបណ្តាញកាត់បន្ថយមកត្រឹម ១៤% ។ ថ្លៃដើមអគ្គិសនីជាទូទៅទាប និងទទួលបាននូវប្រាក់ចំណូលច្រើនជាងមុន ។ ដោយពិនិត្យឃើញថា សេវាករបានខិតខំធ្វើការកែលំអហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីរបស់ខ្លួនដូចខាងលើ អាជ្ញាធរអគ្គិសនីកម្ពុជាបានសំរេចផ្តល់អាណត្តិអាជ្ញាប័ណ្ណចំនួន ១០ឆ្នាំ បន្តទៀតឱ្យសេវាករ ។

ទី២-សេវាករ គុយ ស៊ួរ កាន់អាជ្ញាប័ណ្ណលេខ ០២៧ឯអ បានប្តូរប្រព័ន្ធផលិតកម្មប្រើប្រេងដ្យេសែលចាស់ដែលគ្មានប្រសិទ្ធភាពមកប្រើប្រេងដ្យេសែលមានប្រសិទ្ធភាពជាងមុន (ជាកត្តាមួយយ៉ាងសំខាន់ក្នុងការកាត់បន្ថយនូវអត្រាប្រើប្រាស់ប្រេងក្នុងមួយគីឡូវ៉ាត់ម៉ោង) និងបានសាងសង់រោងម៉ាស៊ីនភ្លើងថ្មីដោយអាចកាត់បន្ថយការរំខានដោយសំលេង និងជាតិពុលដទៃទៀតមកខាងក្រៅ ។ សេវាករបានកែលំអហេដ្ឋារចនាសម្ព័ន្ធចែកចាយ ដោយបានកែលំអប្រព័ន្ធតង់ស្យុងមធ្យម និងកំពុងកែលំអប្រព័ន្ធតង់ស្យុងទាប ស្របតាមស្តង់ដាបច្ចេកទេសអគ្គិសនី ។ ថ្លៃដើមអគ្គិសនីនឹងចុះទាប និងទទួលបាននូវប្រាក់ចំណូលច្រើនជាងមុន ។ ដោយពិនិត្យឃើញថា សេវាករបានខិតខំធ្វើការកែលំអហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីរបស់ខ្លួនដូចខាងលើ អាជ្ញាធរអគ្គិសនីកម្ពុជាបានសំរេចផ្តល់អាណត្តិអាជ្ញាប័ណ្ណចំនួន ១០ឆ្នាំ បន្តទៀតឱ្យសេវាករ ។

### ៤.៥.១ ការកែលំអមធ្យោបាយផលិតកម្មរបស់សេវាករតូចៗ

អ្នកកាន់អាជ្ញាប័ណ្ណផ្សេងៗទៀតជាច្រើន ក៏បានបន្ថែម និងកែលំអមធ្យោបាយផលិតកម្មរបស់ខ្លួនដែរ ។ សេវាករខ្លះបានធ្វើការផ្លាស់ពីម៉ាស៊ីនភ្លើងដែលគ្មានប្រសិទ្ធភាព ទៅម៉ាស៊ីនភ្លើងដែលមានប្រសិទ្ធភាពជាងមុន ដើម្បីធានាស្ថេរភាពក្នុងការផ្គត់ផ្គង់អគ្គិសនី ។ សេវាករខ្លះបានកែលំអរោងម៉ាស៊ីនភ្លើង ហើយខ្លះបានតម្លើងនូវបញ្ជាត្រួតពិនិត្យ និងនូវបញ្ជាផ្តាច់ភ្ជាប់ចរន្តប្រសើរជាងមុន ។ មធ្យោបាយផលិតកម្មដែលបានកែលំអដោយអ្នកកាន់អាជ្ញាប័ណ្ណនានារហូតមកដល់ចុងឆ្នាំ ២០០៤ និងលំដាប់ថ្នាក់អាស្រ័យនឹងអត្រាប្រើប្រាស់ប្រេងឥន្ធនៈ មានបង្ហាញជូនក្នុងតារាងទី ៧ ខាងក្រោម ។

**តារាងទី ៧ : ពត៌មានស្តីពីការកែលំអមធ្យោបាយផលិតកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណតូចៗ**

| **អាជ្ញាប័ណ្ណលេខ** | **អ្នកកាន់អាជ្ញាប័ណ្ណ** | **សកម្មភាពកែលំអមធ្យោបាយផលិតកម្ម** |
|---|---|---|
| ១-ប្រសិទ្ធភាព **"ល្អ"** (អត្រាប្រើប្រាស់ប្រេងឥន្ធនៈតិចជាង ០.៣២ លីត្រក្នុង១គីឡូវ៉ាត់ម៉ោង) | | |
| 038L | លោក ឃុន ប៊ុនពេជ្រ | បានបន្ថែមម៉ាស៊ីនភ្លើងចំនួន ១គ្រឿង អានុភាព ៧៥ គីឡូវ៉ុលអាំពែរ និងបានប្តូរម៉ាស៊ីនភ្លើងពីអានុភាព ១០០ គីឡូវ៉ុលអាំពែរ ទៅអានុភាព ២០០ គីឡូវ៉ុលអាំពែរ |
| ២-ប្រសិទ្ធភាព **"មធ្យម"** (អត្រាប្រើប្រាស់ប្រេងឥន្ធនៈចន្លោះពី ០.៣២ ទៅ ០.៣៦ លីត្រក្នុង១គីឡូវ៉ាត់ម៉ោង) | | |
| 006L | លោក ហួរ ផេង | បានប្តូរឌីណាម៉ូចំនួន ១គ្រឿង ពីអានុភាព ២៥០ គីឡូវ៉ុលអាំពែរ ទៅអានុភាព ៣២០គីឡូវ៉ាត់ និងទូរបញ្ជា |
| 093L | លោក ឃុត ចិន្តា | បានកែលំអរោងម៉ាស៊ីនភ្លើង និងទូរបញ្ជា |
| 092L | លោក សោម វិសាល | បានកែលំអរោងម៉ាស៊ីនភ្លើង និងទូរបញ្ជា |
| 017L | លោកស្រី ប៊ុន លីវ | បានតម្លើងទូរសាំងក្រូ ទូរកុងដង់សាទ័រ និងបានកែលំអរោងម៉ាស៊ីន និងទូរបញ្ជាគ្មានសុវត្ថិភាព |
| ២-ប្រសិទ្ធភាព **"អន់"** (អត្រាប្រើប្រាស់ប្រេងឥន្ធនៈលើសពី ០.៣៦ លីត្រក្នុង១គីឡូវ៉ាត់ម៉ោង) | | |
| 013L | លោក ម៉ាក់ ធន | បានតម្លើងទូរសាំងក្រូន និងទូរបញ្ជា |
| 015L | លោក ស្រី សុខុម | បានបន្ថែមម៉ាស៊ីនភ្លើងចំនួន ១គ្រឿង អានុភាព ៥០ គីឡូវ៉ុលអាំពែរ, បានសាងសង់រោងម៉ាស៊ីនថ្មី និង ទូរបញ្ជា |
| 016L | លោក កែ គុយហ៊ួយ | បានប្តូរម៉ាស៊ីនភ្លើងចំនួន ១គ្រឿង ពីអានុភាព ២០ គីឡូវ៉ុលអាំពែរ ទៅ ៦០ គីឡូវ៉ុលអាំពែរ, បានកែលំអរោងម៉ាស៊ីន ក្នុងឆ្នាំ ២០០៣ និងទូរបញ្ជាគ្មានសុវត្ថិភាព |
| 018L | លោក គី សុភា | បានកែលំរោងរោងម៉ាស៊ីន និងទូរបញ្ជាគ្មានសុវត្ថិភាព |
| 019L | លោក តែ កុកអេង | បានប្តូរម៉ាស៊ីនភ្លើងចំនួន ១គ្រឿង ពីអានុភាព ៥០ គីឡូវ៉ុលអាំពែរ ទៅអានុភាព ១៥០ គីឡូវ៉ុលអាំពែរ, បានកែលំអរោងម៉ាស៊ីន ក្នុងឆ្នាំ ២០០៣ និងទូរបញ្ជាគ្មានសុវត្ថិភាព |
| 020L | លោក ឈួ ឡៃ | បានបន្ថែមម៉ាស៊ីនភ្លើងចំនួន ១គ្រឿង អានុភាព ៣៧ គីឡូវ៉ុលអាំពែរ |

| | | |
|---|---|---|
| 033L | លោក ឈូ ងួន | បានប្តូរម៉ាស៊ីនភ្លើងចំនួន ១គ្រឿង ពីអានុភាព ៥០ គីឡូវ៉ាត់ មក ៤០ គីឡូវ៉ាត់, បានកែលំអរោងរោងម៉ាស៊ីន និងទូរបញ្ជាគ្មានសុវត្ថិភាព |
| 035L | លោកស្រី ឈួយ ភឿត | បានប្តូរម៉ាស៊ីនភ្លើងចំនួន ១គ្រឿង ពីអានុភាព ៧៥ គីឡូវ៉ុលអាំពែរ ទៅអានុភាព ២០៨ គីឡូវ៉ុលអាំពែរ និងទូរបញ្ជាគ្មានសុវត្ថិភាព |
| 039L | លោក គឹម ច័ន្ទតារា | បានបន្ថែមម៉ាស៊ីនភ្លើងចំនួន ១គ្រឿង អានុភាព ៧៥ គីឡូវ៉ុលអាំពែរ |
| 042L | លោកស្រី មុយ គាន់ | បានបន្ថែមម៉ាស៊ីនភ្លើងចំនួន ១គ្រឿង អានុភាព ១២៥ គីឡូវ៉ុលអាំពែរ |
| 044L | លោក គង់ ពុទ្ធី | បានបន្ថែមម៉ាស៊ីនភ្លើងចំនួន ១គ្រឿង អានុភាព ២០០ គីឡូវ៉ុលអាំពែរ និងបានកែលំអរោងម៉ាស៊ីន និងទូរបញ្ជា |
| 046L | លោក សេង សុគន្ធ | បានប្តូរម៉ាស៊ីនភ្លើងចំនួន ១គ្រឿង ពីអានុភាព ៨៥ គីឡូវ៉ុលអាំពែរ ទៅ ១០០ គីឡូវ៉ុលអាំពែរ |
| 082L | លោក លី សុខគ្រី | បានបន្ថែមម៉ាស៊ីនភ្លើងចំនួន ១គ្រឿង អានុភាព ១០០ គីឡូវ៉ុលអាំពែរ |

### ៤.៥.២ ការកែលំអមធ្យោបាយចែកចាយរបស់សេវាករតូចៗ

សេវាករជាច្រើនបានធ្វើការកែលំអប្រព័ន្ធចែកចាយអគ្គិសនីរបស់ខ្លួន ដោយធ្វើការផ្លាស់ប្តូរខ្សែបណ្តាញពីប្រព័ន្ធប្រភេទ ១ហ្វា ឱ្យទៅជាប្រព័ន្ធប្រភេទ ៣ហ្វា និងមានមុខកាត់ខ្សែចំលងត្រឹមត្រូវ និងបានបន្ថែមត្រង់ស្វូតង់ស្យុងមធ្យម ២២ គីឡូវ៉ុល ។ ពត៌មានមួយចំនួនទាក់ទងនឹងការកែលំអមធ្យោបាយចែកចាយអគ្គិសនីរហូតមកដល់ចុងឆ្នាំ ២០០៤ មានបង្ហាញជូនក្នុងតារាងទី ៨ ខាងក្រោម ។

**តារាងទី ៨ : ពត៌មានស្តីពីការកែលំអមធ្យោបាយចែកចាយរបស់អ្នកកាន់អាជ្ញាប័ណ្ណតូចៗ**

| **អាជ្ញាប័ណ្ណលេខ** | **អ្នកកាន់អាជ្ញាប័ណ្ណ** | **សកម្មភាពកែលំអមធ្យោបាយចែកចាយ** |
|---|---|---|
| ១- ប្រសិទ្ធភាព "**ល្អ** " | | |
| 015L | លោក ស្រី សុខុម | បានកែលំអ ប្រព័ន្ធតង់ស្យុងទាបទាំង ស្រុង (ក្រោមជំនួយ ឧបត្ថម្ភរបស់ Gret Kosan ), កំហាតបង់ថាមពលតាមបណ្តាញ ៣៥% បានទទួលអាណត្តិបន្ត ៧ឆ្នាំ ។ |
| 093L | លោក ឃុត ចិន្តា | រៀបចំ ប្រព័ន្ធតង់ស្យុងមធ្យម ២២គីឡូវ៉ុល និងកែលំអ ប្រព័ន្ធតង់ស្យុងទាបទាំង ស្រុង, កំហាតបង់ថាមពលតាមបណ្តាញ ២៥% បានទទួលអាណត្តិបន្ត ៧ឆ្នាំ ។ |
| 017L | លោកស្រី ប៊ុន លីវ | រៀបចំ ប្រព័ន្ធតង់ស្យុងមធ្យម ៦.៣គីឡូវ៉ុល និងកែលំអ ប្រព័ន្ធតង់ស្យុងទាបមួយចំនួន, កំហាតបង់ថាមពលតាមបណ្តាញ ២៥% បានទទួលអាណត្តិបន្ត ៥ឆ្នាំ ។ |
| 044L | លោក គង់ ពុទ្ធី | រៀបចំ ប្រព័ន្ធតង់ស្យុងមធ្យម ២២គីឡូវ៉ុល និងកែលំអ ប្រព័ន្ធតង់ស្យុងទាបទាំង ស្រុង,កំហាតបង់ថាមពលតាមបណ្តាញ៣០% ។ |
| 006L | លោក ហួរ ផេង | រៀបចំ ប្រព័ន្ធតង់ស្យុងមធ្យម ៦.៣គីឡូវ៉ុល, កំហាតបង់ថាមពលតាមបណ្តាញ ៣៣% បានទទួលអាណត្តិបន្ត ៥ឆ្នាំ ។ |
| 092L | លោក សោម វិសាល | រៀបចំ ប្រព័ន្ធតង់ស្យុងមធ្យម ២២គីឡូវ៉ុល និងកែលំអ ប្រព័ន្ធតង់ស្យុងទាបទាំង ស្រុង, កំហាតបង់ថាមពលតាមបណ្តាញ ៣៥% |
| ២- ប្រសិទ្ធភាព "**មធ្យម** " | | |
| 035L | លោកស្រី ឈួយ ភឿត | កែលំអបានមួយចំនួនដោយប្តូរសសរឈើតូចៗជាសសរឈើគ្រាក់រឹងមាំ បានបន្ថែមចំនួនហ្វាឱ្យទៅជា ប្រព័ន្ធ ៣ហ្វា មុខកាត់ $70mm^2$ និង $35mm^2$,កំហាតបង់ថាមពលតាមបណ្តាញ ៣០% បានទទួលអាណត្តិបន្ត ៤ឆ្នាំ ។ |
| 020L | លោក ឈូ ឡៃ | បានកែលំអ ប្រព័ន្ធតង់ស្យុងទាបមួយចំនួន, កំហាតបង់ថាមពលតាមបណ្តាញ ៣០% បានទទួលអាណត្តិបន្ត ៣ឆ្នាំ ។ |
| 030L | លោក លី ប៊ុនធី | បានកែលំអ ប្រព័ន្ធតង់ស្យុងទាបមួយចំនួន, កំហាតបង់ថាមពលតាមបណ្តាញ ៣៨% បានទទួលអាណត្តិបន្ត ៣ឆ្នាំ ។ |

| | | |
|---|---|---|
| 018L | លោក គី សុភា | បានកែលំអប្រព័ន្ធតង់ស្យុងទាបមួយចំនួន, កំហាតបង់ថាមពលតាមបណ្តាញ ៣២% បានទទួលអាណត្តិបន្ត ៣ឆ្នាំ ។ |
| 013L | លោក ម៉ាក់ ធន | បានកែលំអបណ្តាញតង់ស្យុងទាបបានប្រវែង ៧០០ម និងបានប្តូរសសរពីឈើទៅបេតុង, កំហាតបង់ថាមពលតាមបណ្តាញ ៣៨% បានទទួលអាណត្តិបន្ត ៣ឆ្នាំ ។ |
| ២- ប្រសិទ្ធភាព "**អន់**" | | |
| 016L | លោក កែ គុយហ៊ួយ | បានកែលំអបណ្តាញតង់ស្យុងទាបបានតិចតួច, កំហាតបង់ថាមពលតាមបណ្តាញ ៣៥% បានទទួលអាណត្តិបន្ត ២ឆ្នាំ ។ |
| 026L | លោក ចាំង ប៊ុណ្ណារ៉េត | បានកែលំអខ្សែបណ្តាញដោយបន្ថែមចំនួនហ្វាឱ្យទៅជាប្រព័ន្ធ ៣ ហ្វាមុខកាត់ 70mm$^2$ និង 35mm$^2$ បានមួយចំនួនធំ និងបានប្តូរសសរឈើតូចៗជាសសរដែកមូល កំហាតបង់ថាមពលតាមបណ្តាញ ២៥% ។ |
| 083L | លោក ទន់ ឃឿន | បានកែលំអប្រព័ន្ធតង់ស្យុងទាប ដោយប្តូរសសរឈើតូចៗជាសសរឈើគ្រាក់រឹងមាំ បន្ថែមចំនួនហ្វាឱ្យទៅជាប្រព័ន្ធ៣ហ្វាមុខកាត់ 70mm$^2$ និង 35mm$^2$, កំហាតបង់ថាមពលតាមបណ្តាញ ៤០% ។ |
| 041L | លោក ទី សុគន្ធ | បានកែលំអប្រព័ន្ធតង់ស្យុងទាបមួយចំនួន, កំហាតបង់ថាមពលតាមបណ្តាញ ៣៥% ។ |
| 078L | លោក វ៉ន យាង | បានកែលំអប្រព័ន្ធតង់ស្យុងទាបមួយចំនួន, កំហាតបង់ថាមពលតាមបណ្តាញ ៣០% ។ |

# ជំពូកទី ៥





# របាយការណ៍



# ស្តីពី



# ការផលិត ការនាំចូល ការបញ្ជូន
# និងការផ្គត់ផ្គង់អគ្គិសនី



# ជំពូកទី ៥
# របាយការណ៍ស្តីពីការផលិត ការនាំចូល ការបញ្ជូន និងការផ្គត់ផ្គង់អគ្គិសនី

ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីរបស់ប្រទេសកម្ពុជានៅក្នុងឆ្នាំ ២០០៤ នៅតែជាប្រព័ន្ធទោលដាច់ៗពីគ្នា ដោយពុំទាន់មានខ្សែបណ្តាញបញ្ជូនភ្ជាប់ប្រព័ន្ធនេះបញ្ចូលគ្នានៅឡើយ ។ រាជធានីភ្នំពេញ ព្រមទាំងទីរួមខេត្ត និងទីប្រជុំជនទានា មានប្រព័ន្ធអគ្គិសនីផ្ទាល់របស់ខ្លួន ។ ក្រៅពីទីប្រជុំជនបិតនៅក្បែរព្រំដែនកម្ពុជា–វៀតណាម និងកម្ពុជា–ថៃ ដែលបានទិញអគ្គិសនីពីប្រទេសជិតខាងយកមកផ្គត់ផ្គង់ឱ្យអ្នកប្រើប្រាស់ក្នុងតំបន់របស់ខ្លួន តំបន់ដទៃទៀតសុទ្ធតែមានប្រព័ន្ធផលិតកម្មអគ្គិសនីរៀងៗខ្លួន ។ ប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីដែលធំជាងគេគឺប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីរាជធានីភ្នំពេញ ដែលផ្តល់ការផ្គត់ផ្គង់អគ្គិសនីឱ្យរាជធានីភ្នំពេញ និងតំបន់ជុំវិញ ។

## ៥.១ ការផលិតអគ្គិសនី

### ៥.១.១ ការផលិតអគ្គិសនីតាមប្រភេទអ្នកកាន់អាជ្ញាប័ណ្ណ

ផលិតកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវមាន ២ប្រភេទគឺ ១–ការផលិតដោយផលិតករអគ្គិសនីឯករាជដែលមានអាជ្ញាប័ណ្ណផលិតកម្ម ផលិត ហើយលក់អគ្គិសនីឱ្យអ្នកផ្គត់ផ្គង់ណាមួយតាមរយៈកិច្ចព្រមព្រៀងទិញអគ្គិសនីជាមួយអ្នកផ្គត់ផ្គង់នោះ និង២–ការផលិតដោយអ្នកផ្គត់ផ្គង់ផ្ទាល់ដែលមានអាជ្ញាប័ណ្ណរួម ដែលផលិតអគ្គិសនីសំរាប់ផ្គត់ផ្គង់ឱ្យប្រព័ន្ធចែកចាយរបស់ខ្លួន ។ អគ្គិសនីកម្ពុជាគឺជាអ្នកកាន់អាជ្ញាប័ណ្ណរួមធំជាងគេ ។

ពត៌មានស្តីពីទិន្នន័យនៃការផលិតអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណផលិតកម្មជារូបវ័ន្តបុគ្គល អគ្គិសនីកម្ពុជា និងអ្នកកាន់អាជ្ញាប័ណ្ណរួម មានបង្ហាញជូនក្នុងឧបសម្ព័ន្ធទី ៣, ឧបសម្ព័ន្ធទី ៥ និងឧបសម្ព័ន្ធទី ៦ ដោយឡែកៗពីគ្នា ។ ពត៌មានសង្ខេបស្តីពីអានុភាពតម្លើង និងថាមពលបញ្ចេញ មានបង្ហាញជូនក្នុងឧបសម្ព័ន្ធទី ២(ក) ។ បរិមាណថាមពលដែលបានបញ្ចេញដោយផលិតករអគ្គិសនីឯករាជ អគ្គិសនីកម្ពុជា និងអ្នកកាន់អាជ្ញាប័ណ្ណរួម មានបង្ហាញជូនក្នុងក្រាភិកខាងក្រោម ។

### ថាមពលបញ្ចេញ ក្នុងឆ្នាំ ២០០៤




## ៥.១.២ ការផលិតអគ្គិសនីតាមប្រភេទមធ្យោបាយផលិតកម្ម

សំរាប់ឆ្នាំ ២០០៤ មធ្យោបាយផលិតកម្មអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជាអាចបែងចែកជា ៣ប្រភេទ : ១-រោងចក្រវារីអគ្គិសនី, ២-រោងចក្រចំហាយដុតប្រេងឥន្ធនៈ និង ៣-រោងចក្រដេរ្យែសែល ។ បច្ចុប្បន្នមានរោងចក្រវារីអគ្គិសនីចំនួន២, មួយនៅគីរីរម្យភ្ជាប់មកប្រព័ន្ធអគ្គិសនីរាជធានីភ្នំពេញ និងមួយទៀតនៅខេត្តរតនៈគីរីភ្ជាប់មកប្រព័ន្ធអគ្គិសនីរតនៈគីរីរបស់អគ្គិសនីកម្ពុជា ។ មានរោងចក្រចំហាយដុតប្រេងឥន្ធនៈចំនួន១តម្លើងនៅរោងចក្រអគ្គិសនីទី២ រាជធានីភ្នំពេញ និងភ្ជាប់ជាមួយប្រព័ន្ធអគ្គិសនីរាជធានីភ្នំពេញ ក្រៅពីនោះ រោងចក្រអគ្គិសនីដទៃទៀតរបស់អ្នកកាន់អាជ្ញាប័ណ្ណគឺជារោងចក្រដេរ្យែសែលដែលប្រើប្រេងខ្មៅ និងប្រេងដេរ្យែសែល ។ ពត៌មានសង្ខេបស្តីពីអានុភាពតម្លើង និងថាមពលបញ្ចេញតាមប្រភេទនៃការផលិត មានបង្ហាញជូនក្នុងឧបសម្ព័ន្ធទី ២(ខ) ។

ដោយសារអាកាសធាតុពុំល្អ បរិមាណថាមពលដែលផលិតបានពីរោងចក្រវារីអគ្គិសនី ក្នុងឆ្នាំ ២០០៤ តិចជាងឆ្នាំ ២០០៣ ។ ថាមពលផលិតដោយរោងចក្រវារីអគ្គិសនីរបស់ក្រុមហ៊ុនស៊ីតិច នៅគីរីរម្យ១ បានថយចុះពី ៤០.៥០៩ លានគីឡូវ៉ាត់ម៉ោង ក្នុងឆ្នាំ ២០០៣ មក ២៧.០០៥ លានគីឡូវ៉ាត់ម៉ោង ក្នុងឆ្នាំ ២០០៤ ។ ដើម្បីឆ្លើយតបនឹងតម្រូវការបន្ទុក អគ្គិសនីកម្ពុជាបានបង្កើនការផលិតថាមពលអគ្គិសនីពីរោងចក្រចំហាយក្នុងឆ្នាំ ២០០៤ ច្រើន បើប្រៀបធៀបជាមួយឆ្នាំ ២០០៣ ។ សមាមាត្រនៃការផលិតថាមពលដោយរោងចក្រចំហាយបានកើនឡើងពី ៤.៥៥% ក្នុងឆ្នាំ ២០០៣ ទៅ ៨.៩% ក្នុងឆ្នាំ ២០០៤ ។

### ៥.១.៣ ថាមពលផលិតតាមទំហំរោងចក្រអគ្គិសនី

ចំពោះមធ្យោបាយផលិតកម្មអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណ ទំហំរបស់ម៉ាស៊ីនភ្លើងនីមួយៗ មានភាពខុសគ្នាយ៉ាងខ្លាំង ម៉ាស៊ីនដែលមានទំហំធំជាងគេគឺ ៦ មេហ្គាវ៉ាត់ ហើយម៉ាស៊ីនដែលមានទំហំតូចជាងគេគឺ ២៤ គីឡូវ៉ាត់ ។ ស្រដៀងគ្នាដែរ ទំហំនៃរោងចក្រអគ្គិសនី ក៏មានភាពខុសគ្នាខ្លាំងដែរ ។ រោងចក្រអគ្គិសនីដែលមានទំហំធំជាងគេមានអានុភាពសរុប ៣៧,១០០ គីឡូវ៉ាត់ ជារោងចក្ររបស់ក្រុមហ៊ុនស៊ីយូភីអ៊ិលនៅភ្នំពេញ និងរោងចក្រអគ្គិសនីដែលមានទំហំតូចជាងគេមានអានុភាព ២៤ គីឡូវ៉ាត់ ជារោងចក្ររបស់លោក ម៉ុក ជិន នៅភូមិស្វាយទង ឃុំខ្វាវ ស្រុកសំរោង ខេត្តតាកែវ ។ ពត៌មានសង្ខេបស្តីពីថាមពលបញ្ចេញបែងចែកតាមទំហំរោចចក្រអគ្គិសនី មានបង្ហាញជូនក្នុង ឧបសម្ព័ន្ធទី ២(ខ) ។

**ថាមពលបញ្ចេញបែងចែកតាមប្រភេទផលិតកម្ម**
**ក្នុងឆ្នាំ ២០០៤**



## ថាមពលបញ្ចេញបែងចែកតាមទំហំផលិតកម្ម
## ក្នុងឆ្នាំ ២០០៤



### ៥.១.៤ ថ្លៃលក់អគ្គិសនីរបស់អ្នកផលិតអគ្គិសនីឯករាជ

**តារាងទី ៩ : ពត៌មានស្តីពីថ្លៃលក់អគ្គិសនីក្នុង១គីឡូវ៉ាត់ម៉ោងរបស់ផលិតករអគ្គិសនីឯករាជ**

| ឈ្មោះផលិតករអគ្គិសនីឯករាជ | ថ្លៃលក់មធ្យម គិតជា សេនអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោង សំរាប់ខែនីមួយៗក្នុង៦ខែ ដើមឆ្នាំ ២០០៤ | | | | | |
|---|---|---|---|---|---|---|
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
| ក្រុមហ៊ុនស៊ីតិច, គីរីរម្យ១ | ៧.០០ | ៧.០០ | ៧.០០ | ៧.០០ | ៧.០០ | ៧.០០ |
| ក្រុមហ៊ុនស៊ីយូភីអ៊ិល, ភ្នំពេញ | ១១.៥៤ | ១១.៧៤ | ១២.២៤ | ១១.៨០ | ១២.១៥ | ១២.៣៤ |
| ក្រុមហ៊ុនហ្សាបភីធ័រ, ភ្នំពេញ | ១៣.៥៤ | ១៤.៥៣ | ១៤.១៨ | ១៤.៣១ | ១៤.២៧ | ១៥.២៣ |
| ក្រុមហ៊ុនហ្សាបភីធ័រ, ពោធិសាត់ | ១៧.៨៨ | ១៩.០៦ | ១៨.៦២ | ១៨.៧៧ | ១៨.៧៣ | - |
| ក្រុមហ៊ុនហ្សាបភីធ័រ, កំពង់ឆ្នាំង | ១៧.៨៨ | ១៩.០៦ | ១៨.៦២ | ១៨.៧៧ | ១៨.៧៣ | ១៩.៤៦ |
| ក្រុមហ៊ុន GTS, កំពង់ចាម | ១៥.៧៦ | ១៦.៥៦ | ១៦.២៧ | ១៦.២៥ | ១៦.២៥ | ១៧.២១ |
| ក្រុមហ៊ុន GPS, ព្រៃវែង | ១៦.០០ | ១៦.០០ | ១៦.០០ | ១៦.០០ | ១៦.០០ | ១៦.០០ |
| ក្រុមហ៊ុនកម្ពុជាសន្តិភាពវិនិយោគ, តាកែវ | ១៤.៦២ | ១៥.៧៨ | ១៥.៣៦ | ១៥.៥១ | ១៥.៤៧ | ១៦.៥៩ |
| ក្រុមហ៊ុនអ៊ែតវើតអេនើជីស៊ីបផ្លាយលីមីធីត | - | - | - | - | - | ១៥.៦៩ |
| ក្រុមហ៊ុន ហ្វីរ.ភី.អិន កម្ពុជាអន្តរជាតិ | - | - | - | - | - | - |

| ឈ្មោះផលិតករអគ្គិសនីឯករាជ | ថ្លៃលក់មធ្យម គិតជា សេនអាមេរិកក្នុង១គីឡូវ៉ាត់ម៉ោង សំរាប់ខែនីមួយៗក្នុង៦ខែ ចុងឆ្នាំ ២០០៤ | | | | | |
|---|---|---|---|---|---|---|
| | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
| ក្រុមហ៊ុនស៊ីតិច, គីរីរម្យ១ | ៧.០០ | ៧.០០ | ៧.០០ | ៧.០០ | ៧.០០ | ៧.០០ |
| ក្រុមហ៊ុនស៊ីយូភីអ៊ិល, ភ្នំពេញ | ១២.៥៨ | ១២.៣៩ | ១២.៦៧ | ១២.៦៧ | ១៣.២៨ | ១៣.៥៥ |
| ក្រុមហ៊ុនហ្សាបភីធ័រ, ភ្នំពេញ | ១៤.៩៣ | ១៥.៣២ | ១៦.៤០ | ១៦.៦៧ | ១៧.៤៩ | ១៧.៣៣ |
| ក្រុមហ៊ុនហ្សាបភីធ័រ, ពោធិសាត់ | - | - | - | - | - | - |
| ក្រុមហ៊ុនហ្សាបភីធ័រ,កំពង់ឆ្នាំង | ១៩.១០ | ១៩.៥៧ | ២០.៨៥ | ២១.១៨ | ២២.១៤ | ២១.៩៦ |

| | | | | | | |
|---|---|---|---|---|---|---|
| ក្រុមហ៊ុន GTS, កំពង់ចាម | ១៦.៨៨ | ១៧.៦៩ | ១៨.៦៣ | ១៩.០៩ | ១៩.៨៧ | ១៩.៥៤ |
| ក្រុមហ៊ុន GPS, ព្រៃវែង | ១៦.៨០ | ១៨.០៧ | ១៨.៤០ | ១៩.៣៦ | ១៩.១៧ | ១៧.៩២ |
| ក្រុមហ៊ុនកម្ពុជាសន្តិភាពវិនិយោគ, តាកែវ | ១៦.២៣ | ១៦.៧០ | - | - | - | - |
| ក្រុមហ៊ុនអ៊ែតវើតអេនើជីស៊ីបផ្លាយលីមីធីត | ១៥.៧០ | ១៥.៩៨ | ១៦.៥០ | ១៦.៧០ | ១៦.៩០ | ១៦.៩០ |
| ក្រុមហ៊ុន ហ្វីរ.ភី.អិន កម្ពុជា អន្តរជាតិ | - | - | ១៧.៣៣ | ១៨.៣០ | ១៨.០១ | ១៦.៩៧ |

**កំណត់សំគាល់ :**

- នៅទីរួមខេត្តពោធិសាត់ ក្រុមហ៊ុនហ្សាបភីធ័រ ផៅវ័រ (ខេមបូឌា) បានបញ្ឈប់ការដំណើរការផលិតកម្មរបស់ខ្លួនចាប់ពីខែមិថុនា ឆ្នាំ ២០០៤ ហើយក្រុមហ៊ុនអ៊ែតវើត អេនើជី ស៊ីបផ្លាយលីមីធីត បានចាប់ផ្តើមដំណើរការផលិតកម្មរបស់ខ្លួនចាប់ពីពេលនោះមក **ដោយមានថ្លៃលក់ទាបជាង** ក្រុមហ៊ុនហ្សាបភីធ័រ ផៅវ័រ (ខេមបូឌា) ។
- នៅទីរួមខេត្តតាកែវ ក្រុមហ៊ុនវិនិយោគកម្ពុជាសន្តិភាពបានបញ្ឈប់ការដំណើរការផលិតកម្មរបស់ខ្លួននៅខែកញ្ញា ឆ្នាំ ២០០៤ ហើយក្រុមហ៊ុន ហ្វីរ.ភី.អិន កម្ពុជាអន្តរជាតិ បានចាប់ផ្តើមដំណើរការផលិតកម្មរបស់ខ្លួន ចាប់ពីពេលនោះមក ។

## ៥.២ ការនាំចូលអគ្គិសនីពីប្រទេសជិតខាង

យោងតាមកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយរដ្ឋាភិបាលថៃនិងរដ្ឋាភិបាលវៀតណាម អ្នកកាន់អាជ្ញាប័ណ្ណចែកចាយដែលកំពុងធ្វើអាជីវកម្មចែកចាយនៅតំបន់ក្បែរព្រំដែនកម្ពុជា-ថៃ និងកម្ពុជា-វៀតណាមអាចមានលទ្ធភាពទិញអគ្គិសនីពីប្រទេសថៃ និងពីប្រទេសវៀតណាមមកផ្គត់ផ្គង់ឱ្យតំបន់ចែកចាយរបស់ខ្លួន ។ លើមូលដ្ឋាននៃកិច្ចព្រមព្រៀងសហប្រតិបត្តិការពាណិជ្ជកម្មអគ្គិសនីរវាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលកម្ពុជា ជាមួយក្រសួងឧស្សាហកម្មវៀតណាម អគ្គិសនីកម្ពុជាបានចុះហត្ថលេខាទិញអគ្គិសនីពីក្រុមហ៊ុនអគ្គិសនីទី២វៀតណាម សំរាប់ផ្គង់ផ្គង់អគ្គិសនីឱ្យតំបន់មេមត់ ក្រែកបាវិត កំពង់ត្រាច ដែលឋិតនៅក្បែរព្រំដែនកម្ពុជា-វៀតណាម ។ ដោយឡែក ក្រុមហ៊ុនឯកជនដទៃទៀតបានទទួលសិទ្ធិបន្តពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដើម្បីទិញអគ្គិសនីពីអាជ្ញាធរអគ្គិសនីខេត្តរបស់ថៃ សំរាប់ផ្គង់ផ្គង់អគ្គិសនីឱ្យតំបន់នានាដែលឋិតនៅក្បែរព្រំដែនកម្ពុជា-ថៃ ។ បច្ចុប្បន្នការនាំចូលថាមពលអគ្គិសនីពីប្រទេសវៀតណាម និងថៃ ធ្វើឡើងតាមរយៈខ្សែបណ្តាញតង់ស្យុង ២២គីឡូវ៉ុល ។

អានុភាពក្នុងកិច្ចសន្យា និងបរិមាណថាមពលអគ្គិសនីដែលបាននាំចូលនៅឆ្នាំ ២០០៣ និងឆ្នាំ ២០០៤ ព្រមទាំងឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ និងតំបន់ផ្គត់ផ្គង់ មានបង្ហាញជូនក្នុងតារាងទី ១០ ខាងក្រោម :

**តារាងទី ១០ : អានុភាព និងថាមពលអគ្គិសនីនាំចូលពីប្រទេសជិតខាង**

| ឈ្មោះ អ្នកកាន់ អាជ្ញាប័ណ្ណ | តំបន់ ផ្គត់ផ្គង់ | អានុភាព ក្នុង កិច្ចសន្យា គីឡូវ៉ាត់ | ថាមពលអគ្គិសនីនាំចូល គីឡូវ៉ាត់ម៉ោង | | កំណើន % |
|---|---|---|---|---|---|
| | | | ឆ្នាំ ២០០៣ | ឆ្នាំ ២០០៤ | |
| **១-ការនាំចូលអគ្គិសនីពីប្រទេសថៃ** | | | | | |
| ក្រុមហ៊ុន ហ្វ្រា ណាស៊ី អាហរ័ណ នីហរ័ណ | ទីប្រជុំជនស្រុក កំរៀង | ១,០០០ | ២,៣០៣,១២៤ | ២,៥១៨,៤៦៤ | ៩.៣ |
| | ទីប្រជុំជនស្រុក ភ្នំព្រឹក | ១,០០០ | ៣៦៤,២៥៤ | ៦២៦,៩២៨ | ៧២.១ |
| | ទីប្រជុំជនស្រុក សំពៅលូន | ១,០០០ | ៤៧៤,១៣២ | ៨០៦,៥៣២ | ៧០.១ |
| ក្រុមហ៊ុនអ៊ឹម អេសភី អភិវឌ្ឍន៍ លីមីធីត | ភូមិផ្សារព្រំ | ២,៥០០ | ៣,២១៨,៤៤០ | ៤,៣០១,២០០ | ៣៣.៦ |
| ក្រុមហ៊ុន អានកូ លីមីធីត | ស្រុកអូរជ្រៅ | ៥,០០០ | ២៨,៥៧២,៧២០ | ២០,០៨៦,៧២០[១] | -២៩.៧ |
| ឧធី ហ្វ្រីសប លីមីធីត | ទីរួមខេត្តកោះកុង | ២,០០០ | ១១,២៥៣,៧៥៥ | ១២,៥៦៤,២៤០ | ១១.៦ |
| | ទីប្រជុំជនអូរស្មាច់ | ២,០០០ | ៤,០៤៣,១៨០ | ៥,១១៤,៤៤០ | ២៦.៥ |
| **២-ការនាំចូលអគ្គិសនីពីប្រទេសវៀតណាម** | | | | | |
| អគ្គិសនី កម្ពុជា | ស្រុកពញាក្រែក | ៧០០ | ១,៨៥០,៣០០ | ៣,៩៦៧,៣០០ | ១១៤.៤ |
| | ស្រុកមេមត់ | ១,៧៥០ | ២,៤៤៨,៨០០ | ៣,៨៧២,៧០០ | ៥៨.១ |
| | ឃុំបាវិត | ៨០០ | ៣,៥៧៩,៥០០ | ៤,៩២៨,១០០ | ៣៧.៧ |

| | | | | | |
|---|---|---|---|---|---|
| | កំពង់ត្រាច | ១,០០០ | ១៦៩,១០០ | ៧០០,៥០០ | ៣១៤.៣ |
| **សរុប** | | **១៨,៧៥០** | **៥៨,២៧៧,៣០៥** | **៥៩,៤៨៧,១២៤** | **២.១** |

១–ការថយចុះនេះបណ្ដាលមកពីអ្នកប្រើប្រាស់ធំមួយប្រើថាមពលអគ្គិសនីផលិតដោយខ្លួនឯង

## តារាងទី ១១ : ពត៌មានស្ដីពីថ្លៃទិញអគ្គិសនីក្នុង១គីឡូវ៉ាត់ពីប្រទេសជិតខាង

| **អ្នកកាន់អាជ្ញាប័ណ្ណ** | **ថ្លៃទិញមធ្យម គិតជា សំរាប់៦ខែដើមឆ្នាំ ២០០៤** | | | | | |
|---|---|---|---|---|---|---|
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
| **ថ្លៃទិញអគ្គិសនីពីប្រទេសវៀតណាម គិតជា សេនអាមេរិក** | | | | | | |
| អគ្គិសនីកម្ពុជា, មេមត់ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ |
| អគ្គិសនីកម្ពុជា, ពញាក្រែក | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ |
| អគ្គិសនីកម្ពុជា, បាវិត | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ |
| អគ្គិសនីកម្ពុជា,កំពង់ត្រាច | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ |
| **ថ្លៃទិញអគ្គិសនីពីប្រទេសថៃ គិតជា បាត** | | | | | | |
| ក្រុមហ៊ុនអានកូ, ប៉ោយប៉ែត | ២.៥៥ | ២.៥៦ | ២.៩៣ | ២.៩៣ | ២.៩០ | ២.៩០ |
| ឧជីហ្វ្រីសប, កោះកុង | ២.៤៤ | ២.៦៥ | ២.៥៩ | ២.៥០ | ២.៦០ | ២.៦៥ |
| ឧជីហ្វ្រីសប, អូស្មាច់ | ២.៥០ | ២.៧៨ | ២.៧០ | ២.៥៣ | ២.៦២ | ២.៦៦ |
| អ៊ឹម.អេស.ភី, ប៉ៃលិន | ២.៥៩ | ២.៧៥ | ២.៧១ | ២.៦១ | ២.៦០ | ២.៧០ |
| ក្រុមហ៊ុនហ្វ្រាណាស៊ី, កំរៀង | ២.៥៧ | ២.៧៤ | ២.៦៧ | ២.៥៤ | ២.៥៤ | ២.៦១ |
| ក្រុមហ៊ុនហ្វ្រាណាស៊ី, សំពៅលូន | ២.៨២ | ៣.០២ | ២.៩៦ | ២.៨៣ | ២.៨៥ | ៣.០១ |
| ក្រុមហ៊ុនហ្វ្រាណាស៊ី, ភ្នំព្រឹក | ២.៧២ | ២.៨៦ | ២.៨៣ | ៣.១៤ | ២.៦៩ | ២.៨៤ |


| **អ្នកកាន់អាជ្ញាប័ណ្ណ** | **ថ្លៃទិញមធ្យម គិតជា សំរាប់៦ខែដើមឆ្នាំ ២០០៤** | | | | | |
|---|---|---|---|---|---|---|
| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
| **ថ្លៃទិញអគ្គិសនីពីប្រទេសវៀតណាម គិតជា សេនអាមេរិក** | | | | | | |
| អគ្គិសនីកម្ពុជា, មេមត់ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ |
| អគ្គិសនីកម្ពុជា, ពញាក្រែក | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ |
| អគ្គិសនីកម្ពុជា, បាវិត | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ |
| អគ្គិសនីកម្ពុជា,កំពង់ត្រាច | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ | ៦.៩០ |

| ថ្លៃទិញអគ្គិសនីពីប្រទេសថៃ គិតជា បាត | | | | | | |
|---|---|---|---|---|---|---|
| ក្រុមហ៊ុនអានកូ, ប៉ោយប៉ែត | ២.៩០ | ២.៩១ | ២.៩២ | ២.៩៣ | ២.៩២ | ២.៩២ |
| ឧូធី ហ្វ្រីសប, កោះកុង | ២.៦២ | ២.៦២ | ២.៦៧ | ២.៦៥ | ២.៧៥ | ២.៦៥ |
| ឧូធី ហ្វ្រីសប, អូស្វាច់ | ២.៦៣ | ២.៦៦ | ២.៧០ | ២.៦៩ | ២.៧៧ | ២.៦៨ |
| អ៊ឹម.អេស.ភី, ប៉ៃលិន | ២.៦៨ | ២.៦៥ | ២.៧៦ | ២.៧៦ | ២.៨៣ | ២.៨០ |
| ក្រុមហ៊ុន ហ្វ្រាណាស៊ី, កំរៀង | ២.៦៥ | ២.៦២ | ២.៧១ | ២.៧១ | ២.៧៨ | ២.៧៨ |
| ក្រុមហ៊ុន ហ្វ្រាណាស៊ី, សំពៅលូន | ២.៩៨ | ២.៩៥ | ៣.០៣ | ៣.០១ | ៣.០៧ | ៣.០២ |
| ក្រុមហ៊ុន ហ្វ្រាណាស៊ី, ភ្នំព្រឹក | ២.៨៤ | ២.៨១ | ២.៨៨ | ២.៨៤ | ២.៩០ | ២.៨៧ |

## ៥.៣ ការបញ្ជូនអគ្គិសនី

### ៥.៣.១ ខ្សែបញ្ជូន និងអនុស្ថានីយអគ្គិសនីតង់ស្យុងខ្ពស់

នៅឆ្នាំ ២០០៤ ខ្សែបញ្ជូនតង់ស្យុងខ្ពស់មាន២ខ្សែ គឺទី១-ខ្សែបញ្ជូនតង់ស្យុង ១១៥ គីឡូវ៉ុល ព័ទ្ធជុំវិញរាជធានីភ្នំពេញ និងទី២-ខ្សែបញ្ជូនតង់ស្យុង ១១៥ គីឡូវ៉ុល ដែលបញ្ជូនអគ្គិសនីពីស្ថានីយវារីអគ្គិសនីគីរីរម្យ១ មកផ្គត់ផ្គង់ឱ្យប្រព័ន្ធចែកចាយអគ្គិសនីរាជធានីភ្នំពេញ ។ យោងតាមគោលបំណងនៃការប្រើប្រាស់ ការដំណើរការខ្សែបណ្តាញតង់ស្យុង ១១៥ គីឡូវ៉ុល ព័ទ្ធជុំវិញរាជធានីភ្នំពេញត្រូវបានចាត់ទុកថា ជាសកម្មភាពបំរើឱ្យការធ្វើសេវាកម្មចែកចាយ ហើយមានតែខ្សែបណ្តាញតង់ស្យុង ១១៥ គីឡូវ៉ុល ដែលបញ្ជូនអគ្គិសនីពីស្ថានីយវារីអគ្គិសនីគីរីរម្យ១ មកផ្គត់ផ្គង់ឱ្យប្រព័ន្ធចែកចាយអគ្គិសនីរាជធានីភ្នំពេញទេ ដែលការដំណើរការរបស់វាត្រូវបានចាត់ទុកថា ជាសកម្មភាពផ្នែកបញ្ជូនអគ្គិសនី ។

**តារាងទី ១២ : ពត៌មានស្តីពីខ្សែបញ្ជូនតង់ស្យុងខ្ពស់**

| ល.រ | ឈ្មោះខ្សែបណ្តាញ | កម្មសិទ្ធិរបស់ | ពត៌មានលំអិត |
|---|---|---|---|
| ១ | ខ្សែបណ្តាញអាកាសព័ទ្ធជុំវិញរាជធានីភ្នំពេញ | អគ្គិសនីកម្ពុជា | តង់ស្យុង : ១១៥ គីឡូវ៉ុល<br>ប្រវែង : ២២.៧១ គីឡូម៉ែត្រ<br>គោលបំណង : ភ្ជាប់អនុស្ថានីយទាំង៣នៅក្នុងរាជធានីភ្នំពេញ ដើម្បីរក្សាស្ថិរភាពក្នុងការផ្គត់ផ្គង់អគ្គិសនី |
| ២ | ខ្សែបញ្ជូន (ខ្សែអាកាស) គីរីរម្យ១-កំពង់ស្ពឺ-ភ្នំពេញ | | តង់ស្យុង : ១១៥ គីឡូវ៉ុល<br>ប្រវែង : ១១១.២៤ គីឡូម៉ែត្រ |

| | | | |
|---|---|---|---|
| | | | គោលបំណង : បញ្ជូនអគ្គិសនីពីស្ថានីយវារីអគ្គិសនីគីរីរម្យ១មកឱ្យខេត្តកំពង់ស្ពឺ និងរាជធានីភ្នំពេញ |

## តារាងទី ១៣ : ពត៌មានស្ដីពីអនុស្ថានីយតង់ស្យុងខ្ពស់

| ល.រ | ឈ្មោះអនុស្ថានីយ | កម្មសិទ្ធិរបស់ | ពត៌មានលំអិត |
|---|---|---|---|
| ១ | អនុស្ថានីយទី១<br>នៅភ្នំពេញ | អគ្គិសនីកម្ពុជា | តង់ស្យុង : ១១៥/២២/១៥ គីឡូវ៉ុល<br>ចំនួននិងទំហំត្រង់ស្វូរ : ២ x ៣០ មេហ្គាវ៉ាត់<br>ចំនួនទ្វារចរន្តចែកចាយចេញ : ១៥<br>ចំនួនទ្វារចរន្តចែកចាយចូល : ៤<br>ចំនួនទ្វារចរន្តចែកចាយសរុប : ១៩ |
| ២ | អនុស្ថានីយទី២<br>នៅភ្នំពេញ | អគ្គិសនីកម្ពុជា | តង់ស្យុង : ១១៥/២២/១៥ គីឡូវ៉ុល<br>ចំនួននិងទំហំត្រង់ស្វូរ : ១ x ៣០ មេហ្គាវ៉ាត់<br>ចំនួនទ្វារចរន្តចែកចាយចេញ : ១៣<br>ចំនួនទ្វារចរន្តចែកចាយចូល : ៧<br>ចំនួនទ្វារចរន្តចែកចាយសរុប : ២០ |
| ៣ | អនុស្ថានីយទី៣<br>នៅភ្នំពេញ | អគ្គិសនីកម្ពុជា | តង់ស្យុង : ១១៥/២២គីឡូវ៉ុល និង២២/១៥គីឡូវ៉ុល<br>ចំនួននិងទំហំត្រង់ស្វូរ : ១ x ៣០ មេហ្គាវ៉ាត់<br>និង ១ x ១០ មេហ្គាវ៉ាត់<br>ចំនួនទ្វារចរន្តចែកចាយចេញ : ១២<br>ចំនួនទ្វារចរន្តចែកចាយចូល : ៤<br>ចំនួនទ្វារចរន្តចែកចាយសរុប : ១៦ |
| ៤ | អនុស្ថានីយ នៅកំពង់ស្ពឺ | អគ្គិសនីកម្ពុជា | តង់ស្យុង : ១១៥/២២ គីឡូវ៉ុល<br>ចំនួននិងទំហំត្រង់ស្វូរ : ១ x ៦.៣ មេហ្គាវ៉ាត់<br>ចំនួនទ្វារចរន្តចែកចាយចេញ : ១<br>ចំនួនទ្វារចរន្តចែកចាយចូល : ១<br>ចំនួនទ្វារចរន្តចែកចាយសរុប : ២ |

### ៥.៣.២ ការបញ្ជូនអគ្គិសនី

ពត៌មានស្តីពីការបញ្ជូនអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានបង្ហាញជូនក្នុងតារាងទី ១៤ ខាងក្រោម :

**តារាងទី ១៤ : ការបញ្ជូនអគ្គិសនី**

| ល.រ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | ខ្សែបណ្តាញបញ្ជូន | ថាមពលបញ្ជូន, គីឡូវ៉ាត់ម៉ោង | |
|---|---|---|---|---|
| | | | ឆ្នាំ ២០០៣ | ឆ្នាំ ២០០៤ |
| ១ | អគ្គិសនីកម្ពុជា | គីរីរម្យ១-កំពង់ស្ពឺ-ភ្នំពេញ | ៤០,៥០៨,៨៩៦ | ២៧,០០៥,១៦៣ |

## ៥.៤ ការចែកចាយអគ្គិសនី

### ៥.៤.១ មធ្យោបាយចែកចាយអគ្គិសនី

ជាទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា មធ្យោបាយចែកចាយអគ្គិសនីរបស់អ្នកកាន់អាជ្ញាប័ណ្ណរួម និងអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ គឺជាកម្មសិទ្ធិរបស់អ្នកកាន់អាជ្ញាប័ណ្ណផ្ទាល់ ដែលបានទទួលសិទ្ធិធ្វើការចែកចាយអគ្គិសនីនៅក្នុងតំបន់ចែកចាយកំណត់មួយ ។ បច្ចុប្បន្នអនុស្ថានីយបញ្ចុះពីតង់ស្យុងខ្ពស់មកតង់ស្យុងមធ្យម ខ្សែបណ្តាញតង់ស្យុងមធ្យម បន្ទប់ត្រង់ស្វូ ខ្សែបណ្តាញតង់ស្យុងទាប និងឧបករណ៍សំរាប់ផ្គត់ផ្គង់អគ្គិសនីឱ្យអតិថិជន ត្រូវបានចាត់ទុកថាជា មធ្យោបាយចែកចាយអគ្គិសនី ។

ពត៌មានស្តីពីមធ្យោបាយចែកចាយអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ ២០០៤ មានបង្ហាញជូននៅក្នុងតារាងទី ១៥ ខាងក្រោម :

**តារាងទី ១៥ : ពត៌មានស្តីពីមធ្យោបាយចែកចាយអគ្គិសនី**

| ឈ្មោះ | ឯកតា | ចំនួន/ប្រវែងខ្សែបណ្តាញ | |
|---|---|---|---|
| | | ឆ្នាំ ២០០៣ | ឆ្នាំ ២០០៤ |
| ១-ខ្សែបណ្តាញតង់ស្យុង ២២គវ៉ | គីឡូម៉ែត្រ | ៤៣៤.៣ | ៤៤៧.៥៥ |
| -ខ្សែកាបកប់ដី | គីឡូម៉ែត្រ | ២៣៥.៨ | ២៣៥.៨ |
| -ខ្សែអាកាស | គីឡូម៉ែត្រ | ១៩៨.៥ | ២១១.៧៥ |
| ២-ខ្សែបណ្តាញតង់ស្យុង ១៥គវ៉ | គីឡូម៉ែត្រ | ៣៨.៣៩ | ៣៨.៣៩ |
| -ខ្សែកាបកប់ដី | គីឡូម៉ែត្រ | ៨.៦១ | ៨.៦១ |

| | | | |
|---|---|---|---|
| -ខ្សែអាកាស | គីឡូម៉ែត្រ | ២៩.៧៨ | ២៩.៧៨ |
| ៣-ខ្សែបណ្តាញតង់ស្យុង ៦.៣គវ<br>-ខ្សែកាបកប់ដី<br>-ខ្សែអាកាស | គីឡូម៉ែត្រ<br>គីឡូម៉ែត្រ<br>គីឡូម៉ែត្រ | ១៣.២៦<br>០.៥៦<br>១២.៧ | ១៤.៨៦<br>០.៥៦<br>១៤.៣ |
| ៤-ខ្សែបណ្តាញតង់ស្យុងទាប<br>-ខ្សែកាបកប់ដី<br>-ខ្សែអាកាស | គីឡូម៉ែត្រ<br>គីឡូម៉ែត្រ<br>គីឡូម៉ែត្រ | ១,៥៣៦.២២<br>១៩៣<br>១,៣៤៣.២២ | ១,៧៧៦.១៣<br>១៩៣<br>១,៥៨៦.១៣ |
| ៥-បន្ទប់ត្រង់ស្វូរ<br>- ត្រង់ស្វូ<br>-អានុភាព | ចំនួន<br>គ្រឿង<br>MVA | ៣៥៦<br>៥៨០<br>៤៨៩.៥៨ | ៣៧៦<br>៦០០<br>៤៩២.៣៦ |

### ៥.៤.២ បរិមាណថាមពលលក់ និងចំនួនអ្នកប្រើប្រាស់

**តារាងទី ១៦ : ពត៏មានសង្ខេបស្តីពីការធ្វើអាជីវកម្មផ្គត់ផ្គង់អគ្គិសនី**

| តំបន់សេវាកម្ម | ថាមពលផលិត និងទិញ លានគីឡូវ៉ាត់ម៉ោង | ថាមពលលក់ លានគីឡូវ៉ាត់ ម៉ោង | សមាមាត្រ បាត់បង់ % | ចំនួនអ្នក ប្រើប្រាស់ |
|---|---|---|---|---|
| ប្រព័ន្ធភ្នំពេញ | ៦៤១.៥៣ | ៥៥៧.៧៣ | ១៣ | ១៤៩,៩២២ |
| តំបន់ទទួលការផ្គត់ផ្គង់ អគ្គិសនីពីវៀតណាម | ១៣.៤៧ | ១២.៦២ | ៦.៣ | ៦,២៧៦ |
| តំបន់ទទួលការផ្គត់ផ្គង់ អគ្គិសនីពី ប្រទេសថៃ | ៤៦.០២ | ៤១.៦២ | ៩.៦ | ១០,៧០៤ |
| ទីរួមខេត្តនានា | ៩៨.៥៩ | ៨០.៤៦ | ១៨.៤ | ៦៦,៩៥៦ |
| តំបន់ដទៃទៀត និងតំបន់ជនបទ | ១៤.៥២ | ៩.៨៩ | ៣១.៩ | ៣៨,៨១០ |
| **សរុប** | **៨១៤.១៣០** | **៧០២.៣១២** | **១៣.៧** | **២៧២,៦៦៨** |

ពត៌មានសង្ខេបស្តីពីបរិមាណថាមពលផលិត ទិញ ចែកចាយ លក់ និងបាត់បង់របស់អ្នកកាន់អាជ្ញាប័ណ្ណនីមួយៗ មានបង្ហាញជូនក្នុងឧបសម្ព័ន្ធទី ៤, ឧបសម្ព័ន្ធទី ៥ និងឧបសម្ព័ន្ធទី ៦ ។

### ៥.៤.៣ បញ្ជីថ្លៃលក់អគ្គិសនី

បញ្ជីថ្លៃលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជា ដែលអនុវត្តក្នុងអំឡុងឆ្នាំ ២០០៤ សំរាប់រាជធានីភ្នំពេញ និងខេត្តកណ្តាល មានបង្ហាញជូនក្នុងតារាងទី ១៧ និងសំរាប់ទីរួមខេត្ត-ក្រុង និងទីប្រជុំជននានា មានបង្ហាញជូនក្នុងតារាងទី ១៨ ខាងក្រោម ។

**តារាងទី ១៧ : បញ្ជីថ្លៃលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជាសំរាប់រាជធានីភ្នំពេញ និងខេត្តកណ្តាល**

| ប្រភេទអ្នកប្រើប្រាស់ | បរិយាយ | រៀលក្នុង១ គីឡូវ៉ាត់ម៉ោង |
|---|---|---|
| លំនៅដ្ឋាន | រហូតដល់ ៥០គីឡូវ៉ាត់ម៉ោងក្នុង១ខែ | ៣៥០ |
| | ពី ៥១ ដល់ ១០០គីឡូវ៉ាត់ម៉ោងក្នុង១ខែ | ៥៥០ |
| | ពី ១០១គីឡូវ៉ាត់ម៉ោងក្នុង១ខែ | ៦៥០ |
| ស្ថាប័នរដ្ឋ | | ៧០០ |
| កន្លែងធ្វើការរបស់អង្គការក្រៅរដ្ឋាភិបាល លំនៅដ្ឋានជនបរទេស និងស្ថានទូតនានា | | ៨០០ |
| កន្លែងធ្វើពាណិជ្ជកម្ម | តូច | ៦៥០ |
| | មធ្យម | ៦០០ |
| | ធំ | ៥០០ |
| | តង់ស្យុងមធ្យម | ៤៨០ |
| ឧស្សាហកម្ម និងសិប្បកម្ម | តូច | ៦០០ |
| | មធ្យម | ៥៥០ |
| | ធំ | ៥០០ |
| | តង់ស្យុងមធ្យម | ៤៨០ |
| **អតិថិជនធុន ឧស្សាហកម្ម និងពាណិជ្ជកម្មទាំង ៤ប្រភេទ ត្រូវកំណត់ដូចខាងក្រោម :** | | |
| **ធុនតូច** – អតិថិជនដែលភ្ជាប់ចរន្តពីខ្សែបណ្តាញសាធារណៈនៅតង់ស្យុងទាប ២២០វ៉ុល និង៣៨០វ៉ុល | | |
| **ធុនមធ្យម** – អតិថិជនដែលភ្ជាប់ចរន្តពីអនុស្ថានីយ៍តង់ស្យុងមធ្យម/ទាប ដោយទ្វារចរន្តដាច់ដោយឡែកៗ និងមានតម្លើងនាឡិកាស្ទង់ក្នុងអនុស្ថានីយ៍ និងធានាប្រើប្រាស់ថាមពលអគ្គិសនីមួយខែយ៉ាងតិច ២០,០០០ គីឡូវ៉ាត់ម៉ោង | | |

| | |
|---|---|
| **ធុនធំ – សាធារណៈ** | អតិថិជនដែលមានអនុស្ថានីយ៍ដាច់ដោយឡែកឬក៏ប្រើប្រាស់ថាមពលមួយផ្នែកពីអនុស្ថានីយ៍ និងមានតម្លើងនាឡិកាស្ទង់នៅក្នុងអនុស្ថានីយ ឬនៅក្បែរអនុស្ថានីយរបស់ខ្លួនផ្ទាល់ និងធានាប្រើប្រាស់ថាមពលអគ្គិសនីមួយខែយ៉ាងតិច ៥០,០០០ គីឡូវ៉ាត់ម៉ោង |
| **តង់ស្យុងមធ្យម –** | អតិថិជនដែលភ្ជាប់ទៅនឹងខ្សែបណ្តាញតង់ស្យុងមធ្យមដោយផ្ទាល់ ដោយមានតម្លើងនាឡិកាស្ទង់តង់ស្យុងមធ្យម និងធានាប្រើប្រាស់ថាមពលអគ្គិសនីមួយខែយ៉ាងតិច ៨០,០០០គីឡូវ៉ាត់ម៉ោង |

## តារាងទី ១៨ : បញ្ជីថ្លៃលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជាសំរាប់ទីរួមខេត្តក្រុង និងទីប្រជុំជននានា

| តំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា | អធិប្បាយ | បញ្ជីថ្លៃលក់អគ្គិសនី | |
|---|---|---|---|
| | | រៀលក្នុង១គីឡូវ៉ាត់ម៉ោង | សេនដុល្លា ក្នុង១គីឡូវ៉ាត់ម៉ោង |
| **ក្រុងព្រះសីហនុ** | | | |
| លំនៅដ្ឋាន | | ៥០០ | |
| សហគ្រាស ឧស្សាហកម្ម | ប្រើប្រាស់ថាមពលរហូតដល់ ២០,០០០ គីឡូវ៉ាត់ម៉ោងក្នុង១ខែ | | ១៧.៥ |
| | ប្រើប្រាស់ពី ២០,០០១ ដល់ ៥០,០០០ គីឡូវ៉ាត់ម៉ោងក្នុង១ខែ | | |
| | ពេលថ្ងៃ | | ១៦.០ |
| | ពេលយប់ | | ១៧.៥ |
| | ប្រើប្រាស់ពី ៥០,០០១ ដល់ ១១០,០០០ គីឡូវ៉ាត់ម៉ោងក្នុង១ខែ | | |
| | ពេលថ្ងៃ | | ១៤.៧ |
| | ពេលយប់ | | ១៧.៥ |
| | ប្រើប្រាស់លើសពី ១១០,០០០ គីឡូវ៉ាត់ម៉ោងក្នុង១ខែ | | |
| | ពេលថ្ងៃ | | ១៣.៥ |
| | ពេលយប់ | | ១៧.៥ |
| កន្លែងធ្វើ | ប្រើប្រាស់រហូតដល់ ២០,០០០គីឡូវ៉ាត់ម៉ោង ក្នុង១ខែ | | ១៩.៥ |

| | | | |
|---|---|---|---|
| ពាណិជ្ជកម្ម | ប្រើប្រាស់ពី ២០,០០១ ដល់៥០,០០០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ | | ១៨.០ |
| | ប្រើប្រាស់ពី ៥០,០០១ ដល់ ១១០,០០០ គីឡូវ៉ាត់ម៉ោងក្នុង១ខែ | | ១៦.៤ |
| | ប្រើប្រាស់លើសពី ១១០,០០០ គីឡូវ៉ាត់ម៉ោងក្នុង១ខែ | | ១៥.០ |
| សណ្ឋាគារ និងលំនៅដ្ឋានជនបរទេស | ប្រើប្រាស់រហូតដល់ ២០,០០០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ | | ២០.០ |
| | ប្រើប្រាស់ពី ២០,០០១ ដល់៥០,០០០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ | | ១៨.៤ |
| | ប្រើប្រាស់ពី ៥០,០០១ ដល់ ១១០,០០០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ | | ១៧.០ |
| | ប្រើប្រាស់លើសពី ១១០,០០០ គីឡូវ៉ាត់ម៉ោងក្នុង១ខែ | | ១៦.០ |
| ស្ថានទូតនានា និងស្ថាប័នរដ្ឋ | | ៧៦០ | |
| **ទីរួមខេត្តសៀមរាប** | ប្រើប្រាស់រហូតដល់ ២០,០០០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ | ៧៨០ | |
| | ប្រើប្រាស់ពី ២០,០០១ ដល់៥០,០០០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ | ៧៥០ | |
| | ប្រើប្រាស់ពី ៥០,០០១ ដល់ ១១០,០០០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ | ៧០០ | |
| | ប្រើប្រាស់លើសពី ១១០,០០០ គីឡូវ៉ាត់ម៉ោងក្នុង១ខែ | ៦៥០ | |
| **ទីរួមខេត្តកំពង់ចាម** | គ្រប់ប្រភេទ | ៨៥០ | |
| **ទីរួមខេត្តបាត់ដំបង** | គ្រប់ប្រភេទ | | ២៤.៥ |
| **ទីរួមខេត្តតាកែវ** | គ្រប់ប្រភេទ | ៩០០ | |
| **ស្រុកមេមត់ ក្រែក និងឃុំបាវិត** | តាមតង់ស្យុងទាប | ៦៥០ | ១៦.០ |
| | តាមតង់ស្យុងមធ្យម | | ១១.៥ |

ពត៌មានលំអិតស្តីពីបញ្ជីថ្លៃលក់អគ្គិសនីនៅតាមតំបន់ផ្គត់ផ្គង់អគ្គិសនីដទៃទៀតរបស់អ្នកកាន់អាជ្ញាប័ណ្ណនីមួយៗផ្សេងទៀត មានបង្ហាញជូនក្នុងឧបសម្ព័ន្ធទី ៧ ។

## ឧបសម្ព័ន្ធទី ១

## ពត៌មានស្តីពីតំបន់ផ្គត់ផ្គង់ដោយអ្នកកាន់អាជ្ញាប័ណ្ណរួម និងអ្នកកាន់អាជ្ញាប័ណ្ណចែកចាយ និងរយៈពេលផ្គត់ផ្គង់

| ខេត្ត/ក្រុង | តំបន់ធ្វើសេវាកម្ម | លេខអាជ្ញាប័ណ្ណ | ឈ្មោះអ្នកកាន់អាជ្ញាប័ណ្ណ | រយៈពេលផ្គត់ផ្គង់ |
|---|---|---|---|---|
| **១-បន្ទាយមានជ័យ** | ទីប្រជុំជនផ្សារអូរស្ងួត ឃុំអូរប្រាសាទ ស្រុកមង្គលបូរី | 077L | លោកស្រី ចៅ នុយ | ពីម៉ោង ១៧:00 ដល់ម៉ោង ២៣:00, ពីម៉ោង 0:00 ដល់ម៉ោង ៦:00 និង ពីម៉ោង ១១:00 ដល់ម៉ោង ១៤:00 |
| | ទីប្រជុំជនផ្សារគុត្តសត្ត ឃុំនិមិត្ត និងឃុំកូប ស្រុកអូរជ្រៅ | 078L | លោក វ៉ន យាង | ពីម៉ោង ១៨:00 ដល់ម៉ោង ២១:00 |
| | ទីប្រជុំផ្សារភ្នំតូច ឃុំភ្នំតូច ស្រុកមង្គលបូរី | 079L | លោក ធន់ ធឿន | ពីម៉ោង ១១:១៥ ដល់ម៉ោង ១៥:00 និងពីម៉ោង ១៨:00 ដល់ ម៉ោង ២១:00 |
| | ទីប្រជុំជនផ្សារបន្ទាយនាង ឃុំបន្ទាយនាង ស្រុកមង្គលបូរី | 080L | លោក សុខ វិចិត | ពីម៉ោង ១២:00 ដល់ម៉ោង ១៧:00 និង ពីម៉ោង ១៨:00 ដល់ ម៉ោង ២២:00 |
| | ទីរួមស្រុកភ្នំស្រុក | 081L | លោក មួន ហាន | ពីម៉ោង ១៧:៣0 ដល់ម៉ោង ២២:00 |
| | ទីប្រជុំជនផ្សារភ្នំធំត្បូង ឃុំអូរប្រាសាទ ស្រុកមង្គលបូរី | 105L | លោក សឿង សុវណ្ណា | ពីម៉ោង ១១:00 ដល់ម៉ោង ១៣:00 និងពីម៉ោង ១៨:00 ដល់ ម៉ោង ៦:00 |
| | ស្រុកអូរជ្រៅ | 011L | ក្រុមហ៊ុន អានកូ | ផ្គត់ផ្គង់ ២៤ ម៉ោងពេញ |

| | | | | |
|---|---|---|---|---|
| | ទីរួមស្រុកថ្មពួក | 087L | លោក ហង្ស សុវត្ថិសុធា | ពីម៉ោង ១៣:០០ ដល់ម៉ោង ១៥:០០ និងពីម៉ោង ១៨:០០ ដល់ ម៉ោង ២២:០០ |
| **២-ខេត្តបាត់ដំបង** | ទីរួមខេត្តបាត់ដំបង | 001L | អគ្គិសនីកម្ពុជា | ផ្គត់ផ្គង់ ២៤ ម៉ោងពេញ |
| | ទីប្រជុំជនស្រុកកំរៀង, ទីប្រជុំជនស្រុក ភ្នំព្រឹក និងទីប្រជុំជនស្រុកសំពៅលូន | 008L | ក្រុមហ៊ុនហ្វ្រាណាស៊ី អាហរ័ណ នីហរ័ណ | ផ្គត់ផ្គង់ ២៤ ម៉ោងពេញ |
| | ទីប្រជុំជនថ្មគោល ស្រុកថ្មគោល | 043L | លោក ឡាយ សែ | ផ្គត់ផ្គង់ ២៤ ម៉ោងពេញ |
| | ឃុំភ្នំសំពៅ ស្រុកបាណន់ | 068L | លោកស្រី ទូច មន្ថា | ពីម៉ោង ៥:០០ ដល់ម៉ោង ៦:៣០, ពីម៉ោង ១១:០០ ដល់ម៉ោង ១៤:០០ និងពីម៉ោង ១៧:០០ ដល់ម៉ោង ២៣:០០ |
| | ទីរួមស្រុករតនៈមណ្ឌល | 069L | លោក ណុប ប៊ិន | ពីម៉ោង ៤:០០ ដល់ម៉ោង ៧:០០, ពីម៉ោង ១១:០០ ដល់ម៉ោង ១៤:០០ និងពីម៉ោង ១៧:០០ ដល់ម៉ោង ២៣:០០ |
| | ភូមិប៉ោយសំរោង ឃុំតាពួង ស្រុកថ្មគោល | 070L | លោក ប៊ូ បឿន | ពីម៉ោង ១៨:០០ ដល់ម៉ោង ២២:០០ |
| | ឃុំព្រែកខ្ពប និងឃុំព្រែកហ្លួង ស្រុកឯកភ្នំ | 091L | លោក ស៊ុន ពៅ | ពីម៉ោង ៤:៣០ ដល់ម៉ោង ៦:៣០, ពីម៉ោង ៩:០០ ដល់ម៉ោង ១៤:៣០ និងពីម៉ោង ១៧:៣០ ដល់ម៉ោង ២២:៣០ |
| **៣-កំពង់ចាម** | ទីរួមខេត្តកំពង់ចាម ស្រុកពញាក្រែក ស្រុកមេមត់ | 001L | អគ្គិសនីកម្ពុជា | ផ្គត់ផ្គង់ ២៤ ម៉ោងពេញ |

| | | | | |
|---|---|---|---|---|
| | ភូមិថ្នល់បែក ឃុំស្វាយទាប ស្រុកចំការលើ | 038L | លោក ឃុត ប៊ុនពេជ្រ | ពីម៉ោង ១២:០០ ដល់ម៉ោង ១៤:០០ និងពីម៉ោង ១៨:០០ ដល់ម៉ោង ២២:០០ |
| | ទីប្រជុំជនផ្សារស្គន់ ឃុំសូទិព្វ ស្រុកជើងព្រៃ | 047L | លោក ម៉ុំ តារា | ពីម៉ោង ៣:៣០ ដល់ម៉ោង ២៣:៣០ |
| | ឃុំមេសរជ្រៃ ស្រុកស្ទឹងត្រង់ | 060L | លោក លឹម សុខុន | ពីម៉ោង ៤:០០ ដល់ម៉ោង ២២:០០ |
| | ទីប្រជុំជនផ្សារមៀន ឃុំមៀន និងឃុំត្រពាំងព្រះ ស្រុកព្រៃឈរ | 065L | លោក ជូ ស្រ៊ាន់ | ពីម៉ោង ៤:០០ ដល់ ៥:០០ និងពីម៉ោង ១៧:៣០ ដល់ម៉ោង ២២:៣០ |
| | ផ្សារស្វាយទាប ឃុំស្វាយទាប ស្រុកចំការលើ | 074L | លោក មាន វណ្ណា | ពីម៉ោង ១១:៣០ ដល់ម៉ោង ២២:០០ |
| | ទីប្រជុំជនផ្សារស្ដី ឃុំស្ដីនិងជ័យោ ស្រុកចំការលើ | 075 | លោក ឆាយ គឹមហ៊ួរ | ពីម៉ោង ១៧:៣០ ដល់ម៉ោង ២២:៣០ |
| | ទីប្រជុំជនផ្សារថ្នល់ទទឹង ឃុំជប់ ស្រុកត្បូងឃ្មុំ | 085L | លោក ស៊ឹម សុខា | ពីម៉ោង ៥:០០ ដល់ម៉ោង ៦:០០ និងពីម៉ោង ១៧:៣០ ដល់ម៉ោង ២៣:០០ |
| | ទីប្រជុំជនផ្សារផ្អាវ ឃុំផ្អាវ ស្រុកបាធាយ | 026L | លោក ចាំង ប៊ុណ្ណារ៉េត | ពីម៉ោង ៤:៣០ ដល់ម៉ោង ៦:៣០ និងពីម៉ោង ១៨:០០ ដល់ម៉ោង ២៣:០០ |
| | ទីប្រជុំជនផ្សារសួង ឃុំសួង ស្រុកត្បូងឃ្មុំ | 027L | លោក គុយ ស៊ួរ | ពីម៉ោង ២:៣០ ដល់ ម៉ោង ២៣:៣០ |
| | ទីប្រជុំជនផ្សារព្រៃទទឹង ស្រុកព្រៃឈរ | 023L | លោក ឃុន សំបូរ | ផ្គត់ផ្គង់ ២៤ ម៉ោងពេញ |
| | ទីប្រជុំជនផ្សារបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ | 056L | លោក សៀង ឃុន | ពីម៉ោង ១១:០០ ដល់ម៉ោង ១៤:០០ និងពីម៉ោង ១៨:០០ ដល់ ម៉ោង ២២:០០ |

| | | | | |
|---|---|---|---|---|
| | ទីប្រជុំជនផ្សារស្ទឹងត្រង់ ឃុំព្រែកក់ ស្រុកស្ទឹងត្រង់ | 057L | លោកស្រី ហេង ភីរុន | ពីម៉ោង ១៨:០០ ដល់ម៉ោង ២២:០០ |
| | ទីរួមស្រុកអូររាំងឪ | 088L | លោក ឃុន សុផល | ផ្តត់ផ្គង់ ២៤ ម៉ោងពេញ |
| **៤-កំពង់ឆ្នាំង** | ទីប្រជុំជនផ្សារពន្លៃ ឃុំពន្លៃ ស្រុកបរិបូរណ៍ | 040L | លោក ម៉ក់ ហ៊ាត | ពីម៉ោង ៤:៣០ ដល់ម៉ោង ៦:៣០ និងពីម៉ោង ១៧:០០ ដល់ម៉ោង ០:០០ |
| | ទីរួមស្រុកកំពង់ត្រឡាច | 041L | លោក ទី សុគន្ធ | ផ្គត់ផ្គង់ ២៤ ម៉ោងពេញ |
| | ទីប្រជុំជនផ្សារព្រៃខ្មែរ ឃុំអណ្តូងស្នាយ និង ឃុំរលាប្អៀរ ស្រុករលាប្អៀរ | 095L | លោកស្រី ចាន់ ស៊ីម៉ូលី | ពីម៉ោង ១៨:០០ ដល់ម៉ោង ២៣:០០ |
| | ទីប្រជុំជនផ្សារពង្រ ឃុំពង្រនិងឃុំស្វាយជ្រំ ស្រុករលាប្អៀរ | 096L | លោក ជា សារ៉េត | ពីម៉ោង ១៨:០០ ដល់ម៉ោង ២៣:០០ |
| | ទីរួមខេត្តកំពង់ឆ្នាំង | 051L | ក្រុមហ៊ុនសុវណ្ណនី អភិវឌ្ឍន៍អគ្គិសនីលីមីធីត | ផ្គត់ផ្គង់ ២៤ ម៉ោងពេញ |
| **៥-កំពង់ស្ពឺ** | ទីប្រជុំជនផ្សារត្រែងត្រយឹង ឃុំត្រែងត្រយឹង ស្រុកភ្នំស្រួច | 082L | លោក លី សុខគ្រី | ពីម៉ោង ១១:០០ ដល់ម៉ោង ២៣:៣០ |
| | ទីប្រជុំជនផ្សារបាត់ដឹង ស្រុកឧត្តុង | 099L | លោក ឡេង ម៉ូវ | ពីម៉ោង ១៨:០០ ដល់ម៉ោង ២៣:០០ |
| | ទីប្រជុំជនផ្សារត្រាំខ្នារ ឃុំជង្រុក ស្រុកគងពិសី | 064L | លោក ឈិន សេង | ពីម៉ោង ៥:០០ ដល់ម៉ោង ៦:០០ និងពីម៉ោង ១៨:០០ ដល់ម៉ោង ២៣:០០ |

| | | | | |
|---|---|---|---|---|
| | ទីប្រជុំជនផ្សារថ្នល់បត់ ឃុំពោធិ៍អង្ក្រង ស្រុកបសេដ្ឋ | 101L | លោកស្រី សូរ វិនដា | ពីម៉ោង ៤:០០ ដល់ ៦:០០, ពីម៉ោង ១១:០០ ដល់ម៉ោង ១៤:០០ និង ពីម៉ោង ១៨:០០ ដល់ម៉ោង ២៣:០០ |
| | ទីប្រជុំជនផ្សារឧត្តុង្គ ឃុំវាំងចាស់ ស្រុកឧត្តុង្គ | 076L | លោក គួច អ៊ែតរើត | ផ្តត់ផ្គង់ ២៤ ម៉ោងពេញ |
| | ទីប្រជុំជនផ្សារត្រពាំងក្រឡឹង ឃុំគីរីវ័ណ្ណ ស្រុកភ្នំស្រួច | 067L | លោក សុខ ហ៊ួយ | ពីម៉ោង ៤:៣០ ដល់ម៉ោង ៦:៣០ និងពីម៉ោង ១៧:០០ ដល់ម៉ោង ២២:៣០ |
| | ឃុំត្រពាំងគង ស្រុកសំរោងទង | 053L | លោក ឡុង ង៉ែត | ពីម៉ោង ៤:៣០ ដល់ម៉ោង ៦:៣០ និងពីម៉ោង ១៨:០០ ដល់ម៉ោង ០:០០ |
| | ឃុំទួលអំពិល ស្រុកបសេដ្ឋ | 084L | លោក ម៉ុក ជិន | ពីម៉ោង ១៧:៣០ ដល់ម៉ោង ២១:០០ |
